ខែឧសភា ឆ្នាំ២០១២

# សេរីភាពខាងព័ត៌មាននៅកម្ពុជា ៖ សិទ្ធិយល់ដឹង ឬ វប្បធម៌នៃការលាក់បាំង ?

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

Cambodian Center for Human Rights

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យ ដែលធ្វើការដើម្បីលើកកម្ពស់និងការពារ លទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស នៅព្រះរាជាណាចក្រ-កម្ពុជា (កម្ពុជា) ។ ចក្ខុវិស័យរបស់យើង គឺចង់ឲ្យកម្ពុជាក្លាយជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលក្នុងនោះប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាព ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលប្រយោជន៍ពីការអភិវឌ្ឍន៍ប្រទេស ។ ម.ស.ម.ក ចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ចង់បានស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយមដោយក្នុងនោះភាពចម្រុះបែបនៃសង្គម ត្រូវបានទទួលយកនិងសាទរ ជាជាងព្រងើយកន្តើយឬដាក់ទណ្ឌកម្ម។ និមិត្តសញ្ញារបស់ ម.ស.ម.ក រំលេចឲ្យឃើញរូបសត្វព្រាបស ហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវ ដែលនេះជានិមិត្តរូបនៃការទាមទារសេរីភាពរបស់កម្ពុជា ។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍ស្តីពី "សេរីភាពខាងព័ត៌មាននៅកម្ពុជា ៖ សិទ្ធិយល់ដឹង ឬវប្បធម៌នៃការលាក់-បាំង" (របាយការណ៍) អាចដំណើរការទៅបាន ដោយមានការឧបត្ថម្ភក្រោមជំនួយសប្បុរសធម៌ពីស្ថានទូតអង់គ្លេសប្រចាំកម្ពុជា និងអង្គការអន្តរព្រះវិហារសម្រាប់សហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍។ រាល់យោបល់ របកគំហើញ និងសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍នេះ ជាការទទួលខុសត្រូវរបស់ ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ស្ថានទូតអង់គ្លេសប្រចាំកម្ពុជា និងអង្គការអន្តរព្រះវិហារសម្រាប់សហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍ ឬម្ចាស់ជំនួយ អ្នកគាំទ្រ និងដៃគូរផ្សេងទៀតទេ ។

## ចម្ងល់ និងមតិចូលរួម

ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬមានបំណងចង់ផ្តល់មតិយោបល់ សូមផ្ញើសារមក ម.ស.ម.ក តាមរយៈ ៖ info@cchrcambodia.org ។

របាយការណ៍នេះ និងអត្ថបទបោះពុម្ពផ្សាយផ្សេងទៀតរបស់ម.ស.ម.ក អាចរកបាននៅក្នុងគេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ដែលសម្របសម្រួលដោយ ម.ស.ម.ក ។

(cc) ឆ្នាំ២០១២ ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
ផ្ទះលេខ ៧៩៨ ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# មាតិកា


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ក.ម.ស.ម)....................I

**មាតិកា** ....................II

**និយមន័យ និងពាក្យបំព្រួញ** ....................IV

**សេចក្ដីសង្ខេប** ....................VI

**១. សេចក្ដីផ្ដើម** .................... 1

១.១ កម្ពុជាសម័យបច្ចុប្បន្ន....................2

១.២ វិធីសាស្ត្រ....................3

**២. គោលការណ៍សេរីភាពខាងព័ត៌មាន និងច្បាប់**....................4

២.១ គោលការណ៍សេរីភាពខាងព័ត៌មាន .................... 5

២.២ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ .................... 7

២.៣ ច្បាប់ជាតិដែលមានស្រាប់ .................... 9

២.៤ គំនិតផ្ដួចផ្ដើមរិមជ្ឈការ និងវិសហមជ្ឈការ .................... 12

២.៥ ការវិវឌ្ឍន៍ផ្នែកច្បាប់នៅប្រទេសកម្ពុជា .................... 14

**៣. ការផ្ដត់ផ្គង់ និងតម្រូវការ**....................17

៣.១ ប្រវត្តិសង្ខេបនៃការរក្សាទុកកំណត់ត្រាព័ត៌មាននៅកម្ពុជា....................17

៣.២ តម្រូវការព័ត៌មាន .................... 18

៣.៣ វប្បធម៌គ្រប់គ្រង .................... 19

៣.៤ "បដិវត្តន៍វប្បធម៌" .................... 21

**៤. សេរីភាពខាងព័ត៌មាន និងអំពើពុករលួយ** .................... 22

៤.១ អំពើពុករលួយនៅកម្ពុជា .................... 22

៤.២ ការប្រឆាំងអំពើពុករលួយ .................... 24

៤.៣ សេរីភាពខាងព័ត៌មាន .................... 24

អនុសាសន៍ .................... 26

**៥. សេរីភាពខាងព័ត៌មាន និងសារព័ត៌មាន** .................... 28

៥.១ លទ្ធភាពទទួលបានព័ត៌មាន .................... 28

៥.២ ការចែកចាយ .................... 29

៥.៣ សេរីភាពខាងព័ត៌មាន .................... 32

អនុសាសន៍ .................... 33

**៦. សេរីភាពខាងព័ត៌មាន និងនីតិរដ្ឋ** .................... 34

៦.១ តម្លាភាពក្នុងដំណើរការនីតិបញ្ញត្តិ ........................................................ 34
៦.២ សិទ្ធិទទួលបានឯកសារសេចក្ដីវិនិច្ឆ័យផ្នែកច្បាប់ ........................................... 39
៦.៣ សេរីភាពខាងព័ត៌មាន ........................................................................ 38
អនុសាសន៍ .................................................................................. 40
**៧. សេរីភាពខាងព័ត៌មាន ធនធាន និងដីធ្លី** ................................................. 42
៧.១ ឧស្សាហកម្មនិស្សារណកម្ម ................................................................... 43
៧.២ ការបណ្ដេញចេញពីដីធ្លី ....................................................................... 47
៧.៣ សេរីភាពខាងព័ត៌មាន ........................................................................ 49
អនុសាសន៍ .................................................................................. 52
**៨. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍** ......................................................... 51
**ឯកសារយោង** ............................................................................... 53
ច្បាប់ និងកតិកាសញ្ញាអន្តរជាតិ ............................................................... 53
ច្បាប់ជាតិ .................................................................................... 53
លិខិតគតិយុត្ត ................................................................................ 53
របាយការណ៍ និងការផ្សព្វផ្សាយផ្សេងៗ ......................................................... 53
សុន្ទរកថា និងបទសម្ភាសន៍..................................................................59
សារព័ត៌មាន និងសេចក្ដីថ្លែងការណ៍...........................................................59
វែបសាយ......................................................................................59

# និយមន័យ និងពាក្យបំព្រួញ

| | |
|---|---|
| អ.ប.ព. | អង្គភាពប្រឆាំងអំពើពុករលួយ |
| អង្គការមាត្រា១៩ | ជាអង្គការសិទ្ធិមនុស្សអន្តរជាតិឈានមុខគេខាងសេរីភាពខាងការបញ្ចេញមតិ |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| អ.ប.ជ.ក | អាជ្ញាធរប្រេងជាតិកម្ពុជា |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| គ.ប្រ.ជ | គណបក្សប្រជាជនកម្ពុជា |
| វ.អ.ច.អ | ការវិវឌ្ឍន៍នៃអ៊ិនធើណេតសម្រាប់ច្បាប់អាស៊ាន |
| អ.វ.ត.ក | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| គ.ផ.ត.ឧ.ន | គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម |
| គោលការណ៍សេរីភាពខាងព័ត៌មាន | គោលការណ៍នីតិកម្មនៃសេរីភាពខាងព័ត៌មានរបស់អង្គការមាត្រា ១៩ |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ ១៩៦៦ |
| ក.ម.ផ | ក្រសួងមហាផ្ទៃ |
| ក.រ.ទ.ព.អ | ក្រសួងរដ្ឋសភា ទំនាក់ទំនងព្រឹទ្ធសភា និងអធិការកិច្ច |
| ស.ក.ភ | សាលារាជធានីភ្នំពេញ |
| ក.ឧ.ស.ទ.ប.ស | ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| ច្បាប់អង្គការ | ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨ |

| | |
|---|---|
| ស.ផ.អ.អ.ច | សម្ព័ន្ធភាពផ្សព្វផ្សាយពីអ្វីដែលអ្នកបានចំណាយ |
| ក.យ.ខ.ភ | កងយោធពលខេមរភូមិន្ទ |
| របាយការណ៍ | របាយការណ៍នេះមានចំណងជើងថា "សេរីភាពខាងព័ត៌មាននៅកម្ពុជា៖ សិទ្ធិទទួលព័ត៌មាន ឬរបួចមិនៃការលាក់បាំង? |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |
| គ.ភ.អ.ប.ប | គណៈកម្មការភាគហ៊ុន និងអត្រាប្តូរប្រាក់ |
| អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីសេរីភាពខាងការបញ្ចេញមតិ | អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីការលើកកំពស់ និង ការពារសេរីភាពខាងគំនិត និង ការបញ្ចេញមតិ |
| គ.ស.រ | គណបក្ស សម រង្ស៊ី |
| អ.ស.ប | អង្គការសហប្រជាជាតិ |
| ស.ប.ស.ស | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| អ.ប.ព.អ.ស.ប | អនុសញ្ញាប្រឆាំងអំពើពុករលួយអង្គការសហប្រជាជាតិ |
| យូអិនឌីភី | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| អ៊ុនតាក់ | អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំកម្ពុជា |
| យូសេដ | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| វីអូអេ | វិទ្យុសម្លេងសហរដ្ឋអាមេរិក |

# សេចក្ដីសង្ខេប

សិទ្ធិក្នុងការទទួលបានព័ត៌មាន ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ថាជាសិទ្ធិមនុស្សជាមូលដ្ឋាន ។ សិទ្ធិនេះក៏ជាគោលការណ៍មួយនៃលទ្ធិប្រជាធិបតេយ្យផងដែរ ។ រាជរដ្ឋាភិបាលកម្ពុជា (ហៅកាត់ «រាជរដ្ឋាភិបាល») បានបង្ហាញឆន្ទៈរបស់ខ្លួន ចំពោះសិទ្ធិសេរីភាពខាងព័ត៌មានតាមរយៈការរៀបចំសេចក្ដីព្រាងគោលនយោបាយសេរីភាពខាងព័ត៌មាន ។ ទោះជាយ៉ាងនេះក្ដី ការចង់បានព័ត៌មាន និងសិទ្ធិទទួលបានព័ត៌មានសាធារណៈ នៅតែស្ថិតឆ្ងាយពីអ្វីដែលបានចាក់ឫសនៅក្នុងសង្គមកម្ពុជា ។

របាយការណ៍នេះពិនិត្យមើល លើគោលការណ៍នៃសេរីភាពខាងព័ត៌មាន ស្ថានភាពសិទ្ធិខាងព័ត៌មានក្នុងច្បាប់អន្តរជាតិ និងផ្នែកខ្លះដែលមានចែងពីសិទ្ធិ នៅក្នុងច្បាប់ជាតិរបស់កម្ពុជា ។ របាយការណ៍នេះក៏ពិនិត្យទៅលើភាពប្រឈម ដែលប្រជាពលរដ្ឋខ្មែរសាមញ្ញពើបប្រទះជាប្រចាំថ្ងៃក្នុងការទទួលបានព័ត៌មាន ព្រមទាំងលើកឡើងជាអនុសាសន៍សម្រាប់នីតិបញ្ញត្តិ រចនាសម្ព័ន្ធ និងផ្លាស់ប្ដូរគោលនយោបាយដែលចាំបាច់ ដើម្បីធានាថាសិទ្ធិនេះត្រូវបានគោរព ស្របតាមនិយាមអន្តរ-ជាតិ ។

**ជំពូកទី១ (សេចក្ដីផ្ដើម)** នៃរបាយការណ៍នេះពន្យល់ពីសាវតា និងគោលបំណង ដើម្បីគូសបង្ហាញពីភាពប្រឈម ដែលប្រជាពលរដ្ឋខ្មែរសាមញ្ញពើបប្រទះក្នុងការទទួលព័ត៌មាន ដោយមានដាក់ជាឧទាហរណ៍ក្នុងវិស័យទាំងបួន ដែល ម.ស.ម.ក បានកំណត់ថាមានសារៈសំខាន់ ដែលគួរព្រួយបារម្ភពីសេរីភាពខាងព័ត៌មានរហូតមកដល់ពេលនេះ ដូចជាអំពើពុករលួយ បណ្ដាញផ្សព្វ-ផ្សាយ នីតិរដ្ឋ ព្រមទាំងធនធាននិងដីធ្លី ។ របាយការណ៍នេះជំរុញឲ្យរាជរដ្ឋាភិបាល លើកស្ទួយសិទ្ធិខាងព័ត៌មានក្នុងចំណោមបញ្ហាផ្សេងទៀត តាមរយៈការជំរុញឲ្យមានបទបញ្ញត្តិសេរីភាពខាងព័ត៌-មាន និងផ្ដល់ជូនអនុសាសន៍នានាដែលបញ្ញត្តិច្បាប់គួរតែមានចែង ។ ទោះបីជាយ៉ាងណា ជាការសំខាន់ណាស់ក្នុងការកត់សម្គាល់ថាការជំរុញខាងបទបញ្ញត្តិតែឯងមិនគ្រប់គ្រាន់ទេ ។ របាយការណ៍នេះក៏ផ្ដល់អនុសាសន៍ជារចនាសម្ព័ន្ធ និងយន្តការនានាដែលតម្រូវឲ្យមាន ដើម្បីសម្រួលឲ្យមានលទ្ធ-ភាពទទួលព័ត៌មានកាន់តែប្រសើរឡើង ។

**ជំពូកទី២ (សេរីភាពខាងព័ត៌មាន គោលការណ៍ និងច្បាប់ )** បង្ហាញពីសារៈសំខាន់នៃសេរីភាពខាងសារព័ត៌មាន នៅក្នុងសង្គមប្រជាធិបតេយ្យ ។ ជំពូកនេះក៏វិភាគទៅលើគោលការណ៍សេរីភាពខាងព័ត៌មាន ដែលបានបង្កើតឡើងដោយអ្នកជំនាញ និងស្ថាប័ននានាដែលធ្វើការដើម្បីលើកស្ទួយសេរីភាពខាងព័ត៌មាន និងពន្យល់ប្រាប់អំពីច្បាប់អន្តរជាតិដែលចែងអំពីសិទ្ធិទទួលបានព័ត៌មាន។ ជំពូកនេះក៏ពិនិត្យពិច័យ លើបទបញ្ញត្តិនានាដែលមានស្រាប់នៅក្នុងច្បាប់ជាតិ ដែលមាន

ចែងពីលទ្ធភាពទទួលព័ត៌មាន និងពិចារណាលើវិវឌ្ឍន៍នៃបញ្ញត្តិច្បាប់អំពីសេរីភាពខាងព័ត៌មាន និងគោលនយោបាយ ដែលមាននៅកម្ពុជាមកដល់បច្ចុប្បន្ន ។

**ជំពូកទី៣ (ផ្គត់ផ្គង់ និងតម្រូវការ)** ពន្យល់ពីច្បាប់សេរីភាពខាងព័ត៌មានត្រូវតែអមជាមួយនឹងការផ្លាស់ប្តូរក្នុង "ការផ្គត់ផ្គង់" និង "តម្រូវការ" ព័ត៌មាន ។ វប្បធម៌ហានានុក្រមនៅកម្ពុជា និងភាពខិនលំទោនគោរពដល់អាជ្ញាធរ មានន័យថាប្រជាពលរដ្ឋខ្មែរជាច្រើន ស្ទាក់ស្ទើរសាកសួរព័ត៌មាន ឬ មិនគិតថានេះជាសិទ្ធិឬតួនាទីរបស់ខ្លួន ក្នុងការធ្វើបែបនេះទេ ។ បន្ថែមពីនេះទៀត មន្រ្តីរាជការជាទូទៅគ្មានឆន្ទៈចង់ចែករំលែកព័ត៌មាន ហើយអាជ្ញាធរទាំងនោះ ហាក់ដូចជាមិនចង់ទាក់ទងជាមួយប្រជាពលរដ្ឋផងឡើយ ។ ដូចនេះ ការនាំមកនូវបទបញ្ញត្តិសេរីភាពខាងព័ត៌មានត្រូវតែអមជាមួយនឹងបដិវត្តន៍ "វប្បធម៌" អំពីទស្សនៈរបស់រដ្ឋាភិបាលនិងសាធារណជនចំពោះព័ត៌មាន ។

**ជំពូកទី៤ (សេរីភាពខាងព័ត៌មាន និងអំពើពុករលួយ)** ពិភាក្សាថាតើគោលការណ៍សេរីភាពខាងព័ត៌មាននិងច្បាប់ អាចដំណើរការបានយ៉ាងដូចម្តេច ដើម្បីកាត់បន្ថយជាអតិបរមាចំពោះការប្រព្រឹត្តិអំពើពុករលួយ ។ ទោះបីជារាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដែលតម្រូវឲ្យមានតម្លាភាព និងការផ្សព្វផ្សាយព័ត៌មានជាផ្លូវការក៏ដោយ ជំពូកនេះរៀបរាប់ អំពីមូលហេតុដែលបណ្តាលឲ្យអំពើពុករលួយបន្តរីករាលដាលក្នុងវិស័យជាច្រើនជុំវិញជីវិតរស់នៅរបស់សាធារណជន ។ ច្បាប់ដែលទើបអនុម័តស្តីពីការប្រឆាំងអំពើពុករលួយ មិនបានធានាក្នុងការផ្សព្វផ្សាយព័ត៌មាន និងមានមាត្រានានាដែលអនុញ្ញាតឲ្យលាក់ព័ត៌មានមួយចំនួន ។ ចំណុចខ្វះខាតរបស់ច្បាប់នេះលើកឡើងជាកង្វល់ ថាតើព័ត៌មានដែលប្រមូលបានក្រោមបញ្ញត្តិច្បាប់នេះនឹងត្រូវប្រើឲ្យមានប្រសិទ្ធភាព ក្នុងការដោះស្រាយបញ្ហាអំពើពុករលួយ ឬយ៉ាងណានៅកម្ពុជា។ ជំពូកនេះបានបញ្ចប់ដោយលើក នូវសំណើឲ្យមានវិសោធនកម្មច្បាប់ ដែលត្រូវអនុវត្តដើម្បីធានាឲ្យមានការបើកចំហព័ត៌មានជាសាធារណៈ ។

**ជំពូកទី៥ (សេរីភាពខាងព័ត៌មាន និងបណ្តាញផ្សព្វផ្សាយ)** ពិនិត្យពិច័យថាតើកខ្វះខាតលទ្ធ-ភាពទទួលព័ត៌មាន មានផលប៉ះពាល់ទៅលើបណ្តាញផ្សព្វផ្សាយ ហើយនិងភារកិច្ចរបស់ខ្លួនដើម្បីរក្សាឲ្យសាធារណជន ដឹងពីការរាយការណ៍លើបញ្ហារបស់ផលប្រយោជន៍សាធារណៈដោយរបៀបណា ។ អ្នកសារព័ត៌មានជាច្រើន ដែល ម.ស.ម.ក បានសម្ភាសក្នុងពេលស្រាវជ្រាវរបាយការណ៍នេះ បានកត់សម្គាល់ឃើញថាមានចំណុចវិជ្ជមាន ក្នុងការសុំព័ត៌មានពីក្រសួងរដ្ឋាភិបាលនានា ក្រោមច្បាប់របបសារព័ត៌មានឆ្នាំ១៩៩៥ និងវិវឌ្ឍន៍ក្នុងលទ្ធភាពទទួលព័ត៌មាន ពីក្រសួងរដ្ឋាភិបាលនានាតាំងពីមានការតែងតាំងអ្នកនាំពាក្យ នៅតាមក្រសួងស្ទើរតែទាំងអស់ ។ ប៉ុន្តែអ្នកកាសែតដែលបានសម្ភាសនោះ បានពន្យល់ថា ឧបសគ្គក្នុងការទទួលព័ត៌មាននៅតែកើតមាន ជាពិសេសនៅ ពេលព័ត៌មានដែលស្នើសុំនោះ ផ្ទុយទៅនឹងផលប្រយោជន៍ និងឆ្លុះបញ្ចាំងមិនល្អពីរដ្ឋាភិបាល ។ ជំពូកនេះបញ្ចប់ដោយលើកសំណើឲ្យមានវិសោធនកម្មមួយចំនួន ដែលអាចធ្វើឲ្យច្បាប់របបសារព័ត៌មាន

ធានា ពីលទ្ធភាពទទួលព័ត៌មាន និងលើកអនុសាសន៍ឲ្យមានវិធានការផ្សេងទៀត ដែលអាចបង្កើន សេរីភាពខាងព័ត៌មាន និងសម្រាលលទ្ធភាពបណ្តាញព័ត៌មានក្នុងការផ្សាយព័ត៌មានពីរដ្ឋាភិបាល ។

**ជំពូកទី៦ (សេរីភាពខាងព័ត៌មាន និងនីតិរដ្ឋ)** ពិភាក្សាពីសារៈសំខាន់នៃការទទួលព័ត៌មាន អំពីការអភិវឌ្ឍនៃនីតិរដ្ឋនៅកម្ពុជា ។ ជំពូកនេះបរិយាយអំពីសារៈសំខាន់ ដែលសាធារណជនទទួល បានព័ត៌មានអំពីសេចក្តីព្រាងច្បាប់ ហើយពន្យល់ថា ការទទួលបានព័ត៌មាននេះទៀតសោត ហាក់រឹត តែមានលក្ខណៈទូលំទូលាយថែមទៀត ល្ពឹកណាសេចក្តីព្រាងច្បាប់នោះ ពុំត្រូវបានចាត់ទុកថាមាន លក្ខណៈរសើបខាងនយោបាយ ។ នៅពេលដែលសេចក្តីព្រាងច្បាប់ ត្រូវបានគេមើលឃើញថាមាន លក្ខណៈរសើបខាងនយោបាយ ដូចក្នុងករណីសេចក្តីព្រាងច្បាប់ ស្តីពីសមាគមនិងអង្គការមិនមែន រដ្ឋាភិបាលដែលត្រូវបានគេទុកចោល គេឃើញថាព័ត៌មានពុំត្រូវបានចែកផ្សាយយ៉ាងឆាប់រហ័ស នោះទេ ហើយកិច្ចពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល ត្រូវបានចាត់ទុកជាកិច្ចពិគ្រោះយោបល់ ដែលគ្មានអត្ថន័យមួយ ។ ជំពូកមួយនេះក៏ពិចារណាផងដែរ អំពីរបៀបដែលកម្រិតលទ្ធភាពរបស់ សាធារណជន ក្នុងការទទួលបានព័ត៌មានអំពីសាលក្រមនានាផងដែរ ។ មានឧទាហរណ៍វិជ្ជមាន មួយចំនួន ចេញពីករណីដែលតុលាការខ្លះតែងតែផ្សព្វផ្សាយសេចក្តីសម្រេចរបស់ខ្លួន ហើយរបាយ-ការណ៍នេះ ជំរុញឲ្យតុលាការកម្ពុជាទាំងអស់ យកតម្រាប់តាមការអនុវត្តបែបនេះ ។

**ជំពូកទី៧ (សេរីភាពខាងព័ត៌មាន ព្រមទាំងធនធាននិងដីធ្លី )** សូមកត់សម្គាល់ថាសេរីភាព ខាងព័ត៌មាននិងលទ្ធភាពទទួលព័ត៌មាន អាចជួយប្រទេសឲ្យជៀសផុតពី "បណ្តាសាធនធាន" ក្នុង ពេលធ្វើឲ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ និងលើកស្ទួយស្ថិរភាពសង្គមនិងសេដ្ឋកិច្ច ឲ្យកាន់ តែប្រសើរ ។ បណ្តាសាធនធាននេះគឺជាប្រតិមតិមួយ ដោយក្នុងនោះប្រទេសនិងតំបន់សម្បូរណ៍ ធនធានធម្មជាតិ រងគ្រោះពីកំណើនសេដ្ឋកិច្ចទាប និងការអភិវឌ្ឍអន់ថយជាងមុន ពីហេតុនៃកត្តា ផ្សេងគ្នាជាច្រើន រាប់ទាំងកង្វះការគ្រប់គ្រងធនធានឲ្យបានត្រឹមត្រូវ និងអំពើពុករលួយ ជាដើម ។ កិច្ចសន្យានានាទាក់ទងនឹងធនធានមួយភាគធំ ហាក់ត្រូវបានគេរក្សាជាការសម្ងាត់ ហើយក្នុងករណី មួយចំនួន ការរក្សាជាការសម្ងាត់នេះត្រូវបានគាំពារដោយច្បាប់ ដែលចែងឲ្យមានការរក្សាជាការ សម្ងាត់បែបនោះតែម្តង ។ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីការផ្តល់សម្បទានដីធ្លី ក៏ពុំត្រូវបាន ផ្តល់ព័ត៌មានឲ្យបានច្រើន ឬក៏ត្រូវបានគេមកពិគ្រោះយោបល់ឲ្យបានក្បោះក្បាយនោះឡើយ ។ ជា លទ្ធផល សំណួរនៅតែបន្តចោទឡើង ថាតើនរណាទទួលផលប្រយោជន៍ ពីបណ្តាប្រតិបត្តិការទាំង នេះ ។ តម្លាភាពនិងលទ្ធភាព ទទួលបានព័ត៌មានច្បាស់លាស់និងទាន់ពេលវេលា ជុំវិញប្រតិបត្តិការ ទាំងនោះ គឺជាសម្លក់សំខាន់ដើម្បីជៀសវាងការគ្រប់គ្រងធនធានពុំបានត្រឹមត្រូវ រីឯសេរីភាពនៃការ ផ្តល់ព័ត៌មានវិញនោះ ដើរតួជាស្នូលសម្រាប់ផ្តល់នូវលទ្ធភាពទទួលបានទាំងនោះ ។

**ជំពូកទី៨ (សេចក្តីសន្និដ្ឋាន និងអនុសាសន៍)** ផ្តល់សេចក្តីបញ្ចប់ដល់របាយការណ៍មួយនេះ ដោយអំពាវនាវឲ្យរាជរដ្ឋាភិបាល អនុម័តច្បាប់សេរីភាពខាងព័ត៌មាន និងដោយផ្តល់នូវអនុសាសន៍ ជុំវិញខ្លឹមសារបញ្ញត្តិទាំងឡាយ ដែលច្បាប់នោះគួរមានចែង ។ គួរបញ្ជាក់ជាថ្មីម្តងទៀត ថាការផ្លាស់

ប្តូរពិតប្រាកដនឹងចេញជារូបរាងបាន ដរាបមានការផ្លាស់ប្តូរវប្បធម៌ និងឥរិយាបទចំពោះព័ត៌មាន ។ នេះមានន័យសំដៅដល់ មិនត្រឹមតែតម្រូវការរបស់សាធារណជន ដើម្បីទទួលបានព័ត៌មានប៉ុណ្ណោះទេ តែថែមទាំងសំដៅដល់ការទទួលស្គាល់ដោយមន្ត្រីសាធារណៈ ចំពោះឥទ្ធិពលនៃព័ត៌មាននិងសេចក្តីត្រូវការរបស់សាធារណជនទូទៅ ក្នុងការទទួលបានព័ត៌មាន ថាជាធាតុសំខាន់មួយសម្រាប់អភិវឌ្ឍជាបន្តបន្ទាប់ នូវលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។

# ១. សេចក្តីផ្តើម

សិទ្ធិក្នុងការទទួលបានព័ត៌មានដែលគ្រប់គ្រងដោយស្ថាប័នសាធារណៈ សំដៅដល់ "សេរីភាពខាងព័ត៌មាន" "សិទ្ធិយល់ដឹង" ឬ "សិទ្ធិខាងព័ត៌មាន" ។ មានការទទួលស្គាល់ជាទូទៅ ថាសិទ្ធិក្នុងការទទួលបានព័ត៌មាន ជាសិទ្ធិមូលដ្ឋាន ហើយផ្សារភ្ជាប់ពីកំណើតជាមួយនឹងសិទ្ធិដទៃទៀត ដូចដែលលើកឡើងនៅក្នុងនីតិកាលទី១ របស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ (អ.ស.ប) នៅឆ្នាំ១៩៤៦ ថា ៖ "សេរីភាពខាងព័ត៌មានជាសិទ្ធិមនុស្សមូលដ្ឋាន និងជាគំរូនៃសេរីភាពទាំងអស់ ដែលអ.ស.បបានប្រកាសឡើង ។"[1]

> "អ្នកជំនាញខាងដោះស្រាយទំនាស់ តែងតែដកស្រង់ថា ការយកព័ត៌មានមិនគ្រប់គ្រាន់ និងមិនច្បាស់លាស់ ជាប្រភពដ៏មានសក្តានុពលភាពនៃទំនាស់។ សន្មត់ថាជាការពិត នោះគេអាចអះអាងស្រដៀងគ្នានឹង អ្នកតស៊ូមតិសិទ្ធិមនុស្សជាច្រើនបានទាមទារដែរនាពេលថ្មីៗនេះ ថាសម្រាប់សង្គមក្រោយសង្គ្រាម មានកម្ពុជាជាដើម លំហូសេរីនៃព័ត៌មាន ជាពិសេសចេញពីស្ថាប័នសាធារណៈ គឺសំខាន់ណាស់ក្នុងការកសាង និងរក្សាស្ថេរភាព ដំណើរការលទ្ធិប្រជាធិបតេយ្យ និង ធ្វើឲ្យប្រជាពលរដ្ឋទទួលបានចំណាប់អារម្មណ៍ ការជូនដំណឹង និងមានការចូលរួម" ។
>
> រ៉ាយមុន លីអូ ២០០៩ 'លទ្ធភាពទទួលព័ត៌មាន នៅអាស៊ីអាគ្នេយ៍' ទំព័រ ១។

លទ្ធភាពទទួលបានព័ត៌មានគឺមានទំនាក់ទំនង នឹងធាតុផ្សំមូលដ្ឋាននៃអភិបាលកិច្ចល្អដូចជាតម្លាភាព និងគណនេយ្យភាព ហើយសេរីភាពខាងព័ត៌មានគឺមានសារៈសំខាន់ ក្នុងការបង្កើតឲ្យមានទំនុកចិត្ត និងជំនឿចិត្តចំពោះរដ្ឋាភិបាល ។[2] ប្រសិនគ្មានការទទួលព័ត៌មានទេ ប្រជាពលរដ្ឋនឹងមិនដឹង អំពីបញ្ហានានាដែលប៉ះពាល់ដោយផ្ទាល់ដល់ជីវិតរបស់ពួកគាត់ឡើយ ។ បើគ្មានការទទួលព័ត៌មាន អ្នកសារព័ត៌មានមិនអាចបំពេញតួនាទីរបស់ខ្លួន ក្នុងការផ្សាយជូនសាធារណជនពីបញ្ហានានា ដើម្បីជាប្រយោជន៍សាធារណៈបានឡើយ ។ បើគ្មានការទទួលព័ត៌មាន នោះគេនឹងមិនច្បាស់ ថាតើយុត្តាធិការតុលាការមានយុត្តិធម៌ ដែរឬយ៉ាងណាឡើយ ។ បើគ្មានការទទួលព័ត៌មាន រដ្ឋាភិបាលនឹងប្រឈមមុខនឹងការលំបាក ក្នុងការសម្រេចបញ្ហាសាធារណៈសំខាន់ៗ ហើយសាធារណជននឹងត្រូវបានគេប្លន់យក នូវឱកាសក្នុងការដឹងអំពីរបៀបនិងមូលហេតុ ដែលនាំឲ្យមានសេចក្តីសម្រេចចិត្តបែបនោះ ។ ជារួមមក ការទទួលបានព័ត៌មានជាគោលការណ៍មូលដ្ឋានមួយនៃលទ្ធិប្រជាធិបតេយ្យ និងបែងចែកភាពខុសគ្នារវាងរដ្ឋាភិបាលប្រជាធិបតេយ្យ ទល់នឹងរបបដែលគ្មានគណនេយ្យភាព និងធ្វើសកម្មភាពប្រកបដោយភាពកំបាំង ។

---

[1] អង្គការមាត្រា១៩ (ថុមប៊ី មេនឌែល) " សេរីភាពខាងព័ត៌មានជាសិទ្ធិមនុស្សដែលត្រូវការពារជាអន្តរជាតិ" ទំព័រ១

[2] សង្ខេបនៃសេចក្តីថ្លែងការណ៍របស់ ឯកឧត្តម ខៀវ កញ្ញារិទ្ធិ រដ្ឋមន្ត្រី ក្រសួងព័ត៌មាន នៅក្នុងសិក្ខាសាលាស្តីពី លទ្ធភាពទទួលបានព័ត៌មាន នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០ នៅភ្នំពេញ សូមអាន របាយការណ៍របស់ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ ស្តីពី លទ្ធភាពទទួលព័ត៌មាន និងរដ្ឋសភា ខែធ្នូ ឆ្នាំ២០១០ ទំព័រទី៨ ។

## ១.១ កម្ពុជាសម័យបច្ចុប្បន្ន

រាជរដ្ឋាភិបាលបានប្រកាសជាសាធារណៈ នូវឆន្ទៈរបស់ខ្លួនចំពោះសិទ្ធិសេរីភាពខាងព័ត៌មាន ។ នៅឆ្នាំ២០០៣ កម្មវិធីកំណែទម្រង់ផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានអះអាងថា *"លទ្ធភាពទទួលបានព័ត៌មានដោយសេរី ...ជាតម្រូវការមូលដ្ឋាន សម្រាប់ដំណើរការលទ្ធិប្រជាធិបតេយ្យសេរីនិយម"*[3] មានសញ្ញាជំរុញជាច្រើន បានបញ្ជាក់ថារដ្ឋាភិបាលមានឆន្ទៈ ក្នុងការបង្កើតគោលនយោបាយសេរីភាពខាងព័ត៌មាន និងបទបញ្ញត្តិ ទោះបីជាដំណើរការនេះត្រូវបានកកស្ទះមកដល់ពេលនេះក៏ដោយ (សូមមើលជំពូកទី២) ។

ប៉ុន្តែ សិទ្ធិក្នុងការទទួលព័ត៌មានបានងាកចេញឆ្ងាយ នៅក្នុងសង្គមកម្ពុជា ។ ម្យ៉ាងទៀត ប្រពៃណីឋានានុក្រមបង្ហាញថា ប្រជាពលរដ្ឋខ្មែរស្ទាក់ស្ទើរក្នុងស្នើសុំព័ត៌មាន ឬគិតថាខ្លួនមិនមានតួនាទីក្នុងនាមជាពលរដ្ឋ ក្នុងការជ្រៀតជ្រែកកិច្ចការរបស់អាជ្ញាធរ ទោះបីជាប្រពៃណីនេះកំពុងតែផ្លាស់ប្តូរយ៉ាងយឺតៗក៏ដោយ ។ ម្យ៉ាងវិញទៀតរដ្ឋាភិបាលហាក់ពុំចង់ចែករំលែកព័ត៌មាន ដោយខ្លួនយល់ឃើញថា កិច្ចការនេះពុំមែនជាទំនួលខុសត្រូវនិងហួសពីទំនួលខុសត្រូវរបស់ខ្លួន (សូមមើលជំពូកទី៣)។

គោលបំណងសំខាន់នៃរបាយការណ៍នេះ គឺជំរុញឲ្យរដ្ឋាភិបាល បន្តកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការទទួលយក ច្បាប់បញ្ញត្តិសេរីភាពខាងព័ត៌មាន និងជួយសម្រួល ឲ្យលទ្ធភាពទទួលព័ត៌មានបានរឹតតែប្រសើរឡើង ។ របាយការណ៍នេះពិចារណា ទៅលើគោលការណ៍សេរីភាពបញ្ចេញមតិស្ថានភាពនៃសិទ្ធិសេរីភាពខាងព័ត៌មាន នៅក្នុងច្បាប់អន្តរជាតិ ព្រមទាំងថាតើលទ្ធភាពទទួលព័ត៌មានត្រូវបានដោះស្រាយ នៅក្នុងច្បាប់ខ្មែរបែបណាខ្លះ ។ របាយការណ៍នេះក៏ពិនិត្យទៅលើការលំបាក ដែលប្រជាពលរដ្ឋសាមញ្ញពើបប្រទះប្រចាំថ្ងៃនៅពេលដែលខ្លួនចង់ទទួលបានព័ត៌មាន ។ របាយការណ៍ នេះយកឧទាហរណ៍នៅក្នុងវិស័យទាំង ៤ ដែល ម.ស.ម.ក បានកំណត់ ថាជាការសំខាន់ដែលគួរព្រួយបារម្ភ ពីសេរីភាពខាងព័ត៌មានមកដល់ពេលនេះ មានដូចជា អំពើពុករលួយ (ជំពូកទី៤) បណ្តាញផ្សព្វផ្សាយ(ជំពូកទី៥) នីតិរដ្ឋ(ជំពូកទី៦) ព្រមទាំងធនធាន និងដីធ្លី(ជំពូកទី៧) មកប្រើប្រាស់ ។ របាយការណ៍នេះក៏បង្ហាញពីរចនាសម្ព័ន្ធ និងយន្តការនានាដែលតម្រូវឲ្យមាន ដើម្បីសម្រួលឲ្យមានលទ្ធភាពទទួលព័ត៌មានកាន់តែប្រសើរឡើង និងផ្តល់អនុសាសន៍នានា សម្រាប់ខ្លឹមសាររបស់ច្បាប់សេរីភាពខាងព័ត៌មាន ។ ប៉ុន្តែ ច្បាប់បែបនេះតែម្យ៉ាង មិនអាចដោះស្រាយភ្លាមៗចំពោះវត្តមានតម្លាភាព និងទំនួលខុសត្រូវ ដែលមានជាទូទៅនៅកម្ពុជាបច្ចុប្បន្ននេះ នោះទេ ។ ទាំងនេះត្រូវឲ្យមានការផ្លាស់ប្តូរ ក្នុងស្មារតីរបស់រាជរដ្ឋាភិបាល និងសាធារណជន ថាប្រភេទព័ត៌មានណាដែលអាចមានលទ្ធភាពទទួលបាន ហើយថាតើអាចទទួលបានតាមរបៀបណា ។

---

[3] ក្រុមប្រឹក្សាកំណែទម្រង់យុត្តិធម៌ មិថុនា ២០០៣ "ច្បាប់ និងកំណែទម្រង់យុត្តិធម៌" ទំព័រទី១០ អាចរកបាននៅ www.cljr.gov.kh/eng/library/doc/o6-Legal.and.Judiciary.Reform.Strategy.pdf.

## ១.២ វិធីសាស្ត្រ

ក្នុងការកសាងទឡ្ហីករណ៍ សម្រាប់បទបញ្ញត្តិសេរីភាពខាងព័ត៌មាននេះ និងរចនាសម្ព័ន្ធនិងយន្តការនានាដែលពាក់ព័ន្ធសម្រាប់កម្ពុជា ម.ស.ម.ក ធ្វើការស្រាវជ្រាវដោយផ្អែកលើឯកសារ និងមានសម្ភាសអ្នកពាក់ព័ន្ធដែលចាប់អារម្មណ៍មួយចំនួន ។

របាយការណ៍នេះបានដកស្រង់ យករបាយការណ៍ស្តីពីសេរីភាពខាងព័ត៌មាននានា ដែលសរសេរដោយអ្នកជំនាញនិងស្ថាប័នផ្សេងៗ ដែលធ្វើការដើម្បីលើកស្ទួយ សេរីភាពខាងព័ត៌មានជុំវិញពិភពលោក រួមមាន ៖ តូប៊ី មេនឌេល, អេគ្រូ អេលេស្ទូន, និងអង្គការមាត្រា១៩ ។ របាយការណ៍នេះក៏សំដៅទៅលើវណ្ណកម្ម របស់អ្នកសិក្សានៅកម្ពុជា ដែលបានស្រាវជ្រាវពិនិត្យទៅលើបញ្ហានេះ ដូចជាលោកសាស្ត្រាចារ្យ រេមុន លីអូ ។ ក្នុងការចងក្រងរបាយការណ៍នេះ ម.ស.ម.ក បានប្រើទិន្នន័យ ព័ត៌មាន និងការវិភាគរបស់គណៈកម្មការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងអ្នករាយការណ៍ពិសេស នៃអង្គការសហប្រជាជាតិ ដើម្បីលើកស្ទួយ និងការពារសិទ្ធិសេរីភាពខាងបញ្ចេញមតិ និងយោបល់ (អ្នករាយការណ៍ពិសេសស្តីពីសេរីភាពខាងបញ្ចេញមតិ) ។ នៅក្នុងការវិភាគលើបទបញ្ញត្តិសេរីភាពបញ្ចេញមតិ ដើម្បីជាមធ្យោបាយបង្កើន និងពង្រឹងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យសិទ្ធិមនុស្សរបស់កម្ពុជា ម.ស.ម.ក បានប្រើប្រភពបណ្តាញផ្សព្វផ្សាយជាច្រើន ដែលបានរាយការណ៍ពីស្ថានភាពនៅកម្ពុជា រួមមានសារព័ត៌មាន ៖ ភ្នំពេញប៉ុស្តិ៍ ឌឹខេមបូឌាដេលី វិទ្យុអាស៊ីសេរី និងវិទ្យុសម្លេងសហរដ្ឋអាមេរិក ។

ម.ស.ម.ក ក៏បានសម្ភាសអ្នកសារព័ត៌មានជាច្រើន ដើម្បីពិភាក្សាលើបញ្ហា សេរីភាពខាងព័ត៌មាន ព្រោះនេះពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយ(ជំពូកទី៥) ។ ការសម្ភាសទាំងនេះបានធ្វើឡើងនៅក្រុងភ្នំពេញ ។ តាមការស្នើសុំពីអ្នកតបសម្ភាសន៍ ឈ្មោះរបស់អ្នកសារព័ត៌មាននិង ការចេញផ្សព្វផ្សាយដែលពាក់ព័ន្ធសូមរក្សាការសម្ងាត់ ។ សារៈសំខាន់មិនចាំបាច់ផ្អែកលើពួកគាត់ទាំងនេះជានរណា ឬកន្លែងណាដែលពួកគាត់ធ្វើការនោះទេ ប៉ុន្តែគឺខ្លឹមសារពីអ្វីដែលពួកគាត់បាននិយាយទាក់ទង នឹងបទពិសោធន៍ក្នុងការទទួលព័ត៌មាននៅកម្ពុជា ។

# ២. គោលការណ៍សេរីភាពខាងព័ត៌មាន និងច្បាប់

សេរីភាពខាងព័ត៌មាន គឺមានភាពចាំបាច់ជាខ្លាំងចំពោះលទ្ធិប្រជាធិបតេយ្យ ។ យោងតាមកំណត់សម្គាល់របស់ អាប៊ីត ហ៊ូសេន ដែលជាអតីតអ្នករាយការណ៍ពិសេស ស្តីពីសេរីភាពបញ្ចេញមតិ នៅក្នុងរបាយការណ៍របស់លោកក្នុងឆ្នាំ១៩៩៥ ទៅកាន់គណកម្មការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ៖ "សេរីភាពទាំងអស់ នឹងគ្មានប្រសិទ្ធភាពទាំងស្រុង ប្រសិនមនុស្សគ្មានលទ្ធភាពទទួលបានព័ត៌មាន ។ លទ្ធភាពទទួលបានព័ត៌មាន ជាមូលដ្ឋានគ្រឹះក្នុងជីវភាពប្រជាធិបតេយ្យ ។ ដូច្នេះ និន្នាការនៃការរក្សាទុកព័ត៌មាន មិនឲ្យសាធារណជនទូទៅដឹង គួរតែត្រូវត្រួតពិនិត្យឲ្យបានម៉ត់ចត់" ។[4]

> *"លំហូរព័ត៌មាន និងគំនិតដ៏សេរី គឺមាននៅក្នុងបេះដូងនៃសញ្ញាណប្រជាធិបតេយ្យ និងមានសារៈសំខាន់ចំពោះការគោរពយ៉ាងមានប្រសិទ្ធភាពចំពោះសិទ្ធិមនុស្ស (...) សំខាន់បំផុតសម្រាប់ធានានូវការអនុវត្តន៍លំហូរដ៏សេរីនៃព័ត៌មាន និងគំនិត គឺជាគោលការណ៍ដែលស្ថាប័នសាធារណៈមិនមែនត្រឹមតែរក្សាព័ត៌មានទុកសម្រាប់តែខ្លួនគេនោះទេ ប៉ុន្តែគឺតំណាងឲ្យសាធារណជន" ។*
>
> *-អាប់ឌុល វ៉ាហ៊ីត ខាន់ ជំនួយការ អគ្គនាយក ផ្នែកទំនាក់ទំនង និងព័ត៌មាន នៅអង្គការការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ*

លទ្ធិប្រជាធិបតេយ្យ សំដៅដល់ប្រជាពលរដ្ឋដែលសកម្ម និងទទួលបានព័ត៌មានគ្រប់គ្រាន់ និងការចូលរួមរបស់ប្រជាពលរដ្ឋទាំងនេះក្នុងសង្គម ។ លទ្ធិប្រជាធិបតេយ្យ តម្រូវឲ្យមានលទ្ធភាពទទួលបានព័ត៌មានយ៉ាងបើកចំហ អំពីអ្វីដែលរដ្ឋាភិបាលកំពុងតែធ្វើតំណាងឲ្យប្រជាពល-រដ្ឋ ដើម្បីធានាថាសកម្មភាពទាំងនោះ ពិតជាតំណាងឲ្យឆន្ទៈរបស់ប្រជាពលរដ្ឋ ដែលមានការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ និងដើម្បីឲ្យប្រជាពលរដ្ឋអាចអនុវត្តនូវជម្រើសដែលទទួលបានព័ត៌មានគ្រប់គ្រាន់ នៅពេលដែលធ្វើការជ្រើសរើសរដ្ឋាភិបាល ។ ដូច្នេះ ព័ត៌មានដែលគ្រប់គ្រងដោយអាជ្ញា-ធរសាធារណៈ គួរតែត្រូវបានពិនិត្យ ថាមិនមែនផ្តល់ប្រយោជន៍ចំពោះតែមន្ត្រីសាធារណៈ ឬអ្នកនយោបាយនោះទេ តែសម្រាប់សាធារណជនទាំងមូល ។

លទ្ធភាពទទួលបានព័ត៌មាន ក៏ជាមធ្យោបាយដ៏សមហេតុសមផលមួយ ដើម្បីបង្កើតនូវសង្គមដ៏ល្អប្រសើរមួយផងដែរ ។[5] ការទទួលបានព័ត៌មាន គឺចាំបាច់សម្រាប់គោលបំណងនៃសង្គមប្រជាធិបតេយ្យ និងយុត្តិធម៌ គឺដើម្បីធានាថារដ្ឋាភិបាលមានតម្លាភាព និងគណនេយ្យភាព ដើម្បីសម្រួលឲ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងជីវភាពសាធារណៈ ដើម្បីបង្កើននូវកិច្ចពិភាក្សារវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋនិងដើម្បីបង្កើតលក្ខខណ្ឌវិជ្ជមាន សម្រាប់ការវិនិយោគ ។

---

[4] គណៈកម្មការសិទ្ធិមនុស្ស សម័យប្រជុំលើកទី៥១ ដោយលោក អាប៊ីដ ហ៊ូសេន ស្តីពី "របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ និងការការពារសេរីភាពខាងគំនិត និងខាងការបញ្ចេញមតិ" ឯកសាររបស់អង្គការសហប្រជាជាតិ E/CN.4/1995/32, ឃ្លាទី៣៥ ចុះផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៤ ។

[5] អេនគ្រូ អ៊ីលេស្លូន ស្តីពី "សំណើរយុទ្ធសាស្ត្រសម្រាប់សេរីភាពខាងព័ត៌មាននៅប្រទេសកម្ពុជា" ចុះផ្សាយខែកញ្ញា ឆ្នាំ២០០៨

**អង្គការមាត្រា១៩ ៖ គោលការណ៍សេរីភាពខាងព័ត៌មាន**

1. **ការបើកបង្ហាញជាអតិបរមា៖**
   បញ្ញត្តិសេរីភាពខាងព័ត៌មានគួរត្រូវបានដឹកមុខដោយការបើកបង្ហាញជាអតិបរមា ។
2. **កាតព្វកិច្ចផ្សព្វផ្សាយ ៖**
   ស្ថាប័នសាធារណៈ គួរមានកាតព្វកិច្ចផ្សព្វផ្សាយព័ត៌មានសំខាន់ៗ ។
3. **ការលើកស្ទួយឲ្យមានរដ្ឋាភិបាលដែលបើកចំហ ៖**
   ស្ថាប័នសាធារណៈ ត្រូវតែលើកស្ទួយឲ្យមានរដ្ឋាភិបាលដែលបើកចំហ ។
4. **វិសាលភាពដែលមានកម្រិតក្នុងករណីលើកលែង ៖**
   ករណីលើកលែង គួរត្រូវបានចែងឲ្យបានច្បាស់ និងចង្អៀតបំផុត ហើយត្រូវឆ្លងកាត់ការសាកល្បងផ្នែក "គ្រោះថ្នាក់" និង"ផលប្រយោជន៍សាធារណៈ" តឹងតែងបំផុត ។
5. **ដំណើរការដើម្បីសម្របសម្រួលលទ្ធភាពទទួលបានព័ត៌មាន ៖**
   សំណើសួមព័ត៌មានគួរត្រូវបានដំណើរការយ៉ាងឆាប់រហ័ស និងដោយយុត្តិធម៌ ហើយការត្រួតពិនិត្យឯករាជ្យមួយចំពោះការបដិសេធណាមួយនោះគួរត្រូវធ្វើឡើង ។
6. **សោហ៊ុយចំណាយ ៖**
   បុគ្គលគ្រប់រូបមិនគួរត្រូវបានគេរាំងស្ទះ ក្នុងការស្នើសុំព័ត៌មានដោយសារតែការចំណាយសោហ៊ុយខ្ពស់នោះទេ ។
7. **កិច្ចប្រជុំដែលបើកចំហ ៖**
   កិច្ចប្រជុំរបស់ស្ថាប័នសាធារណៈ គួរបើកចំហដល់សាធារណៈជនឲ្យបានដឹងឮ ។
8. **ការបើកបង្ហាញត្រូវមានអាទិភាពជាង ៖**
   ច្បាប់នានាដែលផ្ទុយពីគោលការណ៍បើកបង្ហាញជាអតិបរមានោះ គួរត្រូវបានធ្វើវិសោធនកម្ម ឬលុបចោល ។
9. **កិច្ចការពារដល់អ្នកផ្តល់ព័ត៌មាន ៖**
   បុគ្គលគ្រប់រូបដែលផ្សព្វផ្សាយព័ត៌មានអំពីកំហុសឆ្គង ពោលគឺអ្នកផ្តល់ព័ត៌មាននោះ ត្រូវទទួលបានការការពារ ។

ក្នុងជំពូកទី៤ ដល់ទី៧ នឹងមានការពិនិត្យមើលបន្ថែមទៀត ថាតើគោលបំណងទាំងនេះ អាចសម្រេចបានក្នុងកម្រិតណានៅកម្ពុជា ។

## ២.១ គោលការណ៍សេរីភាពខាងព័ត៌មាន

តំណាងពិសេស ស្តីពីសេរីភាពបញ្ចេញមតិ បច្ចុប្បន្ន លោក ហ្វ្រែង ឡារូហ៍ បានកត់សម្គាល់ថា ក្នុងទសវត្សរ៍ចុងក្រោយនេះ សេរីភាពខាងព័ត៌មានត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាសិទ្ធិមនុស្សមូលដ្ឋាន ដែលសម្គាល់មើលលើការអនុម័តច្បាប់ ស្តីពីសេរីភាពខាងព័ត៌មាន[6] ហើយចំនួនប្រទេស ដែលអនុវត្តច្បាប់នេះមានការកើនឡើងយ៉ាងខ្លាំងរាល់ឆ្នាំ ។[7] ដោយមានការទទួលស្គាល់ កាន់តែច្រើនឡើងៗ និងការកំណត់លទ្ធភាព ទទួលបានព័ត៌មានជាវឌ្ឍនភាព នៃដំណើរការលទ្ធិប្រជាធិបតេយ្យនោះ អង្គការអន្តរជាតិជាច្រើនបាននឹង កំពុងធ្វើការលើកកម្ពស់សិទ្ធិ និងតស៊ូ មតិឲ្យមានការអនុវត្ត និងការធានាបាន នូវសិទ្ធិទាំងនោះ ។

អង្គការមាត្រា១៩ ដែលជាអង្គការសិទ្ធិ មនុស្សអន្តរជាតិឈានមុខមួយ ស្តីអំពីសេរីភាពបញ្ចេញមតិ បានតាក់តែងនូវគោលការណ៍ ដែល មានឈ្មោះថា "*សិទ្ធិរបស់សាធារណជនក្នុងការ*

---

[6] អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ និងការការពារសេរីភាពខាងគំនិត និងខាងការបញ្ចេញមតិ ចុះផ្សាយថ្ងៃទី២៥ ខែមិនា ឆ្នាំ ២០១០ ស្តីពី "សេចក្តីប្រកាសរួមខួបលើកទី១០ ៖ ការប្រឈម១០ចំណុចរបស់សេរីភាពខាងការបញ្ចេញមតិនាទសវត្សខាងមុខ" A/HRC/14/23/Add.2, ឃ្លាទី៩ អាចរកមើលបានលើគេហទំព័រដែលមានអាសយដ្ឋាន៖ www2.ohchr.org/english/bodies/hrcouncil/docs/14session/A.HRC.14.23.Add.2_en.pdf.

[7] នាយកវិទ្យាស្ថានធនធានពិភពលោកផ្តួចផ្តើមលទ្ធភាពទទួលបានព័ត៌មាន លោក ឡាលាណាត់ ដេ ស៊ីលវា បានធ្វើការកត់សម្គាល់ក្នុងបទសម្ភាសន៍កាលពីឆ្នាំ២០១០ ថា ក្នុងចំណោមច្បាប់ចំនួន៨០ ដែលរួមទាំងច្បាប់សេរីភាពខាងព័ត៌មាន ដែលត្រូវបានអនុម័តនៅលើពិភពលោកនេះ ភាគច្រើនត្រូវបានដាក់ចេញចាប់ពីឆ្នាំ២០០៥ ។ សូមមើលកិច្ចសម្ភាសន៍ជាមួយលោក ឡាលាណាត់ ដេ ស៊ីលវា ចុះផ្សាយនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១០ មានចំណងជើងថា "ច្បាប់សេរីភាពខាងព័ត៌មានត្រូវបានរាលដាលពេញពិភពលោក" ដែលអាចរកមើលលើគេហទំព័រដែលមានអាសយដ្ឋាន ៖www.wri.org/stories/2010/09/freedom-information-laws-spreading-around-world. ភ្ជាប់ទៅកាន់បញ្ញត្តិធម្មនុញ្ញ ច្បាប់ និងបទវិន័យនានាពាក់ព័ន្ធនឹងសេរីភាពខាងព័ត៌មាននៅលើពិភពលោក អាចរកមើលតាមគេហទំព័រព័ត៌មានដើម្បីសិទ្ធិ ដែលមានអាសយដ្ឋាន ៖right2info.org/laws.

*ដឹងឮ ៖ គោលការណ៍បញ្ញត្តិសេរីភាពខាងព័ត៌មាន*”។[8] គោលការណ៍ទាំងនេះចែងពីមាត្រដ្ឋានបទបញ្ញត្តិសេរីភាពព័ត៌មាន ដែលដកស្រង់ចេញពីច្បាប់នានានៅជុំវិញពិភពលោក ។ គោលបំណងនៃគោលការណ៍សេរីភាពព័ត៌មាននេះ គឺផ្តល់ជាមគ្គុទេសក៏សម្រាប់វឌ្ឍនភាព នៃបញ្ញត្តិសេរីភាពព័ត៌មានដ៏មានប្រសិទ្ធភាព ដល់ប្រទេសដែលពិចារណាក្នុងការអនុវត្តច្បាប់នេះ ។

មានគោលការណ៍សេរីភាពខាងព័ត៌មាន ចំនួន៩ (សូមមើលការបរិយាយក្នុងប្រអប់) ។ គោលការណ៍ទីមួយ គឺថា បញ្ញត្តិសេរីភាពខាងព័ត៌មានគួរត្រូវបានអនុលោមតាមគោលការណ៍ដែលបើកចំហជាអតិបរមា ពោលគឺថា ស្ថាប័នសាធារណៈ មានកាតព្វកិច្ចបើកបង្ហាញព័ត៌មាន ហើយប្រជាពលរដ្ឋមានសិទ្ធិក្នុងទទួលបានព័ត៌មាន ។ រាល់ការបដិសេធផ្តល់ព័ត៌មាន ត្រូវតែផ្អែកលើមូលដ្ឋានហានិភ័យពិតប្រាកដ ដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ជាកត់សម្គាល់ ដល់ផល ប្រយោជន៍ដែលត្រូវបានការពារស្របច្បាប់ ដូចជា ការពង្រឹងការអនុវត្តច្បាប់ ឯកជនភាព សន្តិសុខជាតិ ភាពសម្ងាត់ខាងពាណិជ្ជកម្ម សុវត្ថិភាពសាធារណៈនិងបុគ្គល និងប្រសិទ្ធភាពនិងសុចរិតភាព ក្នុងដំណើរការសម្រេចចិត្តរបស់រដ្ឋាភិបាល ជាដើម ។ រាល់ការមិនបង្ហាញព័ត៌មាន ដែលអាចចាត់ទុកថាស្របច្បាប់បាន លុះណាផលប៉ះពាល់ទាំងស្រុង ក្នុងការបង្ហាញព័ត៌មាននោះ បណ្តាលឲ្យមានគ្រោះថ្នាក់ដល់ផលប្រយោជន៍ដែលត្រូវបានការពារស្របច្បាប់ ។[9] បើទោះបីជាក្នុងករណី ដែលហានិភ័យនោះពិតជាកើតឡើងមែន ព័ត៌មាននោះគួរត្រូវបានបើកចំហ ក្នុងលក្ខខណ្ឌដែលផលប្រយោជន៍ នៃការបើកចំហព័ត៌មាននិងផលប្រយោជន៍សាធារណៈមានទម្ងន់ជាងផលគ្រោះថ្នាក់ ។ ឧទាហរណ៍ មានអំណះអំណាង ក្នុងគោលការណ៍សេរីភាពព័ត៌មានថា “ការលាត ត្រដាង ពីអំពើពុករលួយ ក្នុងជួរយោធា អាចត្រូវបានមើលឃើញដំបូង ថានឹងធ្វើឲ្យចុះខ្សោយផ្នែកការពារជាតិ ប៉ុន្តែជាការពិត ជានិច្ចកាលការលាតត្រដាងនេះ បានជួយកាត់បន្ថយអំពើពុករលួយ និងបានជួយពង្រឹងកងកម្លាំងប្រដាប់អាវុធថែមទៀត” ។[10] រាល់ការបដិសេធពីសំណាក់អាជ្ញាធរសាធារណៈ ក្នុងការបើកបង្ហាញព័ត៌មានគួរអាចត្រូវបានតវ៉ាដល់ស្ថាប័នរដ្ឋបាលឯករាជ្យមួយ ដែលមានអំណាចគ្រប់គ្រាន់ក្នុងការលើកស្ទួយការអនុលោមតាមច្បាប់ដ៏មានប្រសិទ្ធភាពមួយ និងជាពិសេស គឺតាមរយៈស្ថាប័នតុលាការ (គោល-ការណ៍៥) ។[11]

គោលការណ៍សេរីភាពខាងព័ត៌មានចំនួនពីរ ចង្អុលបង្ហាញពីកាតព្វកិច្ចវិជ្ជមានរបស់អាជ្ញាធរសាធារណៈ ៖ (ក)ឲ្យផ្សព្វផ្សាយជាស្វ័យប្រវត្តិនូវរាល់ឯកសារជាក់លាក់នានា ដូចជាព័ត៌មានជុំវិញការប្រព្រឹត្តិទៅ និងការសម្រេចចិត្តរបស់ស្ថាប័នរដ្ឋាភិបាល បើទោះបីជាគ្មានសំណើសុំឲ្យដាក់ផ្សាយយ៉ាងក៏ដោយ និង(ខ)លើកស្ទួយជាសកម្មឲ្យមានរដ្ឋាភិបាលបើកចំហមួយ តាមរយៈការធានាថា

---

[8] អង្គការមាត្រា១៩ ចុះផ្សាយខែកក្កដា ឆ្នាំ១៩៩៩ មានចំណងជើងថា “សិទ្ធិរបស់សាធារណជន ក្នុងការដឹងឮ ៖ គោលការណ៍បញ្ញត្តិសេរីភាពខាងព័ត៌មាន” ដែលអាចរកមើលលើគេហទំព័រដែលមានអាសយដ្ឋាន ៖ www.article19.org/pdfs/standards/righttoknow.pdf.

[9] ដូចខាងលើ ទំព័រ៦

[10] ដូចក្នុងលេខយោង១២ ទំព័រ៦

[11] ដូចខាងលើ ទំព័រ៧

សាធារណជន យល់អំពីសិទ្ធិរបស់ខ្លួនក្នុងការទទួលបានព័ត៌មាន ហើយមន្ត្រីសាធារណៈដឹងអំពីតម្រូវការក្នុងការបង្ហាញព័ត៌មាន ។

គោលការណ៍មួយចំនួន ពាក់ព័ន្ធនឹងសំណើក្នុងការទទួលបាន ដំណាក់កាលស្នើសុំ និងសោហ៊ុយចំណាយនានាដើម្បីទទួលព័ត៌មាន ។ គោលការណ៍ដទៃទៀត តម្រូវឲ្យរដ្ឋាភិបាលបើកកិច្ចប្រជុំជាចំហ ក្នុងគោលបំណងបង្កើតឲ្យមានការសន្មត់មួយ ដែលថារាល់កិច្ចប្រជុំនានារបស់ស្ថាប័នរដ្ឋាភិបាលត្រូវតែបើកចំហ ដែលនេះគឺជាផ្នែកមួយនៃសិទ្ធិរបស់សាធារណជន ក្នុងការដឹងឮអំពីការប្រព្រឹត្តិទៅរបស់រដ្ឋាភិបាលដែលធ្វើការក្នុងនាមពលរដ្ឋ ។ មានគោលការណ៍មួយចំនួនទៀតផ្តោតលើកិច្ចការពារអ្នកផ្តល់ព័ត៌មាន និងទំនាក់ទំនងរវាងច្បាប់សេរីភាពព័ត៌មាន និងបញ្ញត្តិរក្សាការសម្ងាត់ ។

វិសាលភាពដែលបញ្ញត្តិច្បាប់ និងការអនុវត្តជាក់ស្តែង នៅប្រទេសកម្ពុជា បំពេញគោលការណ៍សេរីភាពខាងព័ត៌មាននេះ នឹងត្រូវបានត្រួតពិនិត្យជាលម្អិត ក្នុងជំពូក៤ ដល់ជំពូក៧ ។

## ២.២ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

ដូចមានចែង ក្នុងលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិ សេរីភាពព័ត៌មានគឺត្រូវបានការពារនៅ ក្នុងផ្នែកមួយ នៃសិទ្ធិសេរីភាពបញ្ចេញមតិ ។ មាត្រា១៩ នៃសេចក្តីប្រកាសជាសកល ស្តីអំពីសិទ្ធិមនុស្សបានចែងថា ៖ *"ជនគ្រប់រូបមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ។ សិទ្ធិនេះរាប់បញ្ចូលសេរីភាពក្នុងការ [...] រាវរក ការទទួលបាន និងការផ្សព្វផ្សាយនូវព័ត៌មាន"* ។ មាត្រា១៩ នៃសេចក្តីប្រកាសជាសកលនេះ ជាកញ្ចក់ឆ្លុះបញ្ចាំង ដូចនឹងមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) ដែលបានចែងថា ៖ *"ជនគ្រប់រូបមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពក្នុងការរាវរក ការទទួលបាន និងការផ្សព្វផ្សាយ*

> *" [សេរីភាពខាងព័ត៌មាន] ច្បាប់សេរីភាពខាងព័ត៌មាន គឺជាឧបករណ៍មួយក្នុងការជំនះឲ្យបាននូវការផ្លាស់ប្តូរជាវិជ្ជមានផ្នែកសង្គម នយោបាយ និងសេដ្ឋកិច្ច ។ ច្បាប់សេរីភាពខាងព័ត៌មាននេះ អាចជួយឲ្យពលរដ្ឋ និងស្ថាប័នមានគណនេយ្យភាព ជួយសម្របសម្រួលឲ្យមានការចូលរួមពីសាធារណជនក្នុងការតាក់តែងនិងអនុវត្តគោលនយោបាយនានា ជួយកាត់បន្ថយនូវការរាំងស្ទះឲ្យមានការផ្លាស់ប្តូរមួយតាមរយៈការចូលរួមវិភាគទានឲ្យមានកិច្ចសន្ទនាដែលត្រូវបានដឹងឮជាងមុនរវាងអ្នកគាំទ្រអំពីបញ្ហានានា និងជួយបង្កលក្ខណខ័ណ្ឌដែលជម្រុញឲ្យមានវិនិយោគទុនមួយ ។"*
>
> អានគ្រ្លូ អ៊ីលេស្លូន ខែកញ្ញាឆ្នាំ២០០៨ "សំណើយុទ្ធសាស្ត្រដើម្បីសេរីភាពខាងព័ត៌មាននៅកម្ពុជា" ទំព័រទី៥

*ព័ត៌មាននិងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែនកំណត់ ឬមួយដោយផ្ទាល់មាត់ ដោយសំណេរ ឬបោះពុម្ព ក្រោមទម្រង់សិល្បៈក្ដីឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្ដី តាមការជ្រើសរើសរបស់ខ្លួន"*។

ការិយាល័យរបស់អ្នករាយការណ៍ពិសេសស្ដីពីសេរីភាពបញ្ចេញមតិ បានសម្ដែងការទទួលស្គាល់ សិទ្ធិសេរីភាពខាងព័ត៌មាន ថាជាបំណែកសំខាន់មួយនៃមាត្រា១៩ នៃ ក.អ.ស.ព.ន ។ ក្នុងរបាយការណ៍ប្រចាំឆ្នាំ១៩៩៩ របស់អ្នករាយការណ៍ពិសេស រាយការណ៍ជូនទៅឧត្ដមស្នងការអង្គការសហប្រជាជាតិស្ដីពីសិទ្ធិមនុស្ស និងសេរីភាពបញ្ចេញមតិ អតីតអ្នករាយការណ៍ពិសេស គឺលោកអាប៊ីដ ហ៊ូសាន បានធ្វើការកត់សម្គាល់ថា *"ជនគ្រប់រូបមានសិទ្ធិក្នុងការរាវរក ការទទួលបាន និងការផ្សព្វផ្សាយព័ត៌មាន ហើយនេះគឺជាកាតព្វកិច្ចវិជ្ជមានរបស់រដ្ឋនិមួយៗ ក្នុងការធានានូវលទ្ធភាពទទួលបានព័ត៌មាន ជាពិសេសព័ត៌មានដែលគ្រប់គ្រងដោយរដ្ឋាភិបាល ក្រោមទម្រង់គ្រប់ប្រភេទ ដោយរួមទាំងឯកសារភាពយន្ត ឯកសាររូបភាពខ្នាតតូច ឯកសារអេឡិចត្រូនិច វីដេអូ និងរូបភាពនានា ដែលនេះនឹងអាចត្រូវរឹតបន្តឹងបានដរាបណាដូចបានយោងក្នុងមាត្រា១៩ កថាខ័ណ្ឌ៣ នៃ ក.អ.ស.ព.ន " ។*[12] បន្ថែមលើសនេះទៀត សេចក្ដីអត្ថាធិប្បាយទូទៅដែលបានកែប្រែជាថ្មីស្ដីពីសេរីភាពបញ្ចេញមតិ ក្នុងមាត្រា១៩ ដែលបានបោះពុម្ពផ្សាយដោយគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ កាលពីខែកក្កដា ឆ្នាំ២០១១ សំដៅលើ *"សិទ្ធិក្នុងការទទួលបានព័ត៌មានដែលគ្រប់គ្រងដោយអង្គភាពរដ្ឋ"* ។[13] សេចក្ដីអធិប្បាយនេះ បានបន្តថ្លែងថា ព័ត៌មាន *"រាប់បញ្ចូលទាំងព័ត៌មានដែលគ្រប់គ្រងដោយស្ថាប័នរដ្ឋ ដោយមិនគិតពីទម្រង់ដែលព័ត៌មានទាំងនោះត្រូវបានរក្សាទុក ប្រភពព័ត៌មាន និងកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយនោះឡើយ"* ហើយរាប់បញ្ចូលទាំង *"មែកធាងទាំងអស់របស់រដ្ឋ (រួមមានអង្គនិតិប្រតិបត្តិ អង្គនិតិបញ្ញត្តិ និងតុលាការ) ព្រមទាំងអាជ្ញាធរសាធារណៈ ឬរដ្ឋាភិបាលដទៃទៀត នៅគ្រប់កម្រិតទាំងអស់ រួមទាំងកម្រិតជាតិ តំបន់ និងមូលដ្ឋាន"* ហើយក៏អាចបញ្ចូល *"ទាំងស្ថាប័នទាំងឡាយណា ដែលមានតួនាទីសាធារណៈ"*[14]។

សិទ្ធិសេរីភាពខាងព័ត៌មាន ដូចនឹងសិទ្ធិមនុស្សឯទៀតដែរ គឺមិនមានលក្ខណៈដាច់ខាតនោះទេ ។ ទោះជាយ៉ាងនេះក្ដី រាល់ការរឹតបន្តឹងនានាលើសិទ្ធិនេះ ចាំបាច់ត្រូវបំពេញតាមលក្ខណខណ្ឌជាក់លាក់ ដូចមានចែងក្នុងមាត្រា១៩(៣) នៃក.អ.ស.ព.ន[15] ។ អ្នកជំនាញជាច្រើនបានអះអាងថា

---

[12] គណៈកម្មការសិទ្ធិមនុស្ស សម័យប្រជុំលើកទី៥៥ មានចំណងជើងថា "របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្ដីពីការលើកកម្ពស់ និងការការពារសេរីភាពខាងគំនិត និងខាងការបញ្ចេញមតិ" ឯកសាររបស់អង្គការសហប្រជាជាតិ E/CN.4/1999/64/32, កថាខ័ណ្ឌទី១២ ចុះផ្សាយថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩ ។

[13] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ចុះផ្សាយថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ មានចំណងជើងថា "សេចក្ដីអធិប្បាយទូទៅ លេខ៣៤ មាត្រា១៩" CCPR/C/GC/34, កថាខ័ណ្ឌទី១៨ ។

[14] ដូចខាងលើ

[15] មាត្រា ១៩(៣) របស់ ក.អ.ស.ព.ន ផ្ដល់ករណីលើកលែងដែលបានផ្ដល់ឲ្យដោយច្បាប់ និងចាំបាច់សម្រាប់ការគោរពសិទ្ធិ និងកេរ្តិ៍ឈ្មោះអ្នកដទៃ ឬដើម្បីការពារសន្តិសុខជាតិ សណ្ដាប់ធ្នាប់សង្គម សុខភាពសាធារណៈ និងសីលធម៌។

លក្ខខណ្ឌទាំងនេះអាចត្រូវអនុវត្តបាន លុះណាអាចឆ្លងកាត់នូវការសាកល្បងបីដំណាក់កាល ដែលបានកំណត់ពីកាលៈទេសៈកម្រិតមួយ ដែលព័ត៌មានអាចត្រូវបានបិទមិនផ្សាយ ស្រដៀងនឹងគោលបំណងនៃគោលការណ៍សេរីភាពខាងព័ត៌មាន ដូចបានពិភាក្សាខាងលើ[16] ៖ (ក) ព័ត៌មាននោះ គឺសមាមាត្រនឹងផលប្រយោជន៍ដែលត្រូវបានការពារស្របច្បាប់ ដូចមានចែងក្នុងច្បាប់សេរីភាពខាងព័ត៌មាន (ខ) ការបង្ហាញព័ត៌មាននោះនឹងអាចគំរាមកំហែងបណ្តាលឲ្យមានគ្រោះថ្នាក់ ហើយដែល (គ) គ្រោះថ្នាក់នោះ គឺមានទម្ងន់ជាងផលប្រយោជន៍សាធារណៈ ដោយហេតុនៃការបង្ហាញព័ត៌មាននោះ ។ ការសាកល្បងបីដំណាក់កាលនេះ អាចត្រូវបានអនុវត្តតាមរយៈតុលាការ និង/ឬ ស្ថាប័នរដ្ឋាភិបាល ដែលមានអាណត្តិក្នុងការពិចារណាលើការបដិសេធរបស់ស្ថាប័នរដ្ឋាភិបាល ក្នុងការផ្សាយព័ត៌មានជាក់លាក់ណាមួយទៅសាធារណៈ ។ បើយោងតាមអ្នកឯកទេសសេរីភាពខាងព័ត៌មាន លោក វ៉ៃម៉ុន លីអូ បានបញ្ជាក់ថា គោលបំណងនៃការដាក់ឲ្យមានការសាកល្បងបីដំណាក់កាលនោះ គឺដើម្បី "*ធានាថារាល់ការរក្សាទុកព័ត៌មានរបស់រដ្ឋាភិបាល គឺអាចធ្វើបានសម្រាប់តែករណីដើម្បីការពារផលប្រយោជន៍សាធារណៈទាំងមូល ។ ការអនុវត្តត្រឹមត្រូវមួយតាមការសាកល្បងនេះនឹងអាចជួយទប់ស្កាត់ការដកហូតសិទ្ធិនិងករណីលើកលែងដែលមិនសមស្របមួយ ជួយលុបបំបាត់បញ្ញត្តិដែលការពារស្ថាប័នរដ្ឋាភិបាលពីការរិះគន់ពីសាធារណជនឬអាម៉ាស់ ជួយការពារគេទល់នឹងកំហុសឆ្គងរបស់រដ្ឋាភិបាល និងទប់ស្កាត់ការលាក់បាំងព័ត៌មាន ដែលអាចមានគ្រោះថ្នាក់ដល់គោលនយោបាយរបស់រដ្ឋាភិបាលដែលមានស្រាប់ ឬមនោគមនយោបាយណាមួយ ។*"[17]

## ២.៣ ច្បាប់ជាតិដែលមានស្រាប់

សម្រាប់ប្រទេសកម្ពុជា មិនមានច្បាប់ជាក់លាក់ស្តីពីសេរីភាពខាងព័ត៌មាន ត្រូវបានអនុម័តនៅឡើយទេ តែមានច្បាប់ដទៃទៀត បានធានាដល់សិទ្ធិសេរីភាពខាងព័ត៌មាន និងមានបញ្ចូលបញ្ញត្តិទាក់ទងនឹងសេរីភាពខាងព័ត៌មានថែមទៀត ។ ច្បាប់សំខាន់ៗទាំងនេះនឹងត្រូវបានពិភាក្សាដូចខាងក្រោម ។

### (ក) រដ្ឋធម្មនុញ្ញ

បើទោះបីជាមិនមានបញ្ញត្តិជាក់លាក់ ដើម្បីការពារដល់សេរីភាពខាងព័ត៌មាន ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (តទៅហៅថា "រដ្ឋធម្មនុញ្ញ") យ៉ាងណាក៏ដោយ ក៏រដ្ឋធម្មនុញ្ញបានការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ដូចមានចែងក្នុងមាត្រា៤១ ។ សិទ្ធិសេរីភាពខាងព័ត៌មាន អាចត្រូវបានចាត់ទុកជាឈ្នាន់ សម្រាប់ធានាដល់សេរីភាព ក្នុងការបញ្ចេញមតិ ដោយហេតុថា ដើម្បីបង្កើត ឬសម្តែងនូវមតិយោបល់ដ៏មានអត្ថន័យ គឺពិតជាលំបាក ប្រសិនបើគ្មានលទ្ធភាពទទួលបានព័ត៌មាន

[16] វ៉ៃម៉ុន លីអូ ចុះផ្សាយថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ មានចំណងជើងថា "សិទ្ធិទទួលបានព័ត៌មាននៅតំបន់អាស៊ីអាគ្នេយ៍ និងកម្ពុជា" ទំព័រ៦ ដែលអាចរកមើលបានលើគេហទំព័រមានអាសយដ្ឋាន ៖ www.cchrcambodia.org/admin/media/report/report/english/2009-01-08-%20Access%20to%20Information%20in%20Southeast%20Asia%20and%20Cambodia-%20EN.pdf.

[17] ដូចខាងលើ។

ត្រឹមត្រូវ និងពេញលេញនោះទេ ។រដ្ឋធម្មនុញ្ញ ក៏បានធានាដល់សិទ្ធិពលរដ្ឋគ្រប់រូបក្នុងការ *"ចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។*[18] ដើម្បីអាចឲ្យសិទ្ធិនេះ អាចសម្រេចបានពេញលេញ ចាំបាច់ត្រូវមានលទ្ធភាព ដោយសេរី ក្នុងការទទួលបានព័ត៌មាន ដោយ ហេតុថាបើគ្មានព័ត៌មានទេនោះ អត្ថន័យនៃការចូលរួម យ៉ាងសកម្មគឺគ្មានប្រយោជន៍ ទាល់តែសោះ។

ជាងនេះទៅទៀត មាត្រា៣១ នៃរដ្ឋធម្មនុញ្ញ បានសច្ចាទទួលស្គាល់ និង គោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្តី ប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុញ្ញាទាំងឡាយ ទាក់ទងនឹងសិទ្ធិមនុស្ស។ កម្ពុជាចុះសច្ចាប័ន ទទួលស្គាល់ ក.អ.ស.ព.ន ក្នុងឆ្នាំ១៩៩២ ដោយហេតុនេះកម្ពុជាមានកាតព្វកិច្ចគោរព ការពារ និងអនុលោមតាមបទបញ្ញត្តិរបស់កតិកាសញ្ញានេះ រួមទាំងបទបញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធ នឹងមាត្រា១៩ ផងដែរ ។ ដោយហេតុនេះហើយ បញ្ញត្តិក្នុង ក.អ.ស.ព.ន និងសេចក្តីថ្លែងការណ៍ ជាសកលពោលគឺមាត្រា១៩ ក្នុងបញ្ញត្តិទាំងពីរនេះ ដែលធានាដល់សិទ្ធិទទួលបានព័ត៌មាន គឺត្រូវបានចងក្រងជាផ្នែកមួយនៃច្បាប់ជាតិ។[19]

**រដ្ឋធម្មនុញ្ញកម្ពុជា**

**មាត្រា៣១ ៖** *"ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងកុមារ "។*

**មាត្រា៤១ ៖** *"ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ "។*

## (ខ) ច្បាប់ស្តីពីបណ្ណសារ ឆ្នាំ ២០០៥

ច្បាប់ស្តីពីបណ្ណសារ មានគោលបំណងកំណត់ការគ្រប់គ្រង និងការថែរក្សាព័ត៌មានដែល ផ្ទុកក្នុងបណ្ណសាររដ្ឋានរដ្ឋាភិបាល ។ បណ្ណសារនេះអនុញ្ញាតឲ្យសាធារណជនអាចរកមើល *"ឯកសារផ្សព្វផ្សាយ"* ដែលមិនប៉ះពាល់ដល់សន្តិសុខជាតិ ដើម្បីស្រាវជ្រាវ និងពិគ្រោះដើម្បីជាព័ត៌មាន *ដោយគ្មានការហាមឃាត់"* ។[20] ទោះជាយ៉ាងនេះក្តី ច្បាប់នេះមិនបានកំណត់ពីប្រភេទព័ត៌មានដែល

---

[18] មាត្រា៣៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ។

[19] ក្នុងសេចក្តីសម្រេចរបស់ ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ បានបញ្ជាក់បន្ថែមថាលិខិតុបករណ៍សិទ្ធិមនុស្សទាំងអស់ដែលកម្ពុជាទទួលស្គាល់នឹងត្រូវបញ្ចូលជាផ្នែកមួយនៃរដ្ឋធម្មនុញ្ញ ។ សូមអានសេចក្តីសម្រេចលេខ ០៩២/ ០០៣/២០០៧ ។

[20] មាត្រា១៣ នៃច្បាប់បណ្ណសារ ឆ្នាំ២០០៥

ជា *"ឯកសារផ្សព្វផ្សាយ"* ហើយឯកសារដែលមិន *"ផ្សព្វផ្សាយ"* គឺមិនអាចអនុញ្ញាតឲ្យចូលស្រាវជ្រាវបានរហូតក្រោយ រយៈពេល យ៉ាងតិច២០ឆ្នាំ គិតចាប់តាំងពីកាលបរិច្ឆេទនៃឯកសារ ឬ គិតចាប់ពីថ្ងៃបញ្ចប់សំណុំរឿង ។ ឯកសារជាក់លាក់ ត្រូវបានរក្សាទុកជាសម្ងាត់ក្នុងអំឡុងពេលដ៏ យូរអង្វែងមួយ ដើម្បីការពារសន្តិសុខជាតិ ឬការពារអធិបតេយ្យភាពជាតិ និងសិទ្ធិបុគ្គល ។[21] ទោសពិន័យសម្រាប់បទរំលោភច្បាប់បណ្ណសារ ដោយធ្វើឲ្យធ្លាយឯកសារជាសាធារណៈ នឹងត្រូវពិន័យយ៉ាងធ្ងន់ធ្ងរ ៖ ជាទឹកប្រាក់ ចាប់ពី ចន្លោះ ១.២៥០ដុល្លាសហរដ្ឋអាមេរិក និង៦.២៥០ដុល្លារសហរដ្ឋ-អាមេរិក ព្រមទាំងផ្តន្ទា ទោសដាក់ពន្ធនាគារពី ៧ ឆ្នាំ ទៅ ១៥ ឆ្នាំ ។

## (គ) ច្បាប់របបសារព័ត៌មាន ឆ្នាំ១៩៩៥

មាត្រា៥ នៃច្បាប់របបសារព័ត៌មាន ត្រូវបានគេយល់ឃើញថា ប្រទេសកម្ពុជាខិតទៅជិតប្រទេសដែលមានច្បាប់ធានាដល់ការទទួលបានព័ត៌មាន ដោយសារថា ប្រទេសនេះ បានទទួលស្គាល់សិទ្ធិរបស់សារព័ត៌មាន ក្នុងការ *"ទទួលព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិ-បាល"*។[22] មាត្រា៥ បានចែងថា ដើម្បីអាចទទួលព័ត៌មានបាន ត្រូវមានសំណើជាលាយលក្ខណ៍អក្សរ ហើយត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ អំពីព័ត៌មានដែលត្រូវស្នើសុំទៅស្ថាប័នពាក់ព័ន្ធ ។ មន្ត្រីមានសមត្ថកិច្ចត្រូវឆ្លើយតបនឹងសំណើនោះ ក្នុងរយៈពេល ៣០ ថ្ងៃ ។ បន្ថែមលើសនេះទៀតនោះ ច្បាប់នេះ ក៏បានចែងអំពីលទ្ធភាពដែលសិទ្ធិទទួលបានព័ត៌មាននេះ អាចត្រូវបានបដិសេធ ក្នុងករណីដែលការបង្ហាញព័ត៌មាននេះ នឹងបណ្តាលឲ្យ ៖ (ក) អន្តរាយដល់សន្តិសុខជាតិ និង/ឬ អន្ត-រាយដល់ទំនាក់ទំនងជាមួយប្រទេសដទៃ (ខ) មានការបំពានលើសិទ្ធិរបស់បុគ្គលម្នាក់ៗ (គ) មានការលាតត្រដាងឯកសារសម្ងាត់ផ្នែកពាណិជកម្ម និងផ្នែកហិរញ្ញវត្ថុ (ឃ) ប៉ះពាល់ដល់សិទ្ធិជនណាម្នាក់ ក្នុងការនាំឲ្យមានការជំនុំជម្រះដោយយុត្តិធម៌ (ង) មានគ្រោះថ្នាក់ដល់មន្ត្រីដែលត្រូវអនុវត្តច្បាប់។

អ្វីដែលសំខាន់ជាងនេះនោះគឺ ច្បាប់នេះមានវិសាលភាពតែលើសមាជិកអ្នកសារព័ត៌មានតែប៉ុណ្ណោះ ដោយហេតុនេះហើយ ពលរដ្ឋសាមញ្ញមិនអាចសំអាងលើច្បាប់នេះ ដើម្បីអាចទទួលបានព័ត៌មានដែលស្ថិតក្នុងការគ្រប់គ្រងរបស់រដ្ឋាភិបាលបានឡើយ ។ ការណ៍ដែលសិទ្ធិនេះបានផ្តល់ដល់អ្នកសារព័ត៌មាននោះ ហាក់មិនមានហេតុផលខាងច្បាប់ណាមួយបានបកស្រាយចំពោះការណ៍ដែលសិទ្ធិនេះមិនបានផ្តល់ជូនពលរដ្ឋសាមញ្ញនោះឡើយ ។

បើទោះបីជាច្បាប់របបសារព័ត៌មាន អនុញ្ញាតឲ្យសមាជិកសារព័ត៌មានអាចទទួលបានព័ត៌មានក៏ដោយ បទពិសោធន៍របស់សមាជិកអ្នកសារព័ត៌មានមួយចំនួនដែល ម.ស.ម.ក បានជួបសម្ភាសជាមួយនោះ ដូចបានពិភាក្សាក្នុងជំពូក៥ បង្ហាញថាកម្រិតនៃលទ្ធភាពដែលបានផ្តល់ចំពោះសំណើ អ្នកទាំងនោះមិនស៊ីសង្វាក់គ្នាឡើយ ។ បន្ថែមលើសនេះទៀតនោះ ច្បាប់នេះមិនមានចែង

[21] មាត្រា១៩ នៃច្បាប់បណ្ណសារ ឆ្នាំ២០០៥

[22] រ៉ៃម៉ុន លីអូ សូមមើលលេខយោងលេខ២០ ទំព័រ ៦។

អំពីសិទ្ធិ ក្នុងការប្តឹងតវ៉ា ក្នុងករណីសំណើនោះត្រូវបានបដិសេធនោះទេ ហើយគ្មានបញ្ញត្តិណាចែងពីស្ថាប័ន ឯករាជ្យណាមួយក្នុងការឃ្លាំមើលសំណើទាំងនោះ ព្រមទាំងការឆ្លើយតបរបស់រដ្ឋាភិបាលទេ ។ ប្រសិនបើគ្មានសិទ្ធិក្នុងការប្តឹងតវ៉ាទេ នោះនឹងអនុញ្ញាតឲ្យមានហេតុផលច្រើនលើសលុប ឬដោយបំពានក្នុងការបដិសេធការផ្តល់សិទ្ធិទទួលបានព័ត៌មានដូចចែងក្នុងមាត្រា៥ ។

## ២.៤ គំនិតផ្តួចផ្តើមវិមជ្ឈការ និងវិសហមជ្ឈការ

រដ្ឋាភិបាលបានកំពុងព្យាយាមអនុវត្តគោលការណ៍ "វិមជ្ឈការ និងវិសហមជ្ឈការ" ចាប់តាំងពីឆ្នាំ២០០១មកម្លេះ។[23] គោលបំណងស្នូលនៃគោលការណ៍នេះគឺដើម្បីផ្ទេរ និងកាត់បន្ថយ ឬផ្ទេរអំណាចក្នុងការសម្រេចចិត្ត ទៅអាជ្ញាធរមូលដ្ឋាន ។ គោលការណ៍នេះ តំណាងជំហានវិជ្ជមានមួយឆ្ពោះទៅកាន់លទ្ធភាពទទួលបានព័ត៌មាននៅថ្នាក់មូលដ្ឋាន និងការគ្រប់គ្រងជាច្រើន ដល់ស្ថាប័ននៅថ្នាក់ក្រោម និងដើម្បីបង្កើនការចូលរួមរបស់សាធារណជនក្នុងការសម្រេចចិត្ត ដែលអាចប៉ះពាល់ដល់ពួកគាត់ ។ ច្បាប់នានាដែលគ្រប់គ្រងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ មានដូចជា *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំសង្កាត់ ឆ្នាំ២០០១* ដែលទទួលស្គាល់ឃុំ និងសង្កាត់ជានីតិបុគ្គល ដែលមានអំណាចទាំងនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ក្នុងការតាក់តែងអភិវឌ្ឍផែនការក្នុងឃុំសង្កាត់របស់ពួកគាត់ និងគ្រប់គ្រងគម្រោងថ្នាក់មូលដ្ឋាន និង*ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨* (ច្បាប់អង្គការ) ដែលជាទូទៅត្រូវបានស្គាល់ ថា

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨**

**មាត្រា៩១ ៖** ក្រុមប្រឹក្សាត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវផែនការអភិវឌ្ឍន៍បន្ទាប់ពីបានអនុម័តរួចហើយភ្លាម ។ សាធារណជនអាចពិនិត្យឯកសារផែនការនេះ នៅការិយាល័យ របស់ក្រុមប្រឹក្សាដោយឥតគិតថ្លៃ ឬអាចស្នើសុំជាវឯកសារផែនការនេះពីក្រុមប្រឹក្សា ដោយគិតត្រឹមតម្លៃដើម។

**មាត្រា៥២ ៖** ក្រុមប្រឹក្សានិមួយៗត្រូវមានក្តារព័ត៌មាន ជាសាធារណៈ ឬតាមមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងទៀតនៅការិយាល័យកណ្តាលរបស់ខ្លួន និងនៅតាមកន្លែងនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមការចាំបាច់ ហើយទីកន្លែងទាំងនោះ មានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋទទួលបានព័ត៌មានជាសាធារណៈទាំងនោះ ។

**មាត្រា១៦៩ ៖** គណៈអភិបាលត្រូវធានាឲ្យមានក្តារបិទផ្សាយព័ត៌មាន និងមធ្យោបាយផ្សព្វផ្សាយផ្សេងៗទៀត តាមតម្រូវការរបស់ក្រុមប្រឹក្សារបស់ខ្លួន ។ រាល់ឯកសារទាំងអស់ដែលបានបោះពុម្ពផ្សាយ ស្របតាមច្បាប់នេះ ត្រូវតែបិទផ្សាយនៅលើក្តារព័ត៌មាន ឬត្រូវផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗទៀតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ។

[23] គោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការបានចាប់ផ្តើមដោយមានការអនុម័តច្បាប់ស្តីពីការបោះឆ្នោតឃុំសង្កាត់២០០១ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ឆ្នាំ២០០១ ។

ជាច្បាប់ អង្គការ និងចែងពីការបង្កើតឃុំដែលបោះឆ្នោតឡើងសម្រាប់ផ្នែករដ្ឋបាលនីមួយៗ ឲ្យមានគណនេយ្យភាព ចំពោះពលរដ្ឋថ្នាក់មូលដ្ឋានរបស់ខ្លួនផ្ទាល់ ។

**វិមជ្ឈការ** ៖ ការផ្ទេរអំណាចពីរដ្ឋាភិបាលកណ្តាលទៅអ្នកតំណាងនៅថ្នាក់ក្រោម ជាឧទាហរណ៍ អភិបាលខេត្ត ជាដើម ។
**វិសហមជ្ឈការ** ៖ ការផ្ទេរអំណាចគ្រប់គ្រងរដ្ឋបាលរបស់ស្ថាប័នជាតិ ទៅអាជ្ញាធរថ្នាក់មូលដ្ឋានដែលត្រូវបានគេជ្រើសតាំងតាមការបោះឆ្នោត ។

ច្បាប់ទាំងពីរនេះមានផ្ទុកនូវបញ្ញត្តិសំខាន់ៗ ដែលមានគោលបំណងធានា នូវសេរីភាពខាងព័ត៌មាន ។ ជាឧទាហរណ៍ *ច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលឃុំសង្កាត់* ចែងថារាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែធ្វើឡើងជាសាធារណៈ (មាត្រា ២៣) ហើយរាល់ការសម្រេចចិត្ត ត្រូវធ្វើការផ្សព្វផ្សាយដល់សាធារណជន ឲ្យបានដឹង ភ្លាមៗ (មាត្រា ៤៨) ។ ស្រដៀងគ្នានេះដែរ មាត្រា ៦៨នៃ *ច្បាប់អង្គការ* បានចែងថារាល់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាត្រូវតែរៀបចំ ធ្វើឡើងជាសាធារណៈ ហើយក្នុងមាត្រា៥១បានចែងថា ក្រុមប្រឹក្សាត្រូវតែបង្កលក្ខណៈងាយស្រួលដល់សាធារណជន ក្នុងការជូនព័ត៌មានជាសាធារណៈ អំពីរបាយការណ៍ របៀបវីរៈអង្គប្រជុំ កំណត់ហេតុប្រជុំច្បាប់ ។ល។

ក្តារព័ត៌មានត្រូវបានរៀបរាប់ ក្នុងមាត្រាជាច្រើន នៃច្បាប់អង្គការ ដើម្បីជាមធ្យោបាយផ្សព្វផ្សាយព័ត៌មានដល់សាធារណជន (សូមមើលក្នុងប្រអប់) ។ ទាំងនេះគឺជាមធ្យោបាយដ៏ល្អមួយ ដើម្បីបង្កើនកម្រិតយល់ដឹងដល់សាធារណជនអំពីសកម្មភាពនានារបស់រដ្ឋាភិបាល និងធានាថាអ្នកទាំងឡាយដែលនឹងរងប៉ះពាល់ពីការសម្រេចចិត្តទាំងនោះ ត្រូវបានទទួលព័ត៌មានយ៉ាងជាក់ច្បាស់ ។

បន្ថែមលើសពីនេះ នោះគឺថា តាមរយៈការដាក់អាណត្តិដល់មន្ត្រីមូលដ្ឋានឲ្យប្រឹក្សាយោបល់ជាមួយពលរដ្ឋ និងរាយការណ៍រាល់ការសម្រេចចិត្តជាផ្លូវការនោះ ច្បាប់អង្គការនេះទំនងហាក់បាន លើកកម្ពស់សេរីភាពខាងព័ត៌មានក្នុងប្រទេសនេះ ។

*"ព័ត៌មានគឺជាខ្យល់ដកដង្ហើមនៃលទ្ធិប្រជាធិបតេយ្យ"*
*អង្គការមាត្រា១៩ "សិទ្ធិរបស់សាធារណជនក្នុងការដឹងឮ ៖ គោលការណ៍បញ្ញត្តិសេរីភាពខាងព័ត៌មាន"*
*ចុះផ្សាយខែមិថុនា ឆ្នាំ១៩៩៩ ទំព័រទី១ ។*

ខណៈដែលនេះជាគោលការណ៍វិជ្ជមានមួយនោះ បើយោងតាមរបាយការណ៍ថ្មីមួយ ដែលបោះពុម្ព-ផ្សាយ ដោយធនាគារអភិវឌ្ឍន៍អាស៊ី បានឲ្យដឹងថា មានវិធានការជាច្រើន ដែលបានស្នើឡើងក្នុងឯកសារ បែបផែនយុទ្ធសាស្ត្រឆ្នាំ២០០៥ (ដែលជាមគ្គុទ្ទេស ក៏បង្កើតច្បាប់អង្គការឆ្នាំ២០០៨) និងសេចក្តីព្រាងច្បាប់ចុងក្រោយនៃកម្មវិធីជាតិរយៈពេល

១០ឆ្នាំ (ដែលកំណត់ពីរបៀប ដែលវិមជ្ឈការ និងវិសហមជ្ឈការ នឹងត្រូវបានអនុវត្តនោះ) ដើរថយក្រោយជាងការគ្រោង ទុកជាច្រើនឆ្នាំ ។[24] ម.ស.ម.ក ស្វាគមន៍ចំពោះច្បាប់ទាំងនេះ និងវិសាលភាពព័ត៌មានដែលគួរត្រូវ បានដាក់ជូនដល់សាធារណជនដូចមានចែងក្នុងបញ្ញត្តិជាច្រើននោះ ប៉ុន្តែជាទូទៅ ច្បាប់ល្អៗជា ច្រើនក្នុងប្រទេសកម្ពុជាមិនល្អដូចការយល់ឃើញនោះទេ ដោយ សារការអនុវត្តន៍មិនបានត្រឹមត្រូវ។

## ២.៥ ការវិវឌ្ឍន៍ផ្នែកច្បាប់នៅប្រទេសកម្ពុជា

ចាប់តាំងពីពាក់កណ្តាលទស្សវត្សរ៍៩០ អ្នករាយការណ៍ពិសេស ស្តីពីសេរីភាពខាងបញ្ចេញមតិ បានអំពាវនាវប្រទេសទាំងអស់ឲ្យអនុវត្តច្បាប់សេរីភាពបញ្ចេញមតិ ។[25] សេចក្តីអធិប្បាយទូទៅស្តីពីសេរីភាពបញ្ចេញមតិរបស់គណៈកម្មាធិការសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិក៏បានចែងថា ដើម្បីអាចឲ្យសិទ្ធិទទួលបានព័ត៌មានចូលជាធរមាន រដ្ឋនីមួយៗគួរប្រឹងឲ្យអស់ពីសមត្ថភាពក្នុងការធានាឲ្យបាននូវលទ្ធភាពទទួលបានព័ត៌មាន ដោយងាយស្រួល ទាន់ពេល ប្រសិទ្ធភាព និងជាក់ស្តែង ហើយរដ្ឋគួរតែអនុម័តនីតិវិធីចាំបាច់ ដែលបុគ្គលម្នាក់ៗអាចទទួលបានព័ត៌មាន ដូចជាតាមរយៈបញ្ញត្តិសេរីភាពខាងព័ត៌មានជាដើម ។[26]

នីតិកម្មទាំងនេះមាននៅក្នុងគោលការណ៍ជាតិមួយចំនួនហើយ ប៉ុន្តែមិនមានច្បាប់ណាមួយត្រូវបានប្រកាសឲ្យប្រើជាផ្លូវការនៅឡើយ ។ នៅឆ្នាំ២០០៤ ដោយមានការជំរុញពីប្រទេសជាម្ចាស់ជំនួយ រដ្ឋាភិបាលបានទទួលស្គាល់នូវតម្រូវការច្បាប់សេរីភាពខាងព័ត៌មាន ដើម្បីបង្កើតនូវរដ្ឋាភិ-បាលតម្លាភាព កាត់បន្ថយអំពើពុករលួយ និងបង្កើនភាពទុកចិត្តលើរដ្ឋាភិបាល[27] ហើយបានថ្លែងថាខ្លួននឹងតាក់តែងច្បាប់នេះត្រឹមឆ្នាំ២០០៦ ។ កិច្ចការនេះមិនទាន់ត្រូវបានសម្រេចនៅ ឡើយទេ ហើយជំនួសឲ្យការបង្កើតច្បាប់នេះ ការវិវឌ្ឍន៍ខាងបែបផែនគោលការណ៍ទទួលបានព័ត៌មានត្រូវបានយកចិត្តទុកដាក់ជំនួសវិញ ។

នៅខែកក្កដា ឆ្នាំ២០០៧ បន្ទាប់ពីសិក្ខាសាលា និងសន្និសីទស្តីពីសេរីភាពខាងព័ត៌មានអស់រយៈពេលបីឆ្នាំមក ទីស្តីការគណៈរដ្ឋមន្ត្រី បានផ្តល់អាណត្តិដល់ក្រសួងទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធ-សភា និង អធិការកិច្ច (ក.ទ.រ.ព.អ) ដើម្បីតាក់តែងនូវសេចក្តីព្រាងឯកសារគោលការណ៍មួយ ឡើងជាគោលសម្រាប់ច្បាប់សេរីភាពខាងព័ត៌មាន ។ សេចក្តីព្រាងឯកសារគោលការណ៍ស្តីពីសេរីភាពខាងព័ត៌មាននេះ ត្រូវបានតាក់តែងរួចរាល់នៅចុងខែសីហា ឆ្នាំ២០០៧ ក្រោមជំនួយបច្ចេកទេសពីទី

---

[24] ធនាគារអភិវឌ្ឍន៍អាស៊ី (តារីដ ហេដ ណៃស្ស៊ី) ចុះផ្សាយនៅឆ្នាំ២០១១ មានចំណងជើងថា "កំណែរទម្រង់វិមជ្ឈកាល និងវិសហមជ្ឈកាលនៅកម្ពុជា ៖ អនុសាសន៍សម្រាប់បែបផែនការងារស្ថាប័ន” ទំព័រ៦៧ ។

[25] ដូចខាងលើ ទំព័រ៣ ។

[26] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហហប្រជាជាតិ ដូចលេខយោងលេខ១៨ កថាខ័ណ្ឌ១៨ ។

[27] របាយការណ៍របស់ក.ទ.រ.ព.អ មានចំណងជើងថា “ការទទួលបានព័ត៌មាន៖ បែបផែនការងារគោលការណ៍ច្បាស់លាស់សម្រាប់កម្ពុជា” ចុះផ្សាយថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៧ ទំព័រ៤ ។

ភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (យូសេដ) ។[28] ទោះជាយ៉ាងនេះក្តី ម.ស.ម.ក យល់ឃើញថា ក.ទ.រ.ព.អ មិនទាន់បានបញ្ជូនឯកសារព្រាងនេះទៅកាន់ទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីធ្វើការត្រួតពិនិត្យនៅឡើយទេ ហើយឯកសារនេះក៏មិនដែលត្រូវបានទទួលស្គាល់ជាផ្លូវការថាជាឯកសារគោលផ្លូវការរបស់រដ្ឋាភិបាលនោះដែរ ។[29] មិនមានហេតុផលច្បាស់លាស់ ថាតើហេតុអ្វីបានជាដំណើរការនេះត្រូវបានកកស្ទះបែបនេះឡើយ ។

នៅខែធ្នូ ឆ្នាំ២០១០ សមាជិក៦០នាក់ក្នុងជួររដ្ឋាភិបាលបានចូលរួមក្នុងកិច្ចប្រជុំមួយនៅទីក្រុងភ្នំពេញ ដែលជជែកអំពី "សិទ្ធិទទួលបានព័ត៌មាន និងសភាកម្ពុជា" ដែលរៀបចំធ្វើឡើងដោយវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ ដើម្បីពិភាក្សាលើកិច្ចប្រឹងប្រែងលើកកម្ពស់សិទ្ធិ សេរីភាពខាងព័ត៌មាន ។[30] ជាថ្មីម្តងទៀត នេះជាសញ្ញាដ៏គួរឲ្យលើកទឹកចិត្តមួយដែលថា រដ្ឋាភិបាលបានទទួលខុសត្រូវលើការតាក់តែងច្បាប់សេរីភាពខាងព័ត៌មានដោយយកចិត្តទុកដាក់បំផុត ។

ជាមួយគ្នានោះដែរ នៅខែធ្នូ ឆ្នាំ២០១០ គណៈបក្សសមរង្ស៊ី បានបញ្ជូនសេចក្តីព្រាង ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ជូនទៅកាន់រដ្ឋសភា ហើយជាលទ្ធផលត្រូវបានបដិសេធ។ សេចក្តីព្រាងច្បាប់នេះមានបញ្ញត្តិសំខាន់ៗជាច្រើន ហើយប្រសិនបើសេចក្តីព្រាងនេះត្រូវបានអនុម័តនោះនឹងអាចធ្វើឲ្យមានជំហានដ៏ប្រសើរមួយ ក្នុងការធានាដល់សិទ្ធិសេរីភាពខាងព័ត៌មាននៅប្រទេសកម្ពុជា ។[31] ជាឧទាហរណ៍ សេចក្តីព្រាងច្បាប់នេះចែងថា រាល់ការលើកលែងក្នុងការបើក បង្ហាញព័ត៌មាន ត្រូវឆ្លងកាត់ការសាកល្បងផ្អែកផលប្រយោជន៍សាធារណៈ (មាត្រា៤០) ហើយមានបញ្ចូលបញ្ញត្តិបើកបង្ហាញព័ត៌មានជាសកម្មផងដែរ (មាត្រា៦ ដល់១៦) ដែលលម្អិតពីបញ្ញត្តិបែបផែនស្ថាប័នក្នុងការគាំទ្រដល់សិទ្ធិខាងព័ត៌មានផងដែរ (មាត្រា ៤១ ដល់៦៧) និងកិច្ចការពារអ្នកផ្តល់ ព័ត៌មាន (មាត្រា៦៨ ដល់៦៩) ។ មានបញ្ញត្តិបង្កើតឲ្យមានស្ថាប័នត្រួតពិនិត្យឯករាជ្យមួយផងដែរ (ជំពូក៦ និង៧ នៃសេចក្តីព្រាងច្បាប់) និងតុលាការបង្ហាញព័ត៌មាន (ជំពូក៨) ។

ជំហរនៃសេចក្តីព្រាងច្បាប់នេះ បើធៀបនឹងច្បាប់នានា គឺត្រូវបានបញ្ជាក់យ៉ាងច្បាស់ថា៖ យោងតាមមាត្រា៥ ច្បាប់នេះ *"នឹងលុបលើច្បាប់នានាដែលហាមឃាត់ ឬរារាំងការបង្ហាញឯកសារស្ថាប័នសាធារណៈ (ឬឯកជន) ហើយច្បាប់នេះនឹងជាច្បាប់សំខាន់ក្នុងការដាក់បង្ហាញព័ត៌មាន"* ប៉ុន្តែ *"ច្បាប់នេះមិនគួរ ហាមឃាត់ ឬរារាំងការដាក់បង្ហាញព័ត៌មាន ក្រោមច្បាប់ បញ្ញត្តិ គោលការណ៍ ឬការអនុវត្តន៍នានា នោះទេ"* ។ បន្ថែមលើសពីនេះគឺថា *"រាល់បញ្ញត្តិទាំងឡាយណាដែលផ្ទុយ*

---

[28] របាយការណ៍របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ មានចំណងជើងថា "យូសេហ្វឧបត្ថម្ភកិច្ចប្រជុំស្តីពីសេរីភាពខាងព័ត៌មានសម្រាប់តំណាងរាស្ត្រកម្ពុជា" ចុះផ្សាយថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលអាចរកមើលតាមគេហទំព័រដែលមានអាសយដ្ឋាន៖ www.usaid.gov/kh/documents/USAID_Highlights_Feb22_08.pdf.

[29] វ៉ៃម៉ុន លីអូ ដូចលេខយោងលេខ២០ ទំព័រ៦

[30] ម.ស.ម.ក "សេចក្តីថ្លែងការណ៍ ៖ ម.ស.ម.ក ស្វាគមន៍រាជរដ្ឋាភិបាលកម្ពុជាចំពោះជំហានឆ្ពោះទៅមុខនៃច្បាប់សេរីភាពខាងព័ត៌មាន" ចុះផ្សាយថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០ ដែលអាចរកមើលបានតាមរយៈគេហទំព័រដែលមានអាសយដ្ឋាន ៖ www.cchrcambodia.org/English/add_press_release/press_release/ 2010_12_08_cchr_press_release.pdf.

[31] អង្គការមាត្រា១៩ មានចំណងជើងថា "កម្ពុជា៖ សេចក្តីព្រាងច្បាប់ស្តីពីការទទួលបានព័ត៌មាន" សេចក្តីយោង១

*នឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍"*(មាត្រា៨០) ។

អង្គការមាត្រា១៩ សហការជាមួយនឹងវិទ្យាស្ថានដើម្បីតស៊ូមតិ និងគោលនយោបាយនៅកម្ពុជា បានបញ្ចប់នូវការវិភាគមួយលើសេចក្តីព្រាងច្បាប់នេះ ហើយបានស្នើថាច្បាប់គួរចែងឲ្យច្បាស់ថា នឹងមានវិសាលភាពលើស្ថាប័នទាំងអស់របស់រដ្ឋាភិបាល និងពលរដ្ឋគ្រប់រូប ។ បន្ថែមលើសនេះទៀតនោះគឺថា សេចក្តីព្រាងច្បាប់នេះគួរត្រូវបានធ្វើការកែប្រែដើម្បីធានាថា ព័ត៌មាននានានឹងត្រូវបានដាក់ផ្សាយតាមប្រព័ន្ធអ៊ីនធឺណេត ក្នុងភាសាមួយយ៉ាងច្បាស់លាស់ និងងាយស្រួលយល់ ។[32] ថ្វីបើមានភាពខ្វះខាតមួយចំនួនតូចក៏ដោយ ក៏អង្គការមាត្រា១៩ ស្នើដល់រដ្ឋាភិបាលឲ្យគាំទ្រដល់សេចក្តីព្រាងច្បាប់នេះ ហើយធានាថាច្បាប់នេះត្រូវបានអនុម័ត ។ លើសពីនេះ អង្គការនេះក៏បានអំពាវនាវដល់រដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ឲ្យធ្វើការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនជុំវិញបញ្ញត្តិនេះ ទាំងមុន និងក្រោយពេលដែលច្បាប់នេះត្រូវបានអនុម័ត ។

ក្នុងខែមិនា ឆ្នាំ២០១២ សមាជិកសភារបស់គណបក្ស សម រង្ស៊ី លោក សុន ឆ័យ បានបញ្ជូន សេចក្តីព្រាងច្បាប់ស្តីពីសេរីភាពក្នុងការទទួលព័ត៌មាន ដែលបានកែប្រែទៅកាន់រដ្ឋសភា អំពាវនាវឲ្យសមាជិកសភាពិភាក្សាលើច្បាប់នេះជាមុនសិនមុននឹងបដិសេធមិនពិចារណា ។[33]

---

[32] ដូចលេខយោងខាងលើ ទំព័រ៧ដល់១២

[33] ឌី ភ្នំពេញ ប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី០២ ខែមីនា ឆ្នាំ២០១២ ក្រោមចំណងជើងថា "យ៉ាងហោចណាស់ក៏មានការពិភាក្សាអំពីសេចក្តីព្រាង FOI"

# ៣. ការផ្តត់ផ្គង់ និងតម្រូវការ

ដោយសារថាសិទ្ធិខាងព័ត៌មាន ពិតជាមានសារៈសំខាន់ សម្រាប់ដំណើរការលទ្ធិប្រជាធិបតេយ្យ ការបង្កើតឲ្យមានច្បាប់ស្តីពីសេរីភាពខាងព័ត៌មាន ដើរតួនាទីដ៏មានសារៈសំខាន់ ។ ទោះយ៉ាងនេះក្តី ការបង្កើតឲ្យមានច្បាប់ស្តីពីសេរីភាពខាងព័ត៌មានតែមួយមុខ ពុំមែនជាដំណោះស្រាយទាំងស្រុង ចំពោះបញ្ហាកង្វះតម្លាភាពនិងគណនេយ្យភាព ដែលកើតមាននៅកម្ពុជានោះទេ ។ ច្បាប់សេរីភាពខាងព័ត៌មាន ត្រូវតែមានអមដោយ "បដិវត្តន៍វប្បធម៌" ក្នុងរបៀបដែលព័ត៌មានត្រូវបានគេមើលឃើញ និងតាមរយៈការផ្លាស់ប្តូរទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាល ។

## 3.១ ប្រវត្តិសង្ខេបនៃការរក្សាទុកកំណត់ត្រាព័ត៌មាននៅកម្ពុជា

ក្នុងបរិបទប្រទេសកម្ពុជា គេពិបាកទទួលបានព័ត៌មានសុក្រឹតអំពីរាជរដ្ឋាភិបាល ពីសំណាក់រាជរដ្ឋាភិបាលនិងស្ថាប័នរដ្ឋពាក់ព័ន្ធនានាណាស់ ។ ដើម្បីយល់ពីមូលហេតុនេះ ជាដំបូងគេត្រូវក្រឡេកមើលប្រវត្តិ អំពីរបៀបដែលកំណត់ត្រាព័ត៌មាន ត្រូវបានចងក្រងនិងរក្សាទុកនៅកម្ពុជាជាមុនសិន ។

គេពុំសូវឃើញមានជំនាញក្នុងការរក្សាទុកកំណត់ត្រាព័ត៌មានជាច្រើននោះឡើយ តាំងពីសម័យព្រះមហាក្សត្រខ្មែរកន្លងមក ថ្វីបើគេប្រទះឃើញមានកន្លែងមួយចំនួន ត្រូវបានប្រើសម្រាប់ទុកដាក់ឯកសារ និងឃើញមានបណ្ណាល័យរក្សាឯកសារជាច្រើន នៅតាមប្រសាទក្នុងតំបន់អង្គរក្តី ។

ទស្សនៈបច្ចឹមប្រទេសក្នុងការរក្សាទុកកំណត់ត្រា ត្រូវបាននាំចូលមកនៅក្នុងសម័យអាណានិគមបារាំង (១៨៦៣-១៩៥៣) ។ ឧទាហរណ៍ នៅឆ្នាំ១៩១១ សេចក្តីប្រកាសមួយដែលចេញដោយលោក វេស៊ីដង់ សូពេរីយ័រ ប្រចាំនៅកម្ពុជា ដែលមានគោលការណ៍ណែនាំបង្កើតបណ្ណសារដ្ឋានកណ្តាលមួយនៅទីក្រុងភ្នំពេញ ប៉ុន្តែការងារនេះមិនបានអនុវត្តទេ រហូតទាល់តែពេលដែលសកម្មជនបារាំងម្នាក់ឈ្មោះ ប៉ូល បូដេដ មកដល់នៅឆ្នាំ១៩១៧ ។[34]

មានឯកសារតិចតួចបានបន្សល់ទុក ពីសម័យអាណានិគមបារាំង ។ មានការនិយាយតគ្នាជាច្រើន ថាបន្ទាប់ពីឆ្នាំ១៩៧៥ និងការចូលមកដល់របស់របបខ្មែរក្រហម សៀវភៅនិងឯកសារទាំងអស់នៅក្នុងបណ្ណាល័យនិងបណ្ណសារដ្ឋានជាតិ ត្រូវបានបំផ្លិចបំផ្លាញចោល ។[35] ទោះជាយ៉ាងណាក្តីឯកសារដែលទុកនៅក្នុងបណ្ណសារដ្ឋានជាតិ មាននៅសល់មួយចំនួនធំដោយមិនបានប៉ះពាល់ ។ ប៉ុន្តែឯកសាររបស់ក្រសួងនានា ចាប់ពីទសវត្សឆ្នាំ៥០និង៦០ មិនឃើញបានបញ្ជូន ទៅក្នុងបណ្ណសារដ្ឋានជាតិនោះទេ នៅពេលរបបប៉ុលពតបានកាន់កាប់គ្រប់គ្រងកម្ពុជា ។ ឯកសារទាំងនេះអាចត្រូវ

---

[34] ឯកសារវប្បធម៌ខ្មែរ ឆ្នាំ២០១១ "ទិដ្ឋភាពទូទៅកម្ពុជា ៖ ប្រវត្តិសារវិតា" អាចរកបាននៅ www.culturalprofiles.net/cambodia/Directories/Cambodia_Cultural_Profile/-1727.html.

[35] បណ្ណសារដ្ឋានជាតិនៃកម្ពុជា "ប្រវត្តិនៃស្ថាប័នរបស់យើង" អាចរកបាននៅ www.nac.gov.kh/english/index.php?option=com_content&view=article&id=47&Itemid=58.

បានបំផ្លាញចោលនៅពេលដែលការិយាល័យរបស់ក្រសួង ត្រូវបានគេចូលឆែកឆេរ ឬនៅពេលដែលប្រជាពលរដ្ឋត្រឡប់ចូលក្រុងភ្នំពេញវិញ ។

អ្វីដែលបានដឹងនោះគឺក្នុងរបបខ្មែរក្រហម ស្ថាប័ននានាត្រូវបានបំផ្លាញទាំងស្រុង ហើយរដ្ឋបាលនិងបញ្ជីចុះឈ្មោះស៊ីវិលត្រូវបាត់បង់ដែរ ប្រជាពលរដ្ឋបាត់បង់ឯកសាររបស់ខ្លួន ឬបំផ្លាញដោយចេតនាដើម្បីបិទបាំងអំពីអត្តសញ្ញាណរបស់ខ្លួន និងដើម្បីគេចផុតពីរបបនេះ ។[36] ឧទាហរណ៍ គ្មានម្ចាស់កម្មសិទ្ធិឯកជនលើដីធ្លីនៅកម្ពុជា កំណត់ត្រាបណ្ណកម្មសិទ្ធិនិងអ្នកចុះឈ្មោះត្រូវបំផ្លាញ ដីទាំងអស់ជាកម្មសិទ្ធិរបស់រដ្ឋាភិបាល ។[37] ដូចនេះហើយ សព្វថ្ងៃនេះ បានជាម្ចាស់កម្មសិទ្ធិដី ស្របច្បាប់ក្តី និងសង្គមក្តីមានភាពខុសប្លែកពីគ្នា ។ (នឹងពិភាក្សាបន្ថែមនៅក្នុងជំពូកទី៧) ។

## ៣.២ តម្រូវការព័ត៌មាន

នៅកម្ពុជា តម្រូវការព័ត៌មានរបស់ប្រជាពលរដ្ឋទូទៅ គឺនៅមិនទាន់មាននោះទេ *"ដោយសារតែខ្វះខាតការយល់ដឹងពីសិទ្ធិ ការស្ទាក់ស្ទើរក្នុងការស្នើសុំព័ត៌មាន"រសើប" និងមានការយល់ដឹងតិចតួចក្នុងការស្វែងរកព័ត៌មាន និងរបៀបប្រើព័ត៌មានទាំងនេះ ដើម្បីជះឥទ្ធិពលលើការផ្លាស់ប្តូរ*[38] ទោះបីជាមានការផ្លាស់ប្តូរកើនឡើងជាច្រើន ជាពិសេសពាក់ព័ន្ធនឹងជម្លោះដីធ្លី យើងកំពុងតែមើលឃើញនូវការផ្លាស់ប្តូរទាំងនេះ ។ គេឃើញមានវប្បធម៌ឋានានុក្រមនៅកម្ពុជា ដែលឆ្លុះបញ្ចាំងពីភាពមិនស្មើគ្នារវាងអាជ្ញាធរ ។ នេះមានន័យថា កាលពីបុរាណ ប្រជាពលរដ្ឋស្ទាក់ស្ទើរក្នុងការសួររកព័ត៌មាន ឬមិនគិតថាពួកគាត់មានសិទ្ធិធ្វើបែបនេះ ព្រោះថាការធ្វើបែបនេះជាការជ្រៀតជ្រែកកិច្ចការរបស់អាជ្ញាធរ ។ ជាលទ្ធផល ប្រជាពលរដ្ឋទាំងនោះមិនសួរសំណួរ ទាក់ទងនឹងការចំណាយសាធារណៈ ថវិកា ឬក៏បញ្ហា "រសើប" ឡើយ។ ការសិក្សារបស់ធនាគារពិភពលោក បានរកឃើញថា ប្រជាពលរដ្ឋកម្ពុជាគិតថា ខ្លួនមិនតួនាទី ក្នុងការឲ្យអាជ្ញាធរទទួលខុសត្រូវ ដោយបញ្ជាក់ថា *"ការសម្ភាសជាញឹកញាប់បង្ហាញពីភាពមិនច្បាស់លាស់ក្នុងកម្រិតខ្ពស់ ចំពោះសំណួរ ឬសូម្បីតែការសួរសំណួរដដែលៗ ទៅកាន់អាជ្ញាធរ ដោយមានការភ័យខ្លាច ថាការសួរបែបនោះនឹងត្រូវបានបកស្រាយ ថាជាការបង្ហាញនូវភាពមិនជឿជាក់ និងបណ្តាលឲ្យមានការខឹងសម្បារ បាក់មុខ ឬការឆ្លើយតបជាអវិជ្ជមានមកវិញ"។*[39]

ឥរិយាបថរបស់ប្រជាពលរដ្ឋ និងគំនិតរបស់ពួកគាត់ចំពោះអាជ្ញាធរ គឺត្រូវបានបូកសរុបដោយអ្នកចូលរួម ក្នុងវេទិកាសាធារណៈកាលពីឆ្នាំ២០១០ ដែលរៀបចំឡើងដោយ ម.ស.ម.ក ស្តីពីការបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យ ដែលបាននិយាយថា *"គណបក្សប្រជាជនដែលជាគណបក្ស*

---

[36] ការិយាល័យថ្នាក់តំបន់អាស៊ី ២០០៥ "រាប់បញ្ចូលខ្ញុំផង! របាយការណ៍ប្រវត្តិ យុទ្ធនាការ**UBR** បណ្តោះអាសន្ន" ទំព័រ៨ អាចរកបាននៅ ssl.brookes.ac.uk/ubr/files/4/11-Count_me_in!_Report_Background_ARO.pdf ។

[37] **BNG Hemoregon,** កុម្ភៈ ២០០៩ " ដីធ្លី និងការសាងសង់នៅកម្ពុជា" ទំព័រ ១។ ពាក្យថា"អង្គការ" នៅក្នុងបរិបទនេះ ឬពាក្យដែលប្រើប្រាស់ក្នុងរបបខ្មែរក្រហម "អង្គការ" និយាយសំដៅលើថ្នាក់ដឹកនាំក្នុងរបបខ្មែរក្រហម។

[38] ធនាគារពិភពលោក ខែកុម្ភៈ ឆ្នាំ២០០៩ "ប្រទេសកម្ពុជាភ្ជាប់ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋ ៖ ការវាយតម្លៃការរួមចំណែករបស់សង្គមស៊ីវិលចំពោះអភិបាលកិច្ចល្អ" ទំព័រ១៩ ។

[39] ដូចខាងលើ ទំព័រ ១៩-២០ ។

*កាន់អំណាច គឺជាឪពុកម្តាយរបស់ពួកយើង តើយើងអាចផ្លាស់ប្តូរឪពុកម្តាយរបស់យើងដោយរបៀបណា?"*[40] ម.ស.ម.កក៏បានជួបនឹងឥរិយាបថបែបនេះ ក្នុងការស៊ើបអង្កេតក្នុងសោកនាដកម្មនៅកោះពេជ្រកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១០ ដែលមានមនុស្សប្រហែលជា ៣៥០ នាក់ត្រូវស្លាប់ និងមានចំនួនអ្នករងរបួសប្រហាក់ប្រហែលគ្នា ក្នុងឧបទ្ទវហេតុកកស្ទះនៅលើស្ពាន ក្នុងរាជធានីភ្នំពេញ សាក្សីហាក់ដូចជាស្ទាក់ស្ទើរ ក្នុងការសួរសំណួរទៅកាន់អាជ្ញាធរ ឬផ្តល់យោបល់អវិជ្ជមាន និងមានការភ័យខ្លាច ថានឹងអាចមានការតបតបែបអវិជ្ជមានមកវិញ ប្រសិនបើសួរសំណួរទាំងអស់នេះចេញទៅនោះ ។

## ៣.៣ វប្បធម៌គ្រប់គ្រង

ទស្សនៈឋានានុក្រម របស់ប្រជាពលរដ្ឋកម្ពុជា បានឆ្លុះបញ្ចាំងដោយឥរិយាបថ របស់រដ្ឋាភិបាលដែលបន្តគ្នានេះ និងដោយសារតែអ្នកកាន់អំណាច យល់ពីលក្ខណៈធម្មជាតិបែបនេះ និងតួនាទីរបស់រដ្ឋាភិបាល ។ នៅកម្ពុជា មន្ត្រីរដ្ឋាភិបាលបង្ហាញពីទំនោរតិចតួច ក្នុងការចែករំលែកព័ត៌មាន ដោយគិតថាសកម្មភាពទាំងនេះ ជាកិច្ចការរបស់អ្នកកាន់អំណាចតែប៉ុណ្ណោះ ។ ក្នុងវេទិកាសាធារណៈដែលរៀបចំឡើងដោយ ម.ស.ម.ក ក្នុងឆ្នាំ២០១០ អំពីការបោះឆ្នោត និងការអនុវត្តលទ្ធិប្រជាធិបតេយ្យ អ្នកចូលរួមនិងវាគ្មិនបានទទួលស្គាល់ ថាមន្ត្រីរដ្ឋាភិបាលមានឆន្ទៈជាងកាលពីឆ្នាំមុនៗ ក្នុងការដឹងពីកាតព្វកិច្ចរបស់ពួកគាត់ គឺដើម្បីបម្រើឲ្យម្ចាស់ឆ្នោត មិនមែនដើម្បីផលប្រយោជន៍របស់គណបក្សនោះទេ ។ ក៏ប៉ុន្តែ នៅតែមានការខកខានរបស់រដ្ឋមន្ត្រី និងសមាជិកសភា ដើម្បីពិចារណានូវផលប៉ះពាល់ នៃការសម្រេចចិត្តរបស់ពួកគេ មកលើជីវភាពរបស់ប្រជាពលរដ្ឋទូទៅ និងសារៈសំខាន់នៃការទទួលបានព័ត៌មានគ្រប់គ្រាន់ក្នុងដំណើរការបោះឆ្នោតជាទូទៅ ។[41]

ចំណុចនេះបានបង្ហាញ តាមរយៈការខកខានរបស់សមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជា ដើម្បីចូលរួមក្នុងវេទិកាសាធារណៈ ដែលរៀបចំឡើងដោយ ម.ស.ម.ក ។ វេទិកាទាំងអស់នេះបានលើកយក នូវបញ្ហាដែលមានសារៈសំខាន់សម្រាប់ប្រជាពលរដ្ឋធម្មតា និងផ្តល់វេទិកាឲ្យពួកគាត់ដើម្បីធ្វើការចូលរួមជាមួយរដ្ឋាភិបាល គណបក្សប្រឆាំង អាជ្ញាធរមូលដ្ឋាន និងបុគ្គលកាន់អំណាចដទៃទៀត ។ ក្នុងឆ្នាំ២០០៩ និង២០១០ ម.ស.ម.ក បានអញ្ជើញសមាជិកសភា ដើម្បីចូលរួមក្នុងវេទិកាសាធារណៈទូទាំងប្រទេសចំនួន៣១ ។ ក្នុងនោះ សមាជិកសភារបស់គណបក្សប្រជាជនបានចូលរួម និងស្តាប់ពីការព្រួយបារម្ភ របស់អ្នកចូលរួមក្នុងវេទិកានេះតែមួយលើកគត់ ។[42] ដូចគ្នាដែរ ក្នុងចំណោមវេទិកាចំនួន ៤ និងសិក្ខាសាលាចំនួន ១ ដែល ម.ស.ម.ក បានរៀបចំ ដែលជាផ្នែកមួយនៃគម្រោងស្តីពីលំហលទ្ធិប្រជាធិបតេយ្យ និងការបោះឆ្នោត របស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ មិនមានសមាជិកសភាមកពីគណបក្សប្រជាជនណាម្នាក់ ចូលរួមនោះទេ ទោះបីជា ម.ស.ម.ក បានអញ្ជើញជាច្រើនលើកច្រើនសារក៏ដោយ ។

---

[40] ម.ស.ម.ក វេទិកាស្តីពីលំហលទ្ធិប្រជាធិបតេយ្យ និងការបោះឆ្នោត ខែកក្កដា ឆ្នាំ២០១១ ទំព័រ៣៨ ។

[41] ដូចខាងលើ ទំព័រ៣៩ ។

[42] សម្រាប់ព័ត៌មានបន្ថែមសូមអាន ៖ http://www.cchrcambodia.org/publicforummap/.

នៅកម្ពុជា គេឃើញមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងរដ្ឋាភិបាល និងអាជីវកម្ម ។ ដូច្នេះអាចមានការអះអាង ថារដ្ឋាភិបាលខ្វះខាតការលើកទឹកចិត្ត ឲ្យផ្តល់នូវព័ត៌មាន អំពីកិច្ចសន្យាសាធារណៈ ជាពិសេស នៅពេលដែលកិច្ចសន្យានោះ ពាក់ព័ន្ធនឹងផលប្រយោជន៍ ផ្នែកអាជីវកម្មរបស់អ្នកតំណាងរដ្ឋាភិបាល ឬក៏អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធ ជាមួយសមាជិករដ្ឋាភិបាល ។ ចំណុចនេះបង្ហាញឲ្យឃើញ ដោយមានការលេចធ្លាយព័ត៌មាន ដែលត្រូវបានបោះពុម្ពផ្សាយក្នុង សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ក្នុងខែមិនា ឆ្នាំ២០១០ ដែលបានបង្ហាញពីគម្រោងថវិកាឯកជន ដែលក្រុមអាជីវកម្មផ្តល់មូលនិធិគាំទ្រអង្គភាពមួយចំនួន និងកងវរសេនាតូច នៃកងយោធពលខេមរភូមិន្ទ ។[43] ក្នុងចំណោមម្ចាស់មូលនិធិឯកជនទាំងនេះ មានក្រុមហ៊ុនចំនួន ៧ ជាក្រុមហ៊ុនរបស់ ឬគ្រប់គ្រងដោយបុគ្គលដែលជានាយកនៃក្រុមហ៊ុន ដែលបានទទួលដីសម្បទានសេដ្ឋកិច្ចនៅកម្ពុជា ចាប់តាំងពីឆ្នាំ២០០០ ដូចដែលមានរាយនាម ក្នុងឯកសាររបស់អង្គការសហប្រជាជាតិឆ្នាំ២០០៧ ។[44] ក្នុងករណីមួយចំនួនកងយោធពលខេមរភូមិន្ទ ជាប់ពាក់ព័ន្ធក្នុងការបណ្តេញប្រជាពលរដ្ឋ ចេញពីដីធ្លី ដែលជាដីសម្បទានសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ដូចជាក្នុងករណីរបស់ ព្រឹទ្ធសភារបស់គណបក្សប្រជាជន និងម្ចាស់ជំនួយដល់កងយោធពលខេមរភូមិន្ទ លី យ៉ុងផាត់ ជាដើម ។ នេះមានន័យថា ការផ្តល់មូលនិធិដល់កងយោធពលខេមរភូមិន្ទ គឺដើម្បីចង់ប្រើប្រាស់ទំនាក់ទំនងនេះ ដើម្បីជួយសម្រួលដល់ការយកដីសម្បទានសេដ្ឋកិច្ចនេះតែប៉ុណ្ណោះ ។ ព័ត៌មាននេះអាចឲ្យសាធារណជនទូទៅ រកអានបាន តាមរយៈអ្នកសារព័ត៌មានផ្នែកស៊ើបអង្កេតដ៏ឆ្នើមតែប៉ុណ្ណោះ មិនមែនតាមរយៈនីតិវិធីបើកចំហរបស់រដ្ឋាភិបាល ឬការប្តេជ្ញាចិត្តគោរពតាមតម្លាភាពរបស់ក្រុមអ្នកដែលផ្តល់ និងទទួលដីសម្បទានឡើយ ។

មិនតែប៉ុណ្ណោះក៏មានភស្តុតាងថា ព័ត៌មានដែលត្រូវបានចាត់ទុកថាជាព័ត៌មានរសើប ឬអាចបំផ្លាញមន្ត្រីរដ្ឋាភិបាល ព័ត៌មានទាំងនោះនឹងត្រូវបានរដ្ឋាភិបាលរក្សាទុក និងការពារមិនឲ្យមានការចែកចាយទៅដល់សាធារណជន ។ ករណីសោកនាដកម្មនៅកោះពេជ្រ ជាឧទាហរណ៍ រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការ ដើម្បីស៊ើបអង្កេតព្រឹត្តិការណ៍នារាត្រីថ្ងៃទី២២ ខែវិច្ឆិកា ។ ប៉ុន្តែ ការស៊ើបអង្កេតនេះ ត្រូវបានបញ្ចប់ត្រឹមតែមួយសប្តាហ៍ប៉ុណ្ណោះ និងមានការសន្និដ្ឋាន ថាសោកនាដកម្មនេះបណ្តាលមកពីការភ័យស្លន់ស្លោរបស់អ្នកនៅលើស្ពាន ។ ខណៈពេលដែល លោកនាយករដ្ឋមន្ត្រីហ៊ុន សែន ទទួលស្គាល់ ថារដ្ឋាភិបាលមានកំហុសដែលមិនបានគិតដល់ ថាការកកស្ទះបែបនេះអាចកើតឡើងបាន ក៏ប៉ុន្តែគ្មានមន្ត្រីណាម្នាក់តម្រូវឲ្យទទួលខុសត្រូវនោះទេ ។ បន្ថែមពីលើនេះទៀតក៏មិនមានព័ត៌មានលម្អិត ស្តីពីការខកខានរបស់រដ្ឋាភិបាល ឬក៏ការចាត់វិធានការដើម្បីការពារព្រឹត្តិការណ៍ក្នុងពេលអនាគត ត្រូវបានបោះពុម្ពផ្សាយនោះដែរ ។ ផ្ទុយទៅវិញ មានត្រឹមតែការរៀបចំសន្និសីទសារព័ត៌មាន ដែលមានសេចក្តីថ្លែងការណ៍ព័ត៌មាន អាចអានបានក្នុងវែបសាយរបស់សាលារាជធានីភ្នំពេញប៉ុណ្ណោះ ។ មិនតែប៉ុណ្ណោះ ក៏មានរបាយការណ៍ដ៏គួរឲ្យព្រួយបារម្ភជាច្រើន

---

[43] ឯកសារដែលមានការលើ្យងឆ្ងល់ត្រូវបានបោះពុម្ពក្នុងសារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ កាលពីថ្ងៃទី១០ ខែមិនា ឆ្នាំ២០១០។

[44] *ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា* ខែមិថុនា ឆ្នាំ២០០៧ "ដីសម្បទានសេដ្ឋកិច្ចនៅកម្ពុជា ៖ ទស្សនៈផ្នែកសិទ្ធិមនុស្ស" អាចអានបាន ៖ www.sithi.org/landissue/source/ELC/OHCHR_ELC%20report_2007.pdf ។

ស្តីពីការរារាំងរបស់អាជ្ញាធរ មិនឲ្យចែកចាយខ្សែវីដេអូនៅក្នុងរាត្រីនោះ ដែលរាយការណ៍ថាមន្ត្រីនគរបាលបានប្រមូលខ្សែវីដេអូដែលសាក្សីបានថត នៅយប់ដែលសោកនាដកម្មបានកើតឡើង ។[45]

## ៣.៤ "បដិវត្តន៍វប្បធម៌"

"បដិវត្តន៍វប្បធម៌" នៃការយល់ដឹងក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា ពីតួនាទីរបស់ពួកគាត់ក្នុងសង្គមប្រជាធិបតេយ្យ និងការយល់ដឹងក្នុងចំណោមរដ្ឋាភិបាលកម្ពុជា ពីផលប្រយោជន៍ និងតម្រូវការនៃការមានតម្លាភាព មានសារសំខាន់ណាស់ក្នុងការបង្កើតច្បាប់ស្តីពីសេរីភាពខាងព័ត៌មាន ។ ប្រជាពលរដ្ឋកម្ពុជា ត្រូវតែយល់ថាអ្នកតំណាងរបស់ពួកគេ គឺត្រូវមានទំនួលខុសត្រូវចំពោះពួកគាត់ ហើយដែលការចូលរួមមួយចំណែករបស់ពួកគេ តាមរយៈការសុំព័ត៌មាន និងការសួរសំណួរ គឺជាគ្រឹះសំខាន់ក្នុងដំណើរការអភិវឌ្ឍន៍ជីវភាពសេដ្ឋកិច្ច នយោបាយ សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។ ស្របពេលនេះដែរ រដ្ឋាភិបាលត្រូវតែទទួលស្គាល់ ថាមន្ត្រីដែលត្រូវគេបោះឆ្នោតឲ្យ គឺមានអំណាចដឹកនាំជាតំណាងឲ្យសាធារណជន និងត្រូវមានគណនេយ្យភាពចំពោះពលរដ្ឋ ។ មិនត្រូវឲ្យមានអាជ្ញាធរដែលគិតជំនួស ឬសន្មតថាសាធារណជនមិនយល់ ឬក៏មិនចាំបាច់ត្រូវដឹង ពីព័ត៌មានលម្អិតនៃការសម្រេចចិត្តរបស់រដ្ឋាភិបាលនោះទេ ។

ប្រហាក់ប្រហែលគ្នានេះដែរ ត្រូវតែមានការទទួលស្គាល់ថាការកើនឡើងនៃលទ្ធភាពទទួលបានព័ត៌មានគឺមិនមែនមានន័យថាគ្រាន់តែទទួលបានព័ត៌មាននៅក្នុងកន្លែងផ្ទុកទិន្នន័យសាធារណៈនោះទេ ក៏ប៉ុន្តែក៏មានន័យថាព័ត៌មានទាំងនោះត្រូវតែអាចយកមកប្រើប្រាស់បាន ។ អត្រាអ្នកចេះអានអក្សរនៅកម្ពុជាមាន ៧៤% ដែលជាកម្រិតទាបនៅឡើយ ។[46] ដូច្នេះ មានការចាំបាច់ណាស់ដែលព័ត៌មានទាំងនោះត្រូវបានផ្សព្វផ្សាយក្នុងទម្រង់ដែលប្រជាពលរដ្ឋភាគច្រើនពិតជាអាចទទួលដឹងឮបានប្រាកដមែន ។

ជំពូកទី៤ ដល់ជំពូកទី៧ នៃរបាយការណ៍នេះ ត្រួតពិនិត្យមើលនូវបញ្ហាដែលប៉ះពាល់ដល់ប្រជាពលរដ្ឋកម្ពុជា ក្នុងជីវភាពប្រចាំថ្ងៃ និងថាតើលទ្ធភាពទទួលព័ត៌មាន អាចមានផលប៉ះពាល់ជាវិជ្ជមានយ៉ាងណា មកលើការអភិវឌ្ឍបែបប្រជាធិបតេយ្យ ក្នុងស្ថានភាពបែបនេះ ។ ខណៈពេលដែលរបាយការណ៍នេះផ្តល់នូវអនុសាសន៍ ចំពោះខ្លឹមសារក្នុងច្បាប់សេរីភាពខាងព័ត៌មាន អ្វីដែលសំខាន់គឺត្រូវកត់សម្គាល់ ថាការផ្លាស់ប្តូរពិតប្រាកដក្នុងចំណុចនេះ គឺនឹងអាចកើតមានបានលុះត្រាតែមានការផ្លាស់ប្តូរទស្សនៈ នៃសារៈសំខាន់របស់ព័ត៌មានក្នុងគ្រប់វិស័យទាំងអស់នៅក្នុងសង្គម ។ ប្រសិនបើគ្មានការផ្លាស់ប្តូរបែបនេះទេ ច្បាប់ស្តីពីសេរីភាពខាងព័ត៌មាននឹងជាច្បាប់ដែលគ្មានប្រសិទ្ធភាព។

---

[45] ម.ស.ម.ក ខែវិច្ឆិកា ឆ្នាំ២០១១ "សោកនាដកម្មកោះពេជ្រ ៖ មួយឆ្នាំកន្លងផុត ចម្ងល់នៅតែបន្ត", សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ "ការបង្ក្រាបខ្សែវីដេអូនៅកោះពេជ្រ" ។

[46] អង្គការពលកម្មអន្តរជាតិ ៖ www.ilo.org/public/english/region/asro/bangkok/skills-ap/skills/cambodia literacy.htm ។

# ៤. សេរីភាពខាងព័ត៌មាន និងអំពើពុករលួយ

ការចែកចាយព័ត៌មានស្តីពីកិច្ចការសាធារណៈ និង ការគ្រប់គ្រងបញ្ហាដើម្បីជាប្រយោជន៍ដល់សាធារណជន យោងតាមសម្តីរបស់សមាជិកសភាគណបក្សប្រឆាំង លោក សុន ឆ័យ គឺ "*ជាវិធីមួយដែលមានការទទួលស្គាល់បំផុតក្នុងការប្រឆាំងអំពើពុករលួយ*" ។[47] ច្បាប់ស្តីពីសេរីភាពខាងព័ត៌មានមានទំនាក់ទំនងជិតស្និទ្ធ ជាមួយនឹងច្បាប់ប្រឆាំងអំពើពុករលួយ ពោលគឺថា កង្វះខាតតម្លាភាពជាឫសគល់ នៃការប្រព្រឹត្តអំពើពុករលួយ ហើយលទ្ធភាពទទួលបានព័ត៌មានជាសាធារណៈ ជាមធ្យោបាយដ៏មានសារៈសំខាន់ សម្រាប់ទប់ស្កាត់ និងបើកកកាយអំពើពុករលួយ ។ យោងតាមការកត់សម្គាល់របស់នាយក «ស្ថាប័នគោលនយោបាយនិងតស៊ូមតិ» លោក ណៃប សុិនថៃ មានប្រសាសន៍ថា ៖ "*ប្រសិនបើចង់ឲ្យច្បាប់ប្រឆាំងអំពើពុករលួយមានប្រសិទ្ធភាព យើងត្រូវការទិន្នន័យ យើងត្រូវតែដឹងថាបុគ្គលណាខ្លះពុករលួយ និងបុគ្គលណាខ្លះស្អាតស្អំ ។ ប្រសិនបើគ្មានព័ត៌មានយើងមិនអាចមើលឃើញថានរណាជាអ្នកប្រព្រឹត្តបទល្មើសនោះទេ*" ។[48]

## ៤.១ អំពើពុករលួយនៅកម្ពុជា

អំពើពុករលួយបានរីករាលដាលនៅកម្ពុជា និងជ្រាបចូលទៅក្នុងជីវភាពសាធារណៈគ្រប់កម្រិតទាំងអស់ ។ ការវាយតម្លៃអំពើពុករលួយរបស់ ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក នៅកម្ពុជា បានធ្វើការសន្និដ្ឋានថាអំពើពុករលួយបានក្លាយទៅជាចំណែកមួយក្នុងជីវភាពប្រចាំថ្ងៃ ។[49] ថ្មីៗនេះ អង្គការតម្លាភាពអន្តរជាតិបានបង្ហាញថា អំពើពុករលួយក្នុងប្រទេសកម្ពុជា "មានលក្ខណៈជាប្រព័ន្ធ" ដែលប្រជាពលរដ្ឋសម្របទៅនឹងការសូកប៉ាន់ ដែលឥឡូវនេះ កើតឡើង "ដោយស្វ័យប្រវត្តិ"[50] ។ អវត្តមាននៃតម្លាភាព មានន័យថាអំពើពុករលួយអាចកើតឡើងគ្រប់ភាគីទាំងអស់ ចាប់ពីរដ្ឋាភិបាលទៅកាន់ផ្នែកតុលាការ អ្នកជំនួញ វេជ្ជបណ្ឌិត គ្រូបង្រៀន និងអ្នកលក់ទំនិញ អ្នកទាំងអស់នេះគឺជាជនដែលពាក់ព័ន្ធនឹងចំណាយមិនផ្លូវការ និងមានកិច្ចសន្យាអាថ-

---

47 គ្រីស្តូប ប៉េស៊ូ ថ្ងៃ៤ ឧសភា ២០១០ សន្ទរកថានៅក្នុង៖ ភពលោកទិវាសារព័ត៌មានពី សេរីភាពខាង័ត៌មាន៖ សិទ្ធិយល់ដឹង " ,រៀបចំដោយ អង្គការយូនេស្កូOHCHR ប្រចាំនៅកម្ពុជាជាមួយនឹងក្រសួងព័ត៌មាន ភ្នំពេញ កម្ពុជា ។

48 ទឹកដីខ្មែរ អាចអានបាន ៖ khcampus.wordpress.com/2010/02/14/what-is-freedom-of-information/.

49 ទីភ្នាក់ងារផ្តល់ជំនួយអភិវឌ្ឍសហរដ្ឋអាមេរិក/កម្ពុជា (ម៉ៃឃើល អែម. ខាឡាវ៉ាន, ស៊ើជីអូ ដាយអាស ប្រ៊ីក, ដើរ៉ល អូប្រៀន) ខែសីហា ឆ្នាំ២០០៤ "ការវាយតម្លៃអំពើពុករលួយនៅកម្ពុជា" ទំព័រ២ ។

50 សូមមើលវិចារណកថារបស់លោកព្រាប កុល នាយកប្រតិបត្តិអង្គការតម្លាភាពអន្តរជាតិកម្ពុជា ថ្ងៃទី១២ មេសា ២០១២ ក្នុងវិទ្យុសម្លេងសហរដ្ឋអាមេរិកជាភាសាខ្មែរអំពី "ឥឡូវនេះ អំពើពុករលួយមានលក្ខណៈជាប្រព័ន្ធ៖ អង្គការតម្លាភាពអន្តរជាតិ" អាចអានបាន៖ http://www.voanews .com/khmer-english/news/Widespread-Corruption-Now-Systemic-Transparency-international-146868565.html

កំបាំង ថ្មីៗនេះរដ្ឋាភិបាលប្រទេសអូស្ត្រាលី បានសន្និដ្ឋានថាប្រទេសកម្ពុជាបាត់បង់ប្រាក់ចំណូលរវាង ៣០០លានដុល្លារ ទៅ៥០០លានដុល្លារក្នុងអំពើពុករលួយ ។[51]

សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ របស់អង្គការតម្លាភាពអន្តរជាតិ ឆ្នាំ២០១១ បានចាត់ចំណាត់ថ្នាក់កម្ពុជានៅលេខរៀងទី១៦៤ ក្នុងចំណោមប្រទេសចំនួន១៨៣ ។[52] ក្នុងករណីអំពើពុករលួយដែលមានកម្រិតខ្ពស់ សកម្មភាពមួយចំនួនដែលល្បីល្បាញនោះគឺពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់ (សូមអានជំពូក៧) រដ្ឋាភិបាលធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនដើម្បីបង្កើតនូវភាពផ្តាច់មុខ ឬក៏កិច្ចសន្យាផ្តល់សម្បទានសាធារណៈ (សូមអានជំពូក៧) និងការបំប៉ោងចំណាយក្នុងថវិកាជាតិ ។

ពាក់ព័ន្ធនឹងតម្លាភាពនៃថវិកា ដែលទាក់ទិននឹងរបៀបដែលធនធានសាធារណៈត្រូវបានចំណាយ និងជាចំណុចសំខាន់នៃអំពើពុករលួយដែលអាចកើតមាន ការផ្តួចផ្តើមនៃថវិកាបើកចំហបានដាក់ពិន្ទុឲ្យកម្ពុជាតិចបំផុតគឺ ១៥ពិន្ទុ លើ១០០ពិន្ទុ។[53] វៀតណាម ដែលមានពិន្ទុ១៤ គឺជាប្រទេសតែមួយក្នុងចំណោមប្រទេសក្នុងអាស៊ីអាគ្នេយ៍ដែលមានពិន្ទុទាបជាងកម្ពុជា ។ ពាក់ព័ន្ធនឹងកម្ពុជា របាយការណ៍ក៏បានសន្និដ្ឋានដែរថា *"រដ្ឋាភិបាលផ្តល់ព័ត៌មានតិចបំផុតដល់សាធារណជន ស្តីពីថវិការបស់រដ្ឋាភិបាលកណ្តាល និងការវាយតម្លៃសកម្មភាពហិរញ្ញវត្ថុតាមរយៈការស្ទង់មតិ"* ។[54] ជាឧទាហរណ៍ កម្ពុជាបានបោះពុម្ព និងផ្សព្វផ្សាយដល់សាធារណជន នូវឯកសារចំនួន៤ប៉ុណ្ណោះក្នុងចំណោមឯកសារចំនួន៧ ដែលបានកំណត់ក្នុងរបាយការណ៍គំនិតផ្តួចផ្តើមថវិកាដោយបើកចំហ។ បន្ថែមពីលើនោះ រដ្ឋាភិបាល មិនបានផ្សព្វផ្សាយនូវច្បាប់ចម្លងនៃថវិកាដែលគ្មានលក្ខណៈបច្ចេក-ទេស ដែលអាចអនុញ្ញាតឲ្យប្រជាពលរដ្ឋបានយល់កាន់តែប្រសើរ ស្តីអំពីអាទិភាពនៃការចំណាយនោះទេ ។ ប្រសិនបើសាធារណជនមិនមានលទ្ធភាពទទួលបានព័ត៌មានសំខាន់នៃថវិការបស់ប្រទេសជាតិ ដូច្នេះមានការពិបាកក្នុងការបញ្ជាក់មើល ថាតើថវិកាទាំងនោះត្រូវបានចំណាយ ដើម្បីជាប្រយោជន៍ចំពោះប្រជាពលរដ្ឋឬក៏អត់ ។ កង្វះខាតនៃតម្លាភាពនេះ បង្កើននូវភាពងាយស្រួលឲ្យអំពើលាក់កំបាំងអាចកើតឡើងបានដោយគ្មានការត្រួតពិនិត្យដោយឯករាជ្យ ។

---

[51] វិទ្យុសំឡេងសហរដ្ឋអាមេរិក ជាភាសាខ្មែរ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ "ការធ្វើសវនកម្មក្នុងឆ្នាំ ២០០៧ រកឃើញថាមានភាពខុសប្រក្រតី និងភាពគ្មានប្រសិទ្ធភាព" អាចអានបាន ៖ www.voanews.com/khmer-english/news/2007-Audit-Finds-Irregularities-Inefficiencies--130348243.html.

[52] តម្លាភាពអន្តរជាតិ ឆ្នាំ២០១១ "សន្ទស្សន៍ការយល់ឃើញអំពើពុករលួយឆ្នាំ២០១១" ទំព័រ៣ ។

[53] សូមអានការផ្តួចផ្តើមថវិកាបើកចំហ របាយការណ៍ថវិកាបើកចំហឆ្នាំ២០១០ ទំព័រ៥ អាចអានបាន ៖ http://internationalbudget.org/wp-content/uploads/2011/06/2010_Full_Report-English.pdf.

[54] ការផ្តួចផ្តើមថវិកាបើកចំហ ខែមករា ឆ្នាំ២០១១, សន្ទស្សន៍នៃថវិកាបើកចំហ ឆ្នាំ២០១០, សេចក្តីសង្ខេបតម្លាភាពថវិកា ៖ កម្ពុជា វគ្គ៣ អាចអានបាន ៖ http://www.ngoforum.org.kh/eng/dip/dipdocs/NBP_OBI_Brief_2010-English.pdf ។

## ៩.២ ការប្រឆាំងអំពើពុករលួយ

ក្នុងខែកញ្ញា ឆ្នាំ២០០៧ រដ្ឋាភិបាលបានផ្តល់សច្ចាប័នលើអនុសញ្ញាប្រឆាំងអំពើពុករលួយរបស់អង្គការសហប្រជាជាតិ (អ.ប.អ.ព.អ.ស.ប)។ អ.ប.អ.ព.អ.ស.ប បានរួមបញ្ចូលនូវឯកសារយោងមួយចំនួនស្តីពីសេរីភាពខាងព័ត៌មាន និងកំណត់នូវជំហានដែលរដ្ឋគួរតែដើរដើម្បីលើកកម្ពស់តម្លាភាព ។ ចំណុចទាំងនេះ រួមបញ្ចូលទាំងការបង្កើតនូវស្ថាប័នស៊ើបអង្កេត និងតាមដានអំពើពុករលួយ និងការចែកចាយនូវព័ត៌មានផ្លូវការជាសាធារណៈ ។

នីតិកម្មប្រឆាំងអំពើពុករលួយ ក្នុងទម្រង់ជាច្បាប់ប្រឆាំងអំពើពុករលួយ ត្រូវបានអនុម័តដោយរដ្ឋសភាក្នុងខែមិនា ឆ្នាំ២០១០ និងចូលជាធរមាន ក្នុងខែសីហា ឆ្នាំ២០១០ ។[55] ច្បាប់នេះពង្រឹងអំណាចរបស់អង្គភាពប្រឆាំងអំពើពុករលួយ ដែលត្រូវបានបង្កើតមុនពេលមានការអនុម័តច្បាប់នេះ និងដែលមានតួនាទីអនុវត្តច្បាប់ សេចក្តីបង្គាប់ និងបទបញ្ជា ពាក់ព័ន្ធនឹងអំពើពុករលួយ និងដឹកនាំការងារក្នុងការការពារ និងលុបបំបាត់អំពើពុករលួយក្នុងប្រទេសកម្ពុជា ។ ចំណុចនេះរាប់បញ្ចូលទាំងការតាមដាន និងស៊ើបអង្កេតអំពើពុករលួយ និងពិនិត្យមើលពាក្យបណ្តឹងដែលទទួលបានស្តីពីអំពើពុករលួយ ។ ច្បាប់នេះក៏បានបង្កើតនូវក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ដែលនឹងផ្តល់ជាការណែនាំ និងអនុសាសន៍ដល់អង្គភាពប្រឆាំងអំពើពុករលួយអំពីការងារប្រឆាំងអំពើពុករលួយផងដែរ។

## ៩.៣ សេរីភាពខាងព័ត៌មាន

ខណៈពេលដែលច្បាប់ប្រឆាំងអំពើពុករលួយ ត្រូវបានបុគ្គលមួយចំនួនឃើញថាជាជំហានមួយដ៏វិជ្ជមានក្នុងការកម្ចាត់អំពើពុករលួយ ប៉ុន្តែការវិភាគដ៏ស៊ីជម្រៅបានបង្ហាញ ថាច្បាប់នេះមិនមានអំណាច ក្នុងការកម្ចាត់អំពើពុករលួយនោះទេ ។ ឧទាហរណ៍ ច្បាប់នេះមិនបាននិយាយពីលទ្ធភាព ឬកាតព្វកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការបោះពុម្ពផ្សាយនូវព័ត៌មាន ពាក់ព័ន្ធនឹងសកម្មភាព និងការស៊ើបអង្កេតរបស់អង្គភាពនេះទេ ។ ចំណុចនេះជាលទ្ធផល បានប្រមូលផ្តុំការសន្មត់ទុកជាមុនប្រឆាំងនឹងការបើកចំហព័ត៌មាន ជាជាងទទួលស្គាល់ នូវគោលនយោបាយដែលតម្រូវឲ្យមានការបើកចំហ យ៉ាងទូលំទូលាយដូចមានចែងក្នុងគោលការណ៍សេរីភាពខាងព័ត៌មាន ។ មួយវិញទៀត ច្បាប់ប្រឆាំងអំពើពុករលួយ បានច្រាន

> **អនុសញ្ញាប្រឆាំងអំពើពុករលួយ**
>
> **មាត្រា១០(ក)** ៖ រដ្ឋគួរតែអនុម័ត "នីតិវិធី ឬបទបញ្ជា អនុញ្ញាតឲ្យសមាជិកសាធារណៈទូទៅអាចទទួលបានព័ត៌មានស្តីពីការរៀបចំ តួនាទី និងដំណើរការសម្រេចចិត្តរបស់រដ្ឋបាលសាធារណៈរបស់ខ្លួនតាមការគួរ ហើយដោយមានការការពារឯកជនភាព និងទិន្នន័យឯកជនក្នុងសកម្មភាពសម្រេចចិត្ត និងផ្នែកច្បាប់ ដែលពាក់ព័ន្ធនឹងសាធារណជន" ។

[55] ច្បាប់ប្រឆាំងអំពើពុករលួយ អាចស្វែងរកបានលើគេហទំព័រសិទ្ធិមនុស្សរបស់ ម.ស.ម.ក ៖ www.sithi.org/temp.php?url=view_law.php&&id=172.

ចោលទុកជាមុនយ៉ាងបើកចំហនូវការបោះពុម្ពផ្សាយរបាយការណ៍ផ្សេងៗរបស់ អង្គភាពប្រឆាំងអំពើពុករលួយ ប៉ុន្តែរបាយការណ៍អស់ទាំងនោះត្រូវបញ្ជូនទៅលោកនាយករដ្ឋមន្ត្រីដោយផ្ទាល់ជំនួសវិញ ចំណុចនេះលើកយកនូវការព្រួយបារម្ភ មិនត្រឹមតែការខ្វះខាតនូវតម្លាភាពនោះទេ ប៉ុន្តែក៏មានការព្រួយបារម្ភពីភាពឯករាជ្យផ្នែកនយោបាយរបស់អង្គភាពប្រឆាំងអំពើពុករលួយផងដែរ ។[56]

ក្នុងច្បាប់នេះ បុគ្គល និងស្ថាប័នជាក់លាក់មួយចំនួន ត្រូវតែធ្វើការប្រកាសពីទ្រព្យសម្បត្តិ និងបំណុល ដើម្បីចៀសវាងនូវទំនាស់ផលប្រយោជន៍ (មាត្រា១៧) ។ ប៉ុន្តែ ច្បាប់នេះបានចែងថារាល់ការប្រកាសទៅដល់អង្គភាពប្រឆាំងអំពើពុករលួយ នឹងត្រូវរក្សាជាសម្ងាត់ ចំណុចនេះរាប់បញ្ចូលទាំងការប្រកាសដោយសមាជិកព្រឹទ្ធសភា សមាជិកសភា រដ្ឋាភិបាល និងចៅក្រមអាសនៈ និងថ្នាក់ដឹកនាំសង្គមស៊ីវិល ។[57] គណបក្សប្រឆាំងបានទាមទារឲ្យមានការធ្វើវិសោធនកម្មលើច្បាប់នេះដើម្បីឲ្យមានការបើកចំហនូវព័ត៌មាននៃទ្រព្យសម្បត្តិនេះជាសាធារណៈ ប៉ុន្តែការទាមទារនេះមិនត្រូវបានលើកយកមកពិចារណានោះទេ ។ ដូចដែលបានកត់សម្គាល់ដោយតំណាងរាស្ត្រគណបក្ស សម រង្ស៊ី លោក សុន ឆ័យ មានប្រសាសន៍ថា "*យើងជឿថាប្រសិនបើអ្នកចាត់ទុកការប្រកាសទ្រព្យសម្បត្តិជាការសម្ងាត់បំផុត ជាពិសេសទ្រព្យសម្បត្តិរបស់បុគ្គលក្នុងរដ្ឋាភិបាល ការប្រកាសនេះនឹងគ្មានន័យអ្វីនោះទេ ។ ដូច្នេះ យើងចង់ឲ្យសាធារណជនមានសិទ្ធិដឹងពីទ្រព្យសម្បត្តិទាំងអស់របស់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់រដ្ឋាភិបាល*" ។[58]

ច្បាប់ប្រឆាំងអំពើពុករលួយ ក៏ខកខានមិនបានចែងពីក្របខណ្ឌច្បាប់សម្រាប់ការការពារផ្នែករាងកាយ និងផ្នែកច្បាប់ដល់បុគ្គលដែលហ៊ានបើកកកាយពីអំពើពុករលួយ ដូចដែលបានស្នើក្នុងគោលការណ៍សេរីភាពខាងព័ត៌មាន ។ តាមពិត មាត្រា៤១ក្នុងច្បាប់នេះបានចាត់ទុកការលេចធ្លាយព័ត៌មាន និងការផ្ដល់ព័ត៌មានមិនពិតពីអំពើពុករលួយថាជាបទល្មើស ។ មិនតែប៉ុណ្ណោះ ក៏គ្មានតម្រូវការជាក់លាក់បញ្ជាក់ពីគោលបំណងពាក់ព័ន្ធនឹងពាក្យបណ្ដឹងនោះទេ មានន័យថាគ្មានភាពច្បាស់លាស់ថាតើពាក្យបណ្ដឹងនេះគឺជាពាក្យបណ្ដឹងមិនត្រឹមត្រូវ ជាជាងពាក្យបណ្ដឹងដែលមានបំណងភូតកុហក នឹងអាចត្រូវបានចាត់ទុកជាបទល្មើសដែរឬទេ ។ បញ្ញត្តិទាំងនេះ និងការខ្វះខាតនូវភាពច្បាស់លាស់ថាតើបញ្ញត្តិទាំងនេះនឹងត្រូវបកស្រាយបែបណា គឺហាក់ដូចជាដើរតួជាការបង្អាក់មិនឲ្យបុគ្គលដែលដឹងព័ត៌មានពីអំពើពុករលួយចូលមករាយការណ៍ ។ មិនតែប៉ុណ្ណោះ ដោយសារតែដំណើរការច្បាប់ដែលនៅស្រពេចស្រពិល និងការមិនតម្រូវជាកាតព្វកិច្ចដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការស៊ើបអង្កេតអំពើពុករលួយ ធ្វើឲ្យមានការព្រួយបារម្ភថាតើព័ត៌មានដែលទទួលបាននឹងត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពក្នុងការលុបបំបាត់អំពើពុករលួយដែរឬទេ ។

---

[56] ម.ស.ម.ក ខែមិនា ឆ្នាំ២០១០ "លិខិតរបស់ ម.ស.ម.ក ទៅកាន់ប្រធានរដ្ឋសភាពីសេចក្ដីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ" អាចអានបាន ៖ www.cchrcambodia.org/English/add_press_release/press_release/cchr%20letter%20to%20the%20president%20of%20the%20national%20assembly%20concerning%20the%20draft%20anti-corruption%20law%20(english%20translation)(031010_1268279956).pdf.
[57] សូមអានមាត្រា១៧ និង២០ នៃសេចក្ដីព្រាងច្បាប់ប្រឆាំងអំពើពុករលួយឆ្នាំ២០១០ ។
[58] លោក សុន ឆ័យ ដូចដែលបានដកស្រង់សម្ដីក្នុងវិទ្យុអេប៊ីស៊ី, វិទ្យុអូស្ត្រាលី កាលពីថ្ងៃទី១២ ខែមិនា ឆ្នាំ២០១០ អត្ថបទអាចអានបាន ៖ www.radioaustralia.net.au/connectasia/stories/201003/s2843946.htm ។

ច្បាប់ស្តីពីសេរីភាពខាងព័ត៌មាន ដែលរួមបញ្ចូលនូវការសន្មត់ទុកជាមុននូវការបើកចំហជាអតិបរមាមានន័យថាការអនុវត្តន៍របស់មន្ត្រីរដ្ឋាភិបាល នឹងត្រូវបានតាមដានយ៉ាងត្រឹមត្រូវ ហើយអំពើពុករលួយនឹងត្រូវបានបើកកកាយ ។ ដូច្នេះ សេរីភាពខាងព័ត៌មានបំពេញបន្ថែមឲ្យច្បាប់ប្រឆាំងអំពើពុករលួយ តាមរយៈការពង្រឹងលទ្ធភាពនៃប្រជាពលរដ្ឋកម្ពុជាទូទៅដើម្បីទាមទារឲ្យមន្ត្រីរដ្ឋាភិបាលទទួលខុសត្រូវចំពោះពួកគាត់ ។ ស្របពេលជាមួយនោះដែរ ការបើកចំហការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយជាសាធារណៈ អាចបង្កើនភាពគួរឲ្យជឿជាក់ និងភាពស្របច្បាប់ និងទំនុកចិត្តមកលើការងាររបស់អង្គភាពនេះ ។ ពាក់ព័ន្ធនឹងសេរីភាពខាងព័ត៌មាន និងអំពើពុករលួយ ម.ស.ម.ក ផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោម ៖

## អនុសាសន៍

- ដើម្បីឲ្យអនុលោមទៅតាមគោលការណ៍សេរីភាពខាងព័ត៌មាន គួរតែមានការធ្វើវិសោធនកម្មលើច្បាប់ប្រឆាំងអំពើពុករលួយដើម្បី ៖

- ធានាឲ្យមានការបើកចំហជាអតិបរមា
- ធានានូវឯករាជ្យភាពរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- រួមបញ្ចូលនូវបទបញ្ញត្តិដែលចែងថា ការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ របាយការណ៍ និងការបើកចំហទាំងឡាយណាដែលអង្គភាពនេះបានទទួល គួរតែផ្សព្វផ្សាយជាសាធារណៈ
- ផ្តល់នូវការការពារឲ្យបានទូលំទូលាយចំពោះអ្នកផ្តល់ព័ត៌មាន និង
- ដកចេញនូវបទល្មើសស្តីពីការលេចធ្លាយព័ត៌មាន ។

- រដ្ឋាភិបាលគួរតែបង្កើតនូវគណៈកម្មាធិការ ឬក៏ក្រុមការងារដើម្បីវិភាគនូវច្បាប់ប្រឆាំងអំពើពុករលួយ និងច្បាប់នៅកម្ពុជាដទៃៗទៀត (និងការធ្វើវិសោធនកម្ម ឬក៏បញ្ញត្តិថ្មីៗដែលបានអនុម័ត) ដើម្បីធានាថាបញ្ញត្តិទាំងនោះអនុលោមទៅនឹងកាតព្វកិច្ចរបស់ អនុសញ្ញាស្តីពីការប្រឆាំងអំពើពុករលួយ ។

# ៥. សេរីភាពខាងព័ត៌មាន និងសារព័ត៌មាន

បណ្ដាញសារព័ត៌មានដែលមានគុណភាព និងសេរី គឺចាំបាច់ណាស់សម្រាប់ការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ តាមរយៈការផ្សព្វផ្សាយអត្ថបទ និងរឿងរ៉ាវស្ដីពីកិច្ចការសាធារណៈនិងតួលេខ ហើយបណ្ដាញសារព័ត៌មានជួយសម្រួលដល់ការត្រួតពិនិត្យរបស់សាធារណជន ហើយដូច្នេះអាចជួយពង្រឹងរដ្ឋាភិបាលបែបប្រជាធិបតេយ្យ ។ ព័ត៌មានដែលផ្ដល់ទៅសាធារណជនតាមរយៈបណ្ដាញសារព័ត៌មានចម្រុះ ក៏អាចឲ្យប្រជាពលរដ្ឋដឹងពីការសម្រេចចិត្តចំពោះកិច្ចការសាធារណៈផងដែរ ។ លទ្ធភាពទទួលបានព័ត៌មាន គឺមានភាពចាំបាច់សម្រាប់បណ្ដាញសារព័ត៌មានដើម្បីអនុវត្តតួនាទីរបស់ខ្លួន ។ ថ្វីបើមានការវិវឌ្ឍន៍ខ្លះៗក្នុងការផ្សព្វផ្សាយព័ត៌មានមួយចំនួននៅកម្ពុជាក្ដី ក៏បណ្ដាញព័ត៌មាននៅតែមានឧបសគ្គខ្លះៗក្នុងការស្វែងរកព័ត៌មានជាក់លាក់មួយចំនួនផងដែរ ។

## ៥.១ លទ្ធភាពទទួលបានព័ត៌មាន

ដូចដែលបានកត់សម្គាល់ក្នុងជំពូកទី២ មាត្រា៥ នៃច្បាប់ស្ដីពីរបបសារព័ត៌មាន បានចែងថា សារព័ត៌មានមានសិទ្ធិទទួលបានព័ត៌មានរបស់រដ្ឋាភិបាល ទោះបីជាលទ្ធភាពនេះនឹងត្រូវបានកម្រិតដោយយោងទៅលើមូលដ្ឋានមួយចំនួន ដូចដែលមានចែងក្នុងច្បាប់ក៏ដោយ ។

ក្នុងដំណើរការរៀបចំរបាយការណ៍នេះ ម.ស.ម.ក បាននិយាយជាមួយអ្នកសារព័ត៌មានមួយចំនួនដើម្បីឲ្យដឹងថាតើច្បាប់នេះអនុវត្តជាក់ស្ដែងបែបណា ។ អ្នកសារព័ត៌មាន បានកត់សម្គាល់ថា មានបទពិសោធន៍វិជ្ជមានមួយចំនួនដែលអនុវត្តដូចមានចែងក្នុងមាត្រា៥ នៃច្បាប់ស្ដីពីរបបសារ-ព័ត៌មាន ។ ពិសេស នៅពេលដែលធ្វើការរាយការណ៍ពីបញ្ហាដែលមិនពាក់ព័ន្ធនឹងនយោបាយ អ្នកដែលត្រូវបានសម្ភាសន៍បញ្ជាក់ថា រដ្ឋាភិបាល និងក្រសួងនានាមានព័ត៌មានត្រៀមទុកជាស្រេច ។ អ្នកសារព័ត៌មានក៏ទទួលស្គាល់នូវការវិវត្តន៍ថ្មីៗ ដែលពួកគេអាចទទួលបានព័ត៌មានជាក់លាក់ណាមួយយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព ដោយសារតែក្រសួងនានារបស់រដ្ឋាភិបាលបានតែងតាំងអ្នកនាំពាក្យដើម្បីអាចទទួលយកសំណួរដោយផ្ទាល់ ។ រដ្ឋាភិបាលក៏បានបង្កើត អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស ហើយក្នុងខែមិនា ឆ្នាំ២០១១ ក៏បានបង្កើតអង្គភាពប្រតិកម្មសារព័ត៌មានថ្មី ដើម្បីផ្ដល់ព័ត៌មានទៅអ្នកសារព័ត៌មានស្ដីពីបញ្ហាពាក់ព័ន្ធនឹងសកម្មភាពរបស់យោធា ការងារទូត និងសន្តិ-សុខជាតិទៀតផង។[59]

មានការស្វាគមន៍ចំពោះការវិវឌ្ឍន៍នៃលំហូររបស់ព័ត៌មាន ផ្ដល់លទ្ធភាពទទួលព័ត៌មានសម្រាប់អ្នកសារព័ត៌មាន និងសាធារណជនទូទៅដោយផ្ទាល់ និងអាចងាយរកបាន ។ ក៏ប៉ុន្តែ នៅមានចំណុចដែលត្រូវកែលម្អ ដូចជាក្រសួងមួយចំនួនមិនទាន់តែងតាំងអ្នកនាំពាក្យនៅឡើយ និងអ្នក

---

[59] សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១១ "នាយករដ្ឋមន្ត្រីជំរុញឲ្យមានក្រុមការងារផ្នែកសារព័ត៌មាន" ។

សារព័ត៌មានមួយចំនួនដែលត្រូវបានសម្ភាស បានលើកយកបញ្ហាស្តីពីពេលវេលា ដែលអាចជួបអ្នកនាំពាក្យទាំងនេះផងដែរ ។ មិនតែប៉ុណ្ណោះអ្នកសារព័ត៌មានមួយចំនួនដែលត្រូវបានសម្ភាស បានលើកឡើងដែរ ថាអ្នកនាំពាក្យបាននិយាយចាកពីប្រធានបទជាក់ស្តែង ហើយព័ត៌មានដែលពួកគាត់ផ្តល់ឲ្យគឺពេលខ្លះមិនច្បាស់លាស់ ឬក៏មិនត្រឹមត្រូវ ។

អ្នកសារព័ត៌មានទាំងនោះក៏បានកត់សម្គាល់ផងដែរថា ពេលដែលត្រូវបានសួរសំណួរពាក់ព័ន្ធនឹងព័ត៌មានរសើបផ្នែកនយោបាយ ឬក៏ព័ត៌មានដែលអាចធ្វើឲ្យមានការរិះគន់ដល់គោលនយោបាយ របស់រដ្ឋាភិបាល ជាពិសេសពាក់ព័ន្ធទៅនឹងដីធ្លី ដែលជាប្រធានបទនៃជម្លោះជាបន្តបន្ទាប់រវាងប្រជាពលរដ្ឋ អាជ្ញាធរ និងក្រុមហ៊ុន នោះពួកគេច្រើនតែជួបប្រទះនឹងឧបសគ្គ ហើយការស្នើសុំព័ត៌មានគឺជាទូទៅត្រូវបានបដិសេធ ។ ដូចដែលបានកំណត់ខាងលើ និងផ្ទុយពីគោលការណ៍សេរីភាពខាងព័ត៌មាន ច្បាប់ស្តីពីរបបសារព័ត៌មាន មិនបានចែងពីយន្តការបណ្តឹងឧទ្ធរណ៍ និងមិនមានស្ថាប័នតាមដាន មានន័យថាមិនមានបណ្តឹងសាទុក្ខសម្រាប់អ្នកសារព័ត៌មានដែលត្រូវបានបដិសេធនូវលទ្ធភាពទទួលពត៌មាននោះទេ ។

មានការកត់សម្គាល់បន្ថែមថា នៅពេលដែលសួររកព័ត៌មានក្នុងលក្ខណៈមិនសូវផ្លូវការ ជាទូទៅការស្នើសុំនេះត្រូវបានបដិសេធ ។ អ្នកសារព័ត៌មានដែលត្រូវបានសម្ភាស មានប្រសាសន៍ថាបច្ចេកទេសដែលមន្ត្រីរដ្ឋាភិបាលបានប្រើប្រាស់ គឺនិយាយថាពួកគេរវល់ខ្លាំងណាស់ ដែលមិនអាចឆ្លើយតបនឹងសំណួរទាំងនេះបាន និងប្រាប់ឲ្យអ្នកសារព័ត៌មានទៅរកប្រភពដទៃទៀតដើម្បីរកព័ត៌មានបែបនោះ ។ ឧទាហរណ៍ អ្នកសារព័ត៌មានម្នាក់បានពណ៌នាអំពីដំណើរការស្នើសុំព័ត៌មានរបស់ក្រសួងហិរញ្ញវត្ថុ ដែលជាដំណើរការមួយ ដែលទាមទារឲ្យអ្នកសួរព័ត៌មានចំណាយពេលវេលាច្រើន ដោយតម្រូវឲ្យមានការស្នើសុំជាលាយលក្ខណ៍អក្សរ និងមានសំណួរឲ្យច្បាស់លាស់ក្នុងលិខិតនោះផងដែរ ។ បទពិសោធន៍របស់អ្នកសារព័ត៌មានម្នាក់ គឺថាការឆ្លើយតបត្រូវបានពន្យារពេល និងព័ត៌មានដែលទទួលបានគឺមានភាពមិនច្បាស់លាស់ ។

តាមរយៈការពិភាក្សារបស់ ម.ស.ម.ក ជាមួយអ្នកសារព័ត៌មាន ក៏បានបង្ហាញយ៉ាងច្បាស់ថាបទពិសោធន៍រវាងអ្នកសារព័ត៌មានកម្ពុជា និងអ្នកសារព័ត៌មានបរទេសក៏អាចខុសគ្នាផងដែរ ដែលអ្នកសារព័ត៌មានកម្ពុជាអាចងាយស្រួលក្នុងការទទួលបានព័ត៌មាន ប្រហែលមកពីការប្រើភាសាដូចគ្នា និងតាមរយៈទំនាក់ទំនងផ្ទាល់ខ្លួន ។ ប៉ុន្តែ អ្វីដែលជាក់ច្បាស់គឺអ្នកសារព័ត៌មានកម្ពុជាអាចនឹងត្រូវឲ្យបង្ហាញពីប្រភពដែលគេទទួលបានសំណូក ដើម្បីជួយលាក់បាំងព័ត៌មានជាក់លាក់ណាមួយ ហើយក្នុងករណីធ្ងន់ធ្ងរជាងនេះទៅទៀត គឺត្រូវបានគំរាមកំហែង ឬសូម្បីតែរងការវាយប្រហារ ។ អ្នកដែលត្រូវបានសម្ភាស ក៏បានបង្ហាញពីការបដិសេធមិនផ្តល់ព័ត៌មាន ជាញឹកញាប់ដែលកើតមានឡើងចំពោះការបោះពុម្ពផ្សាយរបស់សារព័ត៌មានជាភាសាអង់គ្លេស ដែលទូទៅគឺហ៊ានរិះគន់រដ្ឋាភិ-បាល និងរាយការណ៍ចំពោះព័ត៌មានរសើបច្រើនជាង ប្រសិនបើប្រៀបធៀបជាមួយសារព័ត៌មានខ្មែរ ។

មតិយោបល់ទាំងអស់ដែលបានមកពីអ្នកសារព័ត៌មាន បានបង្ហាញថាគោលការណ៍នៃការបើកចំហជាអតិបរមា នៅមិនទាន់បានអនុវត្តទាំងស្រុងនៅកម្ពុជានោះទេ ទោះបីជាអ្នកនាំពាក្យរបស់ក្រសួងនីមួយៗ ត្រូវបានតែងតាំងឲ្យផ្តល់ព័ត៌មានបែបនេះក៏ដោយ ។ កង្វះខាតលទ្ធភាពទទួលព័ត៌-មានឲ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ បានរារាំងលទ្ធភាពអ្នកសារព័ត៌មានក្នុងការផ្តល់ព័ត៌មាន និងជំរុញឲ្យមានការជជែកពិភាក្សា និងប៉ះពាល់ដល់មុខងាររបស់សារព័ត៌មាន ដែលជាសសរទ្រូងទីបួនរបស់លទ្ធប្រជាធិបតេយ្យ ។

## ៥.២ ការចែកចាយ

បញ្ហាពាក់ព័ន្ធនឹងការចែកចាយក៏កើតមានឡើងដែរ ឬប្រសិនបើប្រើប្រាស់ភាសាក្នុង កតិកាសញ្ញាស្តី ពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយគឺ *"ផ្សព្វផ្សាយ"* ព័ត៌មាន ដែលបានដាក់កម្រិតមកលើលទ្ធភាព របស់សាធារណជនក្នុងការទទួលបានព័ត៌មាន។

ការមានអំណាចរបស់រដ្ឋាភិបាលមកលើសារព័ត៌មាន មានន័យថារដ្ឋាភិបាលមានអំណាចគ្រប់គ្រងយ៉ាងខ្លាំងមកលើការចែកចាយព័ត៌មាន ។ ស្ថានីយទូរទស្សន៍ទាំងអស់ ស្ថានីយវិទ្យុស្ទើរតែទាំងអស់ និងសារព័ត៌មានភាសាខ្មែរសំខាន់ៗមួយចំនួនជារបស់ ឬក៏គ្រប់គ្រងដោយសមាជិកគណ-បក្សប្រជាជនកម្ពុជា ឬក៏បុគ្គលដែលមានទំនាក់ទំនងជាមួយនឹងគណបក្សកាន់អំណាច ។[60] ដូច្នេះមិនត្រូវភ្ញាក់ផ្អើលនោះទេ ដែលព័ត៌មានផ្សព្វផ្សាយចេញពីបណ្តាញសារព័ត៌មានទាំងនេះ គឺមានទំនោរទៅខាងរដ្ឋាភិបាល ។ ស្ថានីយទូរទស្សន៍ដែលល្បីល្បាញបំផុត គឺបណ្តាញទូរទស្សន៍កម្ពុជា (ស៊ីធីអ៊ិន) ជាក្រុមហ៊ុនរបស់ទីប្រឹក្សារបស់នាយករដ្ឋមន្ត្រី ចំណែកឯទូរទស្សន៍បាយ័ន គឺគ្រប់គ្រងដោយកូនស្រីរបស់លោកនាយករដ្ឋមន្ត្រី ។ អាជ្ញាប័ណ្ណដើម្បីបង្កើតបណ្តាញ និងប្រព័ន្ធផ្សព្វផ្សាយលើទូរទស្សន៍ និងវិទ្យុ ត្រូវផ្តល់ដោយក្រសួងព័ត៌មាន ក៏ប៉ុន្តែ អំណាចនេះហាក់ដូចជាត្រូវបានប្រើដើម្បីជាមធ្យោបាយគាបសង្កត់រាល់ព័ត៌មានរសើបផ្នែកនយោបាយ ដោយធានាថាអាជ្ញាប័ណ្ណនឹងផ្តល់ទៅក្រុមហ៊ុនដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាលតែប៉ុណ្ណោះ ។[61] ក្នុងខែសីហា និងកញ្ញា ឆ្នាំ ២០១១ ក្រសួងព័ត៌មាន បានបិទសារព័ត៌មានខ្មែរចំនួន ៣៩ ព្រោះមានការចោទថាសារព័ត៌មានទាំងនេះកាន់កាប់អាជ្ញាប័ណ្ណហួសអាយុកាលកំណត់ និងក្នុងករណីចំនួនពីរ គឺដោយសារតែការខកខានក្នុងការជូនដំណឹងពីការដូរទីតាំងរបស់ពួកគេ ។[62] ក្រសួងព័ត៌មានបានយល់ព្រមជាគោលការណ៍ដើម្បីអនុញ្ញាតឲ្យអ្នកសារព័ត៌មាន រស់ សុឃិត បើកអាជីវកម្មសារព័ត៌ មានឈ្មោះថា "ការបកស្រាយព័ត៌មានស្តីពីអំពើពុករលួយ" ទោះបីជា លោក សុឃិត មិនទាន់បានទទួលអាជ្ញាប័ណ្ណជាផ្លូវការនៅ

---

[60] ខុមហ្វ្រែល ខែកុម្ភៈ ឆ្នាំ២០១០ "លទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់នៅកម្ពុជា" ទីព័រ១២ អាចអានបាន ៖ www.comfrel.org/images/others/1265785063Comfrel-Cambodia%20Democratic %20Reform%202009-En-Final.pdf.

[61] ដូចខាងលើ ទំព័រ១៣ ។

[62] ម.ស.ម.ក ខែវិច្ឆិកា ឆ្នាំ២០១១ "សលាកប័ត្រព័ត៌មានសេរីភាពមូលដ្ឋាន ៖ ការបិទសារព័ត៌មាន" អាចអានបាន ៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=21&id=5&lang=khm

ឡើយក៏ដោយ ។ លោក រស់ សុឃិត ជាអ្នកសារព័ត៌មានក្រៅម៉ោងដែលនៅឆ្នាំ២០០៩ លោកបានជាប់ពន្ធនាគារពីបទផ្សាយព័ត៌មានមិនពិត ដោយការផ្ញើសារបង្ខូចបង្អាប់មួយដល់លោក សយ សុភាព ដែលជាអ្នកផ្សាយព័ត៌មាននៅបណ្ដាញទូរទស្សន៍កម្ពុជា (ស៊ីធីអ៊ិន) ដ៏ល្បីល្បាញ ។[63] ការបិទប្លុកមួយចំនួនជាក់លាក់ ដូចជា ខេអាយ មីឌៀ គឺជាឧទាហរណ៍ដ៏ថ្មីបំផុតនៃការគាបសង្កត់ ដែលរដ្ឋាភិបាលកំពុងតែអនុវត្ត ។ វិធីសាស្ត្រមួយនេះ អាចរារាំងមិនឲ្យប្រជាពលរដ្ឋធម្មតា បញ្ចេញសំឡេងរបស់ខ្លួនតាមរយៈសារព័ត៌មាន និងរារាំងពួកគេមិនឲ្យទទួលបានព័ត៌មានដើម្បីបញ្ចេញគំនិតផ្ទាល់របស់ពួកគេ និងដើម្បីចូលរួមការជជែកពិភាក្សាដែលពួកគេបានទទួលព័ត៌មាន និងការជជែកពិភាក្សាជាលក្ខណៈប្រជាធិបតេយ្យ ។[64]

សេរីភាពខាងព័ត៌មាន និងសារព័ត៌មានគួរតែពិនិត្យមើលក្នុងបរិបទដ៏ទូលាយ នៃសេរីភាពបញ្ចេញមតិនៅកម្ពុជា ។ ការប្រើប្រាស់ច្បាប់ដើម្បីគាបសង្កត់ កាត់ទោស និងទណ្ឌកម្មផ្នែកព្រហ្មទណ្ឌរួមនឹងបច្ចេកទេស ដូចជាការគំរាមកំហែង ការឃាយឃី និងសូម្បីតែការសម្លាប់ សកម្មភាពទាំងអស់នេះបានរារាំងមិនឲ្យមានសារព័ត៌មានបើកចំហ និងសេរី ។[65] ខណៈពេលដែលច្បាប់ស្ដីពីសារព័ត៌មាន បានចែងក្នុងមាត្រា២០ថា "*គ្មានជនណាម្នាក់ត្រូវចាប់ចង ឬជាប់ពន្ធនាគារ ដោយសារការបញ្ចេញមតិឡើយ*" មានពាក្យជាច្រើនក្នុងច្បាប់នេះ និងការបកស្រាយច្បាប់ស្ដីពីរបបសារព័ត៌មាន និងក្រមព្រហ្មទណ្ឌ នៅមិនច្បាស់លាស់នៅឡើយ ។ ឧទាហរណ៍ មាត្រា១២ ចែងថាច្បាប់មិនរាប់បញ្ចូលការ "*មិនទាន់គិតដល់ការផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ*" និងមាត្រា២០ចែងថា "*អំពើប្រព្រឹត្តរបស់និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទ ដែលរំលោភច្បាប់ព្រហ្មទណ្ឌ ត្រូវទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ*" ។ ខណៈពេលដែលក្នុងករណីរបស់លោក ម៉ុង ឬទ្ធី និងកែវ សុធា (ខែមេសា ឆ្នាំ២០០២) បានទទួលជោគជ័យក្នុងការតវ៉ា ថាបញ្ញត្តិបរិហារកេរ្តិ៍ត្រូវបានជំនួសដោយ មាត្រា ១០ ក្នុងច្បាប់ស្ដីពីរបបសារព័ត៌មាន (ដែលបានកំណត់ថាបទបរិហារកេរ្តិ៍ជាទោសរដ្ឋប្បវេណី) ក៏ប៉ុន្តែករណីនេះមិនត្រូវបានយកមកអនុវត្តក្នុងស្ថានភាពជាក់ស្ដែងនោះទេ ហើយអ្នកសារព័ត៌មានបន្តរងការកាត់ទោសក្នុងក្រមព្រហ្មទណ្ឌ ។[66] លោក ហង្ស ចក្រា ម្ចាស់សារព័ត៌មានខ្មែរម្ចាស់ស្រុក ដែលមានទំនាក់ទំនងជាមួយនឹងគណបក្សប្រឆាំង គឺជាអ្នកសារព័ត៌មានមួយរូបដែលរងនូវការចោទប្រកាន់បែបនោះ ។ គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ បន្ទាប់ពីសារព័ត៌មានរបស់លោកបានផ្សព្វផ្សាយនូវអត្ថបទមួយចំនួន ចោទប្រកាន់ដល់អ្នកជំនួយការ របស់លោកឧបនាយករដ្ឋមន្ត្រី សុខ អាន ថាពាក់ព័ន្ធនឹងអំពើពុករលួយ ។[67] បន្ទាប់ពីលោក ហង្ស ចក្រា

---

[63] សារព័ត៌មាន ឌឹ ខេមបូឌា ដេលី ថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១២ "ក្រសួងយល់ព្រមចំពោះចំណងជើងសារព័ត៌មានថ្មីដែលរាយការណ៍ពីការប្រឆាំងអំពើពុករលួយ" ។

[64] សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្ដិ៍ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ "វែបសាយរបស់គណបក្សប្រឆាំងត្រូវបានបិទ" ។

[65] ម.ស.ម.ក និងអ្នកទាំងអស់ ខែកញ្ញា ឆ្នាំ២០១០ "កម្ពុជាត្រូវបានបំបិទមាត់ ៖ លទ្ធិប្រជាធិបតេយ្យស្ថិតក្នុងគ្រោះថ្នាក់?" ជាពិសេសជំពូកទី៤ ។

[66] អង្គការមាត្រា១៩ ខែធ្នូ ឆ្នាំ២០០៥ "សេរីភាពបញ្ចេញមតិ និងសារព័ត៌មាន" ទំព័រ៥៤ ។

[67] អ្នកសារព័ត៌មានគ្មានព្រំដែន ខែកុម្ភៈ ឆ្នាំ២០១០ "កម្ពុជា ៖ លោកនាយករដ្ឋមន្ត្រី លោកបានសន្យាថានឹងគ្មានអ្នកសារព័ត៌មានរូបណានឹងត្រូវចូលក្នុងពន្ធនាគារនោះទេ" ទំព័រ៣ ។

បដិសេធមិនព្រមបង្ហាញឈ្មោះរបស់ប្រភពព័ត៌មាន (ការបដិសេធនេះមានចែងក្នុងមាត្រា២ នៃច្បាប់ស្តីពីរបបសារព័ត៌មាន) រូបលោកត្រូវបានគេកាត់ទោសដោយកំបាំងមុខ ពីបទផ្សាយព័ត៌មានមិនពិត និងផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ និងបង្គាប់ឲ្យបង់ប្រាក់ពិន័យចំនួន ៩.០០០.០០០ រៀល (ប្រហែលជា ២.២៥០ដុល្លារសហរដ្ឋអាមេរិក) ។[68]

ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលចូលជាធរមានក្នុងខែធ្នូ ឆ្នាំ២០១០ បានចែងជាបើកចំហ ថា បទបរិហារកេរ្តិ៍ដែលពាក់ព័ន្ធនឹងសារព័ត៌មាន គួរតែដោះស្រាយក្នុងបញ្ញត្តិរដ្ឋប្បវេណីនៃច្បាប់ស្តីពីរបបសារព័ត៌មាន ។ ក៏ប៉ុន្តែ ត្រូវនៅចាំមើលបន្តទៀតថាតើបញ្ញត្តិទាំងអស់នេះនឹងយកមកអនុវត្តជាក់ស្តែងបែបណាខ្លះ ជាពិសេស ក្រមព្រហ្មទណ្ឌដែលនៅមានបទបញ្ញត្តិដែលអាចបង្ហាញពីការគំរាមកំហែងដ៏ធ្ងន់ធ្ងរមកលើសេរីភាពបញ្ចេញមតិរបស់អ្នកសារព័ត៌មាន ដែលរួមមានទាំងបទល្មើសនៃការបញ្ចេញមតិជាសាធារណៈដើម្បីជះឥទ្ធិពលមកលើប្រព័ន្ធតុលាការ និងធ្វើឲ្យបាត់បង់ជំនឿមកលើសេចក្តីសម្រេចរបស់តុលាការ ។[69]

ជាលទ្ធផលនៃការភ័យខ្លាចការគំរាមកំហែង ការសម្លុត និងបទល្មើសព្រហ្មទណ្ឌ នៅមានភស្តុតាងបង្ហាញថាអ្នកសារព័ត៌មានប្រើប្រាស់នូវការចាប់ពិរុទ្ធខ្លួនឯង និងចៀសវាងមិនផ្សព្វផ្សាយព័ត៌មានដែលរដ្ឋាភិបាលពិចារណាថាប៉ះពាល់ ឬមានលក្ខណៈជាព័ត៌មានរសើបផ្នែកនយោបាយ។[70] អ្នកសង្កេតការណ៍បានកត់សម្គាល់ថា មានគោលនយោបាយដែលកំពុងអនុវត្តសម្រាប់អ្នកបោះពុម្ព-ផ្សាយ និងនិពន្ធនាយក ដើម្បីបោះពុម្ពផ្សាយនូវព័ត៌មានមិនសូវរសើប និងមិនសូវគួរឲ្យចាប់អារម្មណ៍ "*ដើម្បីគេចផុតពីគ្រោះថ្នាក់*" ។[71]

ក៏ប៉ុន្តែត្រូវចងចាំថា ខណៈពេលដែលមានបរិយាកាសជំរុញ និងជួយសម្រួលពហុនិយមក្នុងសារព័ត៌មាន មានសារៈសំខាន់ក្នុងលទ្ធភាពទទួលបានព័ត៌មាន អ្នកសារព័ត៌មានគឺជាតំណភ្ជាប់ចម្បងមួយរវាងសាធារណជន និងព័ត៌មាន ។ អ្នកសារព័ត៌មានទាំងនេះគួរតែពិចារណានូវការទទួលខុសត្រូវរបស់ពួកគេ ដើម្បីបោះពុម្ពផ្សាយព័ត៌មានរសើប ។ មានរបាយការណ៍កើនឡើងជាច្រើនដែលបង្ហាញថាអ្នកសារព័ត៌មានទទួល ឬសូម្បីតែស្នើចរិកាដើម្បីជាថ្នូរនឹងការមិនផ្សព្វផ្សាយព័ត៌មាន

---

[68] ដូចខាងលើ ។

[69] សរុបមក មានបទបញ្ញត្តិចំនួន៩ ក្នុងក្រមព្រហ្មទណ្ឌ ដែលប៉ះពាល់ដល់សិទ្ធិនៃសេរីភាពក្នុងការបញ្ចេញមតិ ដូចជា៖ បទបរិហារកេរ្តិ៍ជាសាធារណៈ (មាត្រា៣០៥ ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩) បទជេរប្រមាថជាសាធារណៈ (មាត្រា៣០៧) បទប្តឹងបរិហារបង្កាច់កេរ្តិ៍ (មាត្រា៣១១) ការញុះញង់ ដែលនាំឲ្យមានការប្រព្រឹត្ត ឬមិននាំឲ្យមានការប្រព្រឹត្តបទល្មើសក៏ដោយ (មាត្រា៤៩៥) ការញុះញង់ឲ្យមានការរើសអើង (មាត្រា៤៩៦) បទប្រមាថ (មាត្រា៥០២) បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីដាក់សម្ពាធលើយុត្តាធិការ (មាត្រា៥២២) បទធ្វើឲ្យបាត់ជំនឿទុកចិត្តលើសេចក្តីសម្រេចរបស់តុលាការ (មាត្រា៥២៣) និងបទប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ (មាត្រា៥២៤) ។

[70] កាលពីមុន មានករណីដែលអ្នកសារព័ត៌មានត្រូវបានគំរាមកំហែង ឬសូម្បីតែត្រូវសម្លាប់ក្នុងកាលៈទេសៈដែលមិនច្បាស់លាស់ ។ សូមអាន ម.ស.ម.ក និងអ្នកទាំងអស់ កំណត់សម្គាល់បន្ថែមលេខ៦០ ទំព័រ១០។

[71] សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០ ដកស្រង់សម្តីរបស់ លោក មឿន ចាន់ណារិទ្ធ នាយកវិទ្យាស្ថានកម្ពុជាដើម្បីការសិក្សាផ្នែកព័ត៌មាន ក្នុងអត្ថបទរបស់ ប៊ុន ថារម្យ "ទាហានដើម្បីការបញ្ចេញមតិដោយសេរី" ។

ជាពិសេសពាក់ព័ន្ធនឹងករណីកាប់ព្រៃឈើខុសច្បាប់ ។[72] អ្នកសង្កេតការណ៍បានចែកជាក្រុម មិនដឹងថាតើចំណុចនេះឆ្លុះបញ្ចាំងពីការគំរាមកំហែងរបស់អ្នកប្រព្រឹត្តបទល្មើសដើម្បីគំរាមអ្នកសារព័ត៌មាន ឬ ក៏ឆ្លុះបញ្ចាំងពីកំហុសរបស់អ្នកសារព័ត៌មានដែលប៉ុនប៉ងទាញយកប្រយោជន៍ពីការបង្ក្រាបរបស់រដ្ឋាភិបាល ។ លោក សំរិទ្ធ ដួងហាក់ អតីតអនុប្រធានរបស់ សមាគមការពារអ្នកសារព័ត៌មានកម្ពុជា បាននិយាយថាលោកសង្ស័យអ្នកសារព័ត៌មានមួយចំនួនមានទោសកំហុសដោយសារការជំរិតទារប្រាក់ពិតមែន ។[73] ការអនុវត្តតាមវិជ្ជាជីវៈរបស់សារព័ត៌មានដែលទន់ខ្សោយ និងថ្លៃឈ្នួលដែលតិចតួច អាចជាកត្តាចូលរួមធ្វើឲ្យអ្នកសារព័ត៌មានទទួល ឬស្នើសុំថវិកាបែបនោះ ។ មិនថាការពិតបែបណានោះទេ រឿងបែបនេះបានលើកជាសំណួរចំពោះបូរណភាព និងឯករាជ្យភាពរបស់អ្នកសារព័ត៌-មានមួយចំនួនដែលធ្វើការនៅកម្ពុជា ។ ចំណុចនេះក៏ប៉ះពាល់ដល់លទ្ធភាពទទួលបានព័ត៌មានត្រឹមត្រូវ និងមិនលម្អៀងរបស់សាធារណជនផងដែរ ។

## ៥.៣ សេរីភាពខាងព័ត៌មាន

និតិកម្មផ្នែកសេរីភាពខាងព័ត៌មាន គួរតែស្របជាមួយនឹងច្បាប់ស្តីពីរបបសារព័ត៌មាន និងអាចផ្តល់ជាយន្តការបន្ថែមសម្រាប់អ្នកសារព័ត៌មាន ដើម្បីទទួលបានព័ត៌មានដ៏ត្រឹមត្រូវដោយស្របច្បាប់ ។ ច្បាប់នេះ ក៏គួរតែអាចធានាឲ្យមានសេរីភាព និងសុវត្ថិភាពចំពោះអ្នកសារព័ត៌មាន និងផ្តល់ការការពារពីបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ។ ច្បាប់ទាំងនោះ គួរតែរក្សានូវគោលការណ៍ ការបើកចំហជាអតិបរមា សម្រួបឲ្យមានការបើកចំហរបស់រដ្ឋាភិបាល និងធានាឲ្យមានហេតុផលដែលទទួលយកបានសម្រាប់ការបដិសេធមិនផ្តល់ព័ត៌មាន ហើយបង្កើតស្ថាប័នតាមដានដើម្បីត្រួតពិនិត្យមើលរាល់ការបដិសេធនូវលទ្ធភាពទទួលបានព័ត៌មាន ។

ជាថ្មីម្តងទៀត ច្បាប់ស្តីពីសេរីភាពខាងព័ត៌មានគួរតែរួមជាមួយការផ្លាស់ប្តូរអាកប្បកិរិយារបស់មន្ត្រីរដ្ឋាភិបាលក្នុងការមើលឃើញពីសារៈសំខាន់របស់សេរីភាពខាងព័ត៌មាន និងឆន្ទៈក្នុងការអនុលោមតាមសំណើរបស់អ្នកសារព័ត៌មាន។ ស្របពេលដែលការតែងតាំងអ្នកនាំពាក្យនៃក្រសួងនីមួយៗគឺជាជំហានដ៏វិជ្ជមានឆ្ពោះទៅកាន់ការព្រមទទួលស្គាល់នូវសេរីភាពខាងព័ត៌មាន ការផ្លាស់ប្តូរវប្បធម៌គឺនៅតែតម្រូវឲ្យមាន ដើម្បីឲ្យអ្នកសារព័ត៌មានអាចអនុវត្តតាមតួនាទីដ៏សំខាន់របស់ខ្លួនក្នុងលទ្ធិប្រជាធិបតេយ្យ ។ យោងតាមសេរីភាពខាងព័ត៌មាន និងសារព័ត៌មាន យើងសូមផ្តល់អនុ-សាសន៍មួយចំនួនដូចខាងក្រោម ៖

---

[72] ឧទាហរណ៍ អ្នកសារព័ត៌មានរបស់សារព័ត៌មានកោះសន្តិភាព លោក ស៊ីម សំណាង ត្រូវបានចាប់ឃុំក្នុងគុលាការខេត្តសៀមរាប អស់រយៈពេលរាប់ខែបន្ទាប់ពីម្ចាស់ឃ្លាំងម្នាក់ចោទប្រកាន់រូបគាត់ពីបទប៉ុនប៉ងជំរិតទារប្រាក់ បន្ទាប់ពីគាត់បានគំរាមបញ្ចេញព័ត៌មានពីប្រតិបត្តិការរបស់ម្ចាស់ឃ្លាំង ប្រសិនបើម្ចាស់ឃ្លាំងមិនព្រមប្រគល់ប្រាក់ឲ្យគាត់ទេនោះ។ ក្នុងខែឧសភា ឆ្នាំ២០១០ អ្នកសារព័ត៌មានបីនាក់ មកពីខេត្តកំពង់ចាម ត្រូវបានចោទប្រកាន់ពីបទជំរិតទារប្រាក់ពីអ្នកលក់ឈើ ម៉ី គីមហួន ។ មានការចោទប្រកាន់ថា អ្នកសារព័ត៌មានទាំងនោះ នឹងផ្សព្វផ្សាយព័ត៌មានដែលលោកស្រីបានលក់ឈើខុសច្បាប់ ប្រសិនបើលោកស្រីមិនព្រមប្រគល់ប្រាក់ចំនួន ៣.០០០ដុល្លារមកឲ្យពួកគេទេនោះ។ សូមអានសារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្ត៍ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១០ "បណ្តឹងស្តីពីការជំរិតទារប្រាក់កើនឡើង" ។

[73] ដូចខាងលើ ។

## អនុសាសន៍

- គ្រប់ទម្រង់សារព័ត៌មានទាំងអស់ គួរតែមានលទ្ធភាពទទួលបានព័ត៌មាន និងគួរតែត្រូវបានអនុញ្ញាតឲ្យចែកចាយព័ត៌មាន ។
- ត្រូវបង្កើតអាជ្ញាធរផ្នែកផ្សព្វផ្សាយដ៏ឯករាជ្យមួយ ដើម្បីធានាឲ្យមានពហុភាពនៃសារព័ត៌មាន ។
- ក្រមព្រហ្មទណ្ឌ ជាពិសេសបញ្ញត្តិដែលបានគំរាមកំហែងដល់សិទ្ធិសេរីភាពបញ្ចេញមតិ គួរតែត្រូវកែប្រែដើម្បីធានាដល់សេរីភាពបញ្ចេញមតិ ។
- រដ្ឋាភិបាល គួរបញ្ឈប់ការប្រើប្រាស់ក្រមព្រហ្មទណ្ឌក្នុងការដាក់ទោសដល់អ្នកសារព័ត៌មាន ។ ចំពោះទោសកំហុសផ្សេងៗគួរតែត្រូវបានវិនិច្ឆ័យក្នុងក្រមរដ្ឋប្បវេណី ដូចមានចែងក្នុងច្បាប់ស្តីពីរបបសារព័ត៌មានជាដើម ។
- បទបរិហារកេរ្តិ៍គួរតែដាក់ទៅក្នុងក្រមរដ្ឋប្បវេណី ។
- ក្រសួងមន្ទីរ និងស្ថាប័នសាធារណៈទាំងអស់ គួរតែត្រៀមខ្លួនជាស្រេចដើម្បីផ្តល់នូវលទ្ធភាពទទួលបានព័ត៌មានដែលរដ្ឋាភិបាលកាន់កាប់ ទៅដល់អ្នកសារព័ត៌មានទាំងអស់ដូចមានចែងក្នុងច្បាប់ ។
- រដ្ឋាភិបាល គួរតែធានាថាគ្រប់ក្រសួងទាំងអស់មានអ្នកនាំពាក្យដែលត្រូវបានតែងតាំងដើម្បីឆ្លើយតបចំពោះសំណួររបស់សាធារណជន និងបណ្តាញសារព័ត៌មាន រួមទាំងអ្នកនាំពាក្យមួយចំនួនដែលមានឯកទេសដើម្បីនិយាយពីបញ្ហាជាក់លាក់ផងដែរ ។ ក្រសួងនីមួយៗគួរតែធានាថាអ្នកនាំពាក្យទាំងនោះ ទទួលបានការបណ្តុះបណ្តាល និងមានព័ត៌មានផ្តល់ឲ្យទៅអ្នកនាំពាក្យទាំងនោះបានគ្រប់គ្រាន់តាមតម្រូវការ ។
- ក្រសួងព័ត៌មាន គួរតែផ្តល់ការណែនាំនៅពេលដែលលទ្ធភាពទទួលបានព័ត៌មានត្រូវបានបដិសេធចោល ដូចមានចែងក្នុងមាត្រា៥ នៃច្បាប់ស្តីពីរបបសារព័ត៌មាន។ សេចក្តីណែនាំបែបនោះ គួរតែព្រាងឡើងដើម្បីឲ្យស្របទៅនឹងគោលការណ៍បើកចំហជាអតិបរមា ។
- ត្រូវតែមានវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មានដើម្បី ៖

- ផ្តល់ឲ្យមានបណ្តឹងសារទុក្ខសម្រាប់ការត្រួតពិនិត្យដោយឯករាជ្យ និងដំណើរការប្តឹងឧទ្ធរណ៍ចំពោះការបដិសេធមិនផ្តល់នូវព័ត៌មាន។
- បង្កើតនូវភ្នាក់ងារតាមដានឯករាជ្យ ឬស្ថាប័នដើម្បីតាមដានលទ្ធភាពទទួលបានព័ត៌មាន និងត្រួតពិនិត្យលើការបដិសេធមិនព្រមបញ្ចេញព័ត៌មាន។

- អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការជាមួយអ្នកសារព័ត៌មាន គួរតែផ្តល់វគ្គបណ្តុះបណ្តាលដើម្បីធានាថាអ្នកសារព័ត៌មានទាំងអស់ មានបំពាក់ជាមួយនឹងជំនាញអ្នកសារព័ត៌មានស៊ើបអង្កេតដែលចាំបាច់ និងអាចចែកចាយព័ត៌មានទាំងនេះឲ្យបានត្រឹមត្រូវ។

# ៦. សេរីភាពខាងព័ត៌មាន និងនីតិរដ្ឋ

ខណៈដែលសង្គមមួយកំពុងតែដើបពីសង្គ្រាមនោះ ជាការចាំបាច់ដែលកម្ពុជាត្រូវបានស្តារឡើងវិញនូវនិតិរដ្ឋ ។ នេះគឺជាគោលដៅចម្បងមួយក្នុងចំណោមគោលដៅនានារបស់រដ្ឋាភិបាល ហើយអាចឆ្លុះបញ្ចាំងតាមរយៈយុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដែលបានចែងថា ការអភិវឌ្ឍន៍និតិរដ្ឋជាចំណុចគន្លឹះមួយនៃកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ។[74] មូលដ្ឋានគ្រឹះក្នុងការស្តារឡើងវិញនូវនិតិរដ្ឋ ហើយដែលផ្ទុយស្រឡះពីការគ្រប់គ្រងដោយច្បាប់នោះ គឺតម្លាភាពក្នុងការវិវត្តផ្នែកច្បាប់ ការទទួល បាន និងយល់ដឹងអំពីច្បាប់ និងតម្លាភាពក្នុងការអនុវត្តន៍ច្បាប់នោះផងដែរ ។

## ៦.១ តម្លាភាពក្នុងដំណើរការនីតិបញ្ញត្តិ

លទ្ធភាពដែលភាគីពាក់ព័ន្ធ មានដូចជាមេធាវី អ្នកសិក្សាអប់រំ អ្នកតាក់តែងច្បាប់ អង្គការសង្គមស៊ីវិល និងពលរដ្ឋពាក់ព័ន្ធដទៃទៀត អាចទទួលបានសេចក្តីព្រាងច្បាប់នានានោះ គឺ ជាចំណុចគន្លឹះ ក្នុងការធានាថាច្បាប់ដែលនឹងត្រូវបានអនុម័តដោយរដ្ឋាភិបាលនោះ ឆ្លើយតបគ្រប់គ្រាន់ដល់តម្រូវការ និងផលប្រយោជន៍របស់សង្គម ហើយច្បាប់ទាំងនោះនឹងមិនបំពានដល់សិទ្ធិពលរដ្ឋ ។ រដ្ឋាភិបាលដែលបើកចំហមួយ ដូចបានលើកឡើងក្នុងគោលការណ៍សេរីភាពខាងព័ត៌មាន ទាមទារឲ្យដាក់សេចក្តីព្រាងច្បាប់នានាឲ្យសាធារណជនអាចរកមើលបាន ដែលគោលបំណង និងខ្លឹមសារនានានៃច្បាប់ទាំងនោះ អាចត្រូវបានជជែកវែកញែក ក៏ដូចគ្នានឹងផលប៉ះពាល់នានារបស់ច្បាប់ទាំងនោះក៏ត្រូវបានពិភាក្សាយ៉ាងយកចិត្តទុកដាក់ផងដែរ ។

វប្បធម៌នៃការលាក់បាំង ហាក់ដូចជាចាក់ស្រេះក្នុងដំណើរការនីតិបញ្ញត្តិនៅប្រទេសកម្ពុជា ដោយហេតុថា លទ្ធភាពទទួលបានព័ត៌មាន មុនពេលដែលច្បាប់នានាត្រូវបានអនុម័តនោះ ត្រូវបានរឹតបន្តឹងយ៉ាងខ្លាំង ហើយក្នុងករណីខ្លះ ត្រូវបានរឹតបន្តឹងពីបីថ្ងៃមុនដែលច្បាប់នោះ ត្រូវបានលើកយកមកពិភាក្សាថែមទៀតផង ។ ករណីនេះកើតឡើង នៅពេលដែលសេចក្តីព្រាងច្បាប់ដែលចោទជាសំណួរនោះ ត្រូវបានគេយល់ថាមានចំណុចរសើបផ្នែកនយោបាយ ។ ជាឧទាហរណ៍ ខណៈដែលក្រសួងមហាផ្ទៃបើកចំហ ចំពោះសេចក្តីព្រាងច្បាប់ស្តីពីការប្រើប្រាស់ទឹកអាស៊ីដក្នុងដំណើរការធ្វើសេចក្តីព្រាង[75] និងមានកិច្ចពិភាក្សាដ៏គួរឲ្យកត់សម្គាល់ពាក់ព័ន្ធនឹងច្បាប់ស្តីពី ការធ្វើបាតុកម្ម

[74] រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ឆ្នាំ២០០៤ មានចំណងជើងថា "ការទទួលបានព័ត៌មានច្បាប់នៅកម្ពុជា" ទំព័រ៦ ។

[75] សេចក្តីព្រាងច្បាប់អាស៊ីដត្រូវបានបើកចំហទៅកាន់សារព័ត៌មាន និងអង្គការសង្គមស៊ីវិលជាក់លាក់មួយចំនួន ។ សូមអានសារព័ត៌មាន ឌឹ ខេមបូឌា ដេលី ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១០ "សេចក្តីព្រាងច្បាប់អាស៊ីដជិតរួចរាល់ហើយ មន្ត្រីម្នាក់បាននិយាយ" និងសារព័ត៌មាន ឌឹ ខេមបូឌា ដេលី ថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១១ "សេចក្តីព្រាងច្បាប់អាស៊ីដថ្មីកាត់បន្ថយទោស

### ទិន្នន័យឯកសារច្បាប់

- អង្គការយូអ៊ិនឌីភី ចងក្រងកម្រងឯកសារច្បាប់ជាតិជាបីភាសារថតចម្លងលើថាសចម្លងឯកសារ ប៉ុន្តែនៅពេលដែលថវិកាជំនួយត្រូវបានបញ្ចប់ កម្រងឯកសារនេះមិនត្រូវបានគេធ្វើបច្ចុប្បន្នភាពនោះទេ តាំងពីឆ្នាំ១៩៩៨មកម្លេះ ។
- ធនាគារពិភពលោក បានឧបត្ថម្ភ ទស្សនាវដ្តី និងក្រុមប្រឹក្សាអមចៅក្រម ក្នុងការផ្សព្វផ្សាយកម្រងច្បាប់ទ្រង់-ទ្រាយតូចមួយ ក្នុងអំឡុងឆ្នាំ១៩៩៩ដល់ ឆ្នាំ២០០១ ។
- វ៉េលអិល២/ការវិវឌ្ឍន៍នៃអ៊ិនធើណេតសម្រាប់ច្បាប់អាស៊ាន ផ្សព្វផ្សាយកម្រងច្បាប់ជាតិមួយ តែកម្រងនោះមិនមានលក្ខណៈគ្រប់គ្រាន់នៅឡើយ ។
- ឧត្តមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិ ស្ដីពីសិទ្ធិមនុស្សនៅកម្ពុជា មានបណ្ដុំកម្រងឯកសារច្បាប់ខ្មែរមួយ ប៉ុន្តែបណ្ដុំនេះមានត្រឹមឆ្នាំ២០០៦ ប៉ុណ្ណោះ ។
- គេហទំព័រសិទ្ធិមនុស្សកម្ពុជា (www.sithi.org) ដែលសម្របសម្រួលដោយម.ស.ម.ក មានគោលដៅផ្តល់ជាអាសយដ្ឋានរាវរកច្បាប់ជាតិមួយ ។ ក្នុងពេលសរសេររបាយការណ៍នេះ ផ្នែកច្បាប់ជាតិដែលបង្ហោះនៅលើគេហទំព័រនេះ ផ្ទុកច្បាប់ចំនួន៨០ សេចក្តីព្រាងច្បាប់៣ និងអនុក្រិតចំនួន២០ និងប្រកាសមួយចំនួនទៀត ។
- នាយកដ្ឋានរដ្ឋាភិបាលខ្លះ បានផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងជំនាញការងាររបស់ខ្លួន ។ ជាឧទាហរណ៍ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(www.ncdd.gov.kh/) បានបញ្ចូលព័ត៌មានលំអិតនៃច្បាប់ពាក់ព័ន្ធ និងមគ្គុទ្ទេសក៍នានា នៅលើវ៉ែបសាយរបស់ខ្លួន ។

ដោយសន្តិវិធី ចំណែកឯកិច្ចពិភាក្សាចំពោះច្បាប់ ដែលមានលក្ខណៈរសើបផ្នែកនយោបាយ ដូចជាច្បាប់ប្រឆាំងអំពើពុករលួយ ច្បាប់សហជីព និង ច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានរឹតបន្តឹង និងមិនសូវបើកចំហដែលអង្គការសង្គមស៊ីវិលជាច្រើនគិតថា កិច្ចពិភាក្សា បន្ទាប់ពីការផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ហើយគឺ "គ្មានអត្ថ-ន័យ" ។[76]

សម្រាប់ករណីសេចក្តីព្រាងច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលវិញ រដ្ឋាភិបាលមិនមានបំណងផ្សារភ្ជាប់ទំនាក់ទំនងជាមួយសាធារណជន និងអង្គការក្រៅរដ្ឋាភិបាលទេ ។ សេចក្តី-ព្រាងច្បាប់លើកទីមួយ នៃច្បាប់អង្គការត្រូវបានផ្សព្វផ្សាយ រយៈពេលពីរបីសប្តាហ៍មុនកិច្ចពិគ្រោះយោបល់ ជាមួយអង្គការសង្គមស៊ីវិល ហើយសម្រាប់សេចក្តីព្រាងច្បាប់លើកទីពីរវិញ ត្រូវបានផ្សព្វផ្សាយ ពីរថ្ងៃនៃថ្ងៃធ្វើការ មុនកិច្ចពិគ្រោះយោបល់ ជាមួយតំណាងអង្គការសង្គមស៊ីវិលមួយចំនួន។[77] បន្ទាប់ពីមានការផ្សព្វផ្សាយ សេចក្តីព្រាងលើក

---

ទណ្ឌ" ។ សូមបញ្ជាក់ផងដែរថាការពិភាក្សាពាក់ព័ន្ធនឹងច្បាប់នេះត្រូវបានផ្សាយផ្ទាល់ចេញពីរដ្ឋសភាលើបណ្តាញអ៊ីនធើណែត អាចមើលបាន ៖ : www.ustream.tv/channel/debate-from-cambodian-national-assembly ។

[76] ម.ស.ម.ក ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១ "ឯកសារគោលនយោបាយចេញផ្សាយដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ស្តីពីស្ថានភាពបច្ចុប្បន្នរបស់ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល" អាចអានបាន ៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=15&id=5&lang=khm ។

[77] របាយការណ៍របស់មជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់មិនយកកម្រៃ មានចំណងជើងថា "អ្នកឃ្លាំមើលច្បាប់ ៖ នៅកម្ពុជា" ចុះផ្សាយថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ អាចរកមើលបាន៖ www.incl.org/knowledge/ngolawmonitor/cambida.html. សូមមើលក្នុង ម.ស.ម.ក ដូចខាងលើ ទំព័រ ២ និង៣ ។

ទីបី ជាថ្មីម្តងទៀត គឺនៅតែមិនឃើញមានវត្តមាននៃកិច្ចពិភាក្សាដ៏មានអត្ថន័យ មុនពេលដែលសេចក្តីព្រាងលើកទីបួនត្រូវបានផ្សព្វផ្សាយ រដ្ឋាភិបាលបាន ប្រកាស ថាការពិភាក្សានេះនឹងត្រូវពន្យាររហូតដល់ ឆ្នាំ២០១៣ ។

ក្នុងអំឡុងពេលធ្វើសេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ ម.ស.ម.ក បានសរសេរលិខិតទៅកាន់ប្រធានរដ្ឋសភា រិះគន់អំពីឥរិយាបទលាក់បាំងក្នុងការតាក់តែងច្បាប់នេះ និងអំពីកង្វះកិច្ចពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល ។ សេចក្តីព្រាងច្បាប់ត្រូវបានផ្សព្វផ្សាយ ដល់គណបក្សប្រឆាំងនៅថ្ងៃទី០៤ ខែមិនា និងត្រូវលើកយកមកពិភាក្សាក្នុងថ្ងៃទី២០ ខែមិនា ឆ្នាំ២០១០ ដែលមិនបានផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់គណបក្សប្រឆាំងក្នុងការពិចារណា និងពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ មុនពេលសម័យប្រជុំក្នុងរដ្ឋសភាទៀតសោត គឺ*"ផ្ទុយស្រឡះនឹងគោលជំហអភិបាលកិច្ចមានតម្លាភាព ដែលច្បាប់ប្រឆាំងអំពើពុករលួយនេះគួរត្រូវបានតាក់តែងឡើង"* ។[78]

រាល់ច្បាប់ និងបទបញ្ញត្តិនានា គួរត្រូវបានផ្សព្វផ្សាយក្នុងទម្រង់កម្រងឯកសារផ្លូវការ ដូចមានចែងក្នុងមាត្រា១៣ នៃ*ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី* ។ ទោះជាយ៉ាងនេះក្តី ការផ្សព្វផ្សាយនានាគឺមិនត្រឹមតែមិនគ្រប់គ្រាន់នោះទេ ថែមទាំងមិនទៀងទាត់ផងដែរ ។[79] មានកិច្ចប្រឹងប្រែងជាច្រើនបានព្យាយាមចងក្រងជាទិន្នន័យលិខិតូបករណ៍នីតិបញ្ញត្តិនានា (សូមមើលអត្ថបទក្នុងប្រអប់) ប៉ុន្តែគ្មានប្រភពណាមួយ មានច្បាប់ពាក់ព័ន្ធទាំងអស់នោះទេ ។ លើសពីនេះនោះគឺថា ច្បាប់ជាតិពឹងផ្អែកជាច្រើនលើអនុក្រិត និង*"ប្រកាស"* ក្នុងការ បំពេញចន្លោះប្រហោងនានារបស់ច្បាប់ដែលបានអនុម័តហើយ ដែលឯកសារទាំងនេះកម្រត្រូវបានផ្សព្វផ្សាយណាស់ ។ អវត្តមាននៃកម្រងលិខិតូបករណ៍ពាក់ព័ន្ធ ដែលអាចទុកចិត្តបានធ្វើឲ្យមានផលលំបាកក្នុងការកំណត់លក្ខខណ្ឌច្បាប់ និងដំណើរការដែលច្បាប់ដោះស្រាយបញ្ហាទាំងឡាយក្នុងពេលជាក់លាក់ណាមួយ ។[80]

កង្វះនៃលទ្ធភាពទទួលបានការសម្របសម្រួល ឬព័ត៌មានដែលស៊ីសង្វាក់អំពីច្បាប់នានាដែលកំពុងរង់ចាំការអនុម័ត ឬច្បាប់ដែលមានស្រាប់ បានប៉ះពាល់ដោយផ្ទាល់ដល់លទ្ធភាពសាធារណជន ក្នុងការចូលរួមដោយពេញលេញ ក្នុងដំណើរការនីតិបញ្ញត្តិ ។ នេះក៏ផ្ទុយពីគោលការណ៍ស្របច្បាប់ ដែលទាមទារឲ្យពលរដ្ឋចាំបាច់ត្រូវមានគោលជំហមួយ ចំពោះច្បាប់ជាក់លាក់ណាមួយ ដើម្បីឲ្យពលរដ្ឋទទួលខុសត្រូវចំពោះការរំលោភបំពានច្បាប់ នៅពេលមានការរំលោភ

---

[78] លិខិតរបស់ម.ស.ម.ក ចុះផ្សាយនៅថ្ងៃទី១០ ខែមិនា ឆ្នាំ២០១០ ជូនទៅប្រធានរដ្ឋសភាពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ អាចរកមើលបាន ៖ www.cchrcambodia.org/English/add_press_release/press_release/cchr%20letter%20to%20the%20president%20of%20the%20national%20assembly%20concerning%20the%20draft%20anti-corruption%20law%20(english%20translation)(031010_1268279956).pdf

[79] ទស្សនាវត្តីស្តីអំពីព័ត៌មាន ច្បាប់ និងបច្ចេកវិទ្យា (ដាញ៉ែល អេដឡឺ) មានចំណងជើងថា "ការទទួលបានព័ត៌មានច្បាប់នៅកម្ពុជា ៖ ជំហានចាប់ផ្តើម និងឱកាសនាពេលអនាគត" ចុះផ្សាយថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៦ ទំព័រ២ ។

[80] ដូចលេខយោងខាងលើ ទំព័រ៣ ។

បំពានកើតឡើង ។ ធនាគារពិភពលោកបានធ្វើសេចក្តីរាយការណ៍ថា នៅប្រទេសកម្ពុជា ខណៈដែលពលរដ្ឋប្រមាណជា៩៤% គិតថាជាការចាំបាច់ដែលពួកគាត់ត្រូវបានជម្រាបអំពីច្បាប់ជាតិនោះ ពលរដ្ឋប្រមាណជា៧២% ដឹងឮតិចតួច ឬមិនដឹងទាល់តែសោះអំពីច្បាប់នានានោះ ។[81] តាមរយៈបទពិសោធន៍របស់ ម.ស.ម.ក ដែលធ្លាប់ផ្តល់វគ្គបណ្តុះបណ្តាលផ្នែកសិទ្ធិមនុស្ស និងច្បាប់ដែលជាផ្នែកមួយក្នុងកម្មវិធីផ្តល់អំណាចសហគមន៍ និងវគ្គបណ្តុះបណ្តាល ឃើញថាព័ត៌មានទាំងនេះមិនអាចស្វែងរកបាននោះទេ ឬក៏មិនមែនស្ថិតក្នុងទម្រង់ដែលប្រជាពលរដ្ឋភាគច្រើនអាចស្វែងរក និងអាចយល់បានឡើយ ។

## ៦.២ សិទ្ធិទទួលបានឯកសារសេចក្តីវិនិច្ឆ័យផ្នែកច្បាប់

នៅកម្ពុជា មិនមានច្បាប់ណាមួយរឹតបន្តឹងសិទ្ធិក្នុងការទទួលបានព័ត៌មានពាក់ព័ន្ធនឹងការវិនិច្ឆ័យរបស់តុលាការនោះទេ ។[82] ផ្ទុយទៅវិញ មាត្រា១៩ នៃក.អ.ស.ព.ន បានចែងថា ៖ *"ការចេញសាលក្រមទាំងអស់ អំពីរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ"* ហើយយោងតាមគោលការណ៍កែទម្រង់ច្បាប់ និងតុលាការរបស់រាជរដ្ឋាភិបាល ឆ្នាំ២០០៣ ក៏បានថ្លែងយ៉ាងច្បាស់ថា *"ការផ្សព្វផ្សាយសាលក្រមដែលមានស្រាប់ និងបង្កើតច្បាប់ពិសេសមួយ សម្រាប់ទទួលបានការបោះពុម្ព និងការផ្សព្វផ្សាយដីកា សេចក្តីសម្រេចចិត្ត និងការបញ្ជាសម្រេចរបស់តុលាការ ដើម្បីធានា ថាការវិនិច្ឆ័យរបស់តុលាការ អាចត្រូវបានគេងាយស្វែងរកតាមសេចក្តីត្រូវការ"* គឺជាវត្ថុបំណងមួយក្នុងចំណោមវត្ថុបំណងជាក់លាក់នានា ។[83]

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ផ្សព្វផ្សាយរាល់សាលក្រម និងសេចក្តីសម្រេចនានារបស់ខ្លួនតាមប្រព័ន្ធអ៊ីនធឺណេត ។ ស្រដៀងគ្នាដែរ ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ផ្សព្វផ្សាយសេចក្តីសម្រេចរបស់ខ្លួន នៅលើវែបសាយ (www.ccc.gov.kh /english/index.php) ហើយរាល់សាលក្រមតុលាការកំពូលត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណេតផងដែរ ប៉ុន្តែមានត្រឹមឆ្នាំ២០០៦ ប៉ុណ្ណោះ (www.supremecourt.gov.kh/) ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាស្ថាប័នស្រដៀងនឹងតុលាការ ហើយឯករាជ្យ ដែលទទួលបន្ទុកដោះស្រាយជម្លោះខាង ពលកម្មសមូហភាពនោះ ផ្សព្វផ្សាយរាល់សេចក្តីសម្រេចរបស់ខ្លួនតាមប្រព័ន្ធអ៊ីនធឺណេត ក្នុងទម្រង់ជាភាសាខ្មែរ និងភាសាអង់គ្លេស (ថ្វីបើរាល់ការជំនុំជម្រះគឺធ្វើឡើងជាឯកជនក៏ដោយ) ។ អធិប្បាយ ជុំវិញសារៈសំខាន់នៃការផ្សព្វផ្សាយសាលក្រម លោក ទូន ស៊ីផាន អាជ្ញាកណ្តាលមួយរូប នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល បានកត់សម្គាល់ថា "*ការទទួលបានព័ត៌មាន គឺជាស្នូលនៃគណនេយ្យភាព និងការសម្រេចចិត្តប្រកបដោយទំនួលខុសត្រូវ ។ ក្នុងនាមជាអាជ្ញាកណ្តាល យើងផ្សព្វផ្សាយសេចក្តីសម្រេចរបស់យើងសម្រាប់ជនគ្រប់រូបដឹងឮ ។ ពេលខ្លះពលរដ្ឋរិះគន់ពួកយើង ប៉ុន្តែទាំងនេះគឺមិនថ្មី*

[81] ធនាគារពិភពលោក ដូចលេខយោងលេខ៣៧ ទំព័រ២១

[82] ទស្សនាវត្តីស្តីអំពីព័ត៌មាន ច្បាប់ និងបច្ចេកវិទ្យា ដូចលេខយោងលេខ៧៤ ទំព័រ៣ដល់៤

[83] រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាពក្នុងប្រទេសកម្ពុជា ដូចលេខយោងលេខ៧៣ ទំព័រ៥ ។

*នោះទេ ។ នេះបានជម្រុញឲ្យយើងធ្វើការកែលំអរការងាររបស់យើងទៅវិញ ។ យើងព្យាយាមដាក់ចេញជាគំរូដល់ប្រព័ន្ធយុត្តិធម៌មួយ ដែលមើលទៅហាក់ដូចជាមានការភ័យខ្លាចកាលដែលពលរដ្ឋនឹងដឹងឮអំពីការសម្រេចចិត្តរបស់ពួកគេ" ។*[84]

នៅកម្ពុជា សាលក្រមតុលាការជាទូទៅមិនត្រូវបានដាក់ជាសាធារណៈទេ ហើយនៅពេលដែលការចេញសាលក្រមនេះមិនបានអានជាសាធារណៈ ដោយមានតែសាលក្រមសរសេរជាលាយលក្ខណ៍អក្សរនោះ ឯកសារនេះត្រូវបានចែករំលែកតែជាមួយភាគីពាក់ព័ន្ធរឿងក្តីប៉ុណ្ណោះ ។

បន្ថែមលើសនេះទៀតនោះ ក្នុងករណីដែលមានប្រយោជន៍ដល់រដ្ឋាភិបាល តុលាការហាក់ទំនងធ្វើការជំនុំជម្រះក្តីដោយបិទទ្វារ ដើម្បីធានាថាព័ត៌មានតិចតួចបំផុតនឹងត្រូវបានលេចឮដល់សាធារណជន ។ ជាឧទាហរណ៍ ករណីសវនាការមេដឹកនាំគណបក្សប្រឆាំងលោក សម រង្ស៊ី និងអ្នកភូមិពីររូប មកពីខេត្តស្វាយរៀង កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ជាប់ពីបទញុះញង់ជាតិសាសន៍ និងបំផ្លាញទ្រព្យសម្បត្តិ ត្រូវបានបិទមិនឲ្យអ្នកសារព័ត៌មាន អង្គការសិទ្ធិមនុស្ស និងសាធារណជនទូទៅចូលរួមឡើយ ។[85] ដោយយល់ឃើញនូវភាពរសើប នៃការកាត់ក្តីផ្នែកព្រហ្មទណ្ឌលើសមាជិកគណបក្សប្រឆាំង និងដោយហេតុថាលោក សម រង្ស៊ី ត្រូវបានកាត់ក្តីដោយកំបាំងមុខនោះ រឹតតែចាំបាច់ដែលទាមទារនូវការតាមដានពីសាធារណជនលើការកាត់ក្តីនេះថែមទៀត ។

តុលាការទាំងអស់នៅកម្ពុជា គួរយកគំរូតាមតុលាការកំពូល ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ក្រុម-ប្រឹក្សាអាជ្ញាកណ្តាល និងការអនុវត្តន៍របស់ អ.វ.ត.ក ដែលអាចត្រូវបានគេចាត់ទុក ថាជាតុលាការគំរូសម្រាប់តុលាការទាំងអស់នៅកម្ពុជាក្នុងករណីនេះ ។ ការផ្សព្វផ្សាយសាលក្រមនានា នឹងជម្រុញឲ្យមានអំណះអំណាងផ្នែកច្បាប់កាន់តែប្រសើរឡើងពីសំណាក់ចៅក្រម និងសម្រួលដល់ការតាមដានពីសាធារណជនទៅលើរាល់ការសម្រេចទាំងនោះថែមទៀត ។

សម្រាប់ប្រព័ន្ធតុលាការកម្ពុជា ដែលជាប្រព័ន្ធមួយបន្តរងការរិះគន់ពីបទពុករលួយ លំអៀងខាងនយោបាយ និងគ្រប់គ្រងដោយអង្គនិតិប្រតិបត្តិនោះ ការផ្សព្វផ្សាយសាលក្រមនឹងជួយបង្កើននូវទំនុកចិត្តពីសាធារណជន និងជួយឲ្យសម្រេចបាននូវការប្តេជ្ញាខាងធម្មនុញ្ញភាពក្នុងការបែងចែកអំណាចរវាងអង្គនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការ ។

## ៦.៣ សេរីភាពខាងព័ត៌មាន

ការដោះស្រាយកង្វះខាតក្នុងការទទួលបានព័ត៌មានផ្នែកច្បាប់ គឺជាមូលដ្ឋានគ្រឹះមួយក្នុងការជម្រុញឲ្យមានតម្លាភាព និងទំនុកចិត្ត ក្នុងស្ថាប័នតុលាការ និងនិតិប្រតិបត្តិ ហើយនឹងធានាបាននូវការអនុលោមតាមនិតិរដ្ឋ ។ គោលការណ៍កំណែទម្រង់ច្បាប់ និងតុលាការរបស់រដ្ឋាភិបាលកម្ពុជា

---

[84] ទស្សនាវដ្តីព័ត៌មាន ច្បាប់ និងបច្ចេកវិជ្ជា ។ដូចលេខយោងលេខ៧៨ ទំព័រ៤។

[85] របាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស មានចំណងជើងថា "សវនាការលើមេដឹកនាំគណបក្សប្រឆាំងលោក សម រង្ស៊ី គឺជានាកល្ខោន" ចុះផ្សាយថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ អាចរកមើលបាន ៖ www.hrw.org/en/news/2010/01/28/cambodia-opposition-leader-sam-rainsy-s-trial-farce.

បានបញ្ចូលវត្ថុបំណងយុទ្ធសាស្ត្រមួយ នូវបញ្ញត្តិដែលទាមទារឲ្យមានភាពប្រសើរឡើងនូវលទ្ធភាពទទួលបានព័ត៌មានច្បាប់ និងតុលាការ ហើយក៏បានធ្វើការកត់សម្គាល់នូវសារសំខាន់នៃលំហូព័ត៌-មាន ថាជាផ្នែកមួយនៃប្រព័ន្ធអភិបាលកិច្ចប្រកបដោយតម្លាភាព ។[86]

សូមចងចាំនូវបញ្ហាអនក្ខរកម្មនៅកម្ពុជាដូចដែលបានពិភាក្សាក្នុង ជំពូក៣ ដែលជាមធ្យោបាយមួយ ដើម្បីធានាលទ្ធភាពទទួលបានព័ត៌មាននោះ ពោលគឺការផ្សព្វផ្សាយច្បាប់ និងគោលការណ៍តាមរយៈវិទ្យុ ។ ឧទាហរណ៍ ម.ស.ម.ក បានផលិតឯកសារជាសម្លេងអំពីធម្មនុញ្ញច្បាប់ដីធ្លី និងគោលការណ៍យ៉ូយ៉ាកាតា ដែលជាគោលការណ៍អន្តរជាតិពាក់ព័ន្ធនឹងនិន្នាការភេទ និងអត្តសញ្ញាណយេឌ័រ ហើយឯកសារសម្លេងនេះត្រូវបានចាក់ផ្សាយតាមប្រព័ន្ធរលកធាតុអាកាសផងដែរ ។ យុទ្ធសាស្ត្រផ្សព្វផ្សាយនេះ ក៏អាចដោះស្រាយបញ្ហាដែលព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណេត មិនអាចទទួលបានដោយពលរដ្ឋភាគច្រើន ដោយសារថាអត្រាអ៊ីនធឺណេតនៅទាបនៅឡើយសម្រាប់ប្រទេសនេះ ។[87] បន្ថែមលើលនេះ ដូចបានពិភាក្សាក្នុងជំពូក ទីពីរខាងដើម *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ឆ្នាំ២០០១* និង *ច្បាប់អង្គការ* បានចែងអំពីក្តារព័ត៌មានជាមធ្យោបាយមួយ សម្រាប់ធានាថាសាធារណជនទូទៅត្រូវបានជម្រាបព័ត៌មាននានា ។

មធ្យោបាយមួយផ្សេងទៀតដើម្បីបំពេញចន្លោះប្រហោងខាងព័ត៌មាននោះ គឺតាមរយៈសង្គមស៊ីវិល ។ ជាឧទាហរណ៍ ពាក់ព័ន្ធនឹងសិទ្ធិកម្មករ សហជីព និងអង្គការពាក់ព័ន្ធ ព្រមទាំងគំនិតផ្តួចផ្តើមរបស់អង្គការសហប្រជាជាតិ/អង្គការពលកម្មអន្តរជាតិដូចជា *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដែលគាំទ្រដល់កិច្ចប្រឹងប្រែងរបស់សហជីព ដើម្បីបញ្ជ្រាបអំពីសិទ្ធិកម្មករ បានទទួលជោគជ័យគួរឲ្យកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំនេះ ក្នុងការលើកកម្ពស់ការគោរពសិទ្ធិកម្មករនៅកម្ពុជា តាមរយៈការផ្តល់ព័ត៌មានក្នុងទ្រង់ទ្រាយជាសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ។[88] ស្រដៀងគ្នានេះដែរ ម.ស.ម.ក ក៏បានរៀបចំវេទិកាសាធារណៈ និងវគ្គបណ្តុះបណ្តាលជាច្រើននៅពាស- ពេញប្រទេស ដើម្បីផ្តល់ព័ត៌មានពាក់ព័ន្ធនឹងច្បាប់សំខាន់ៗ ដល់សមាជិកសហគមន៍ដែលរងផល ប៉ះពាល់ដោយសារជម្លោះដីធ្លី និងបញ្ហាសិទ្ធិមនុស្សដទៃទៀត ធ្វើយ៉ាងណាដើម្បីអាចអភិវឌ្ឍសមត្ថភាព របស់សហគមន៍ ដាច់ស្រយាល និងងាយរងគ្រោះ ក្នុងការការពារ និងតស៊ូមតិសិទ្ធិរបស់ពួកគាត់ ។

យុទ្ធសាស្ត្រទាំងនេះ ជាមធ្យោបាយដ៏មានសារៈសំខាន់ ដើម្បីបំពេញចន្លោះប្រហោងខាងព័ត៌មាន និងដើម្បីជម្រាបព័ត៌មាន ដល់សាធារណជនអំពីសិទ្ធិរបស់ពួកគាត់ ។ រដ្ឋាភិបាល គួរគាំទ្រ និងសម្របសម្រួលយុទ្ធសាស្ត្រទាំងអស់នេះ ហើយនិងធ្វើការលើកកម្ពស់តម្លាភាព តាមរយៈការដាក់ឲ្យច្បាប់នានា និងព័ត៌មានសំខាន់ៗដទៃទៀត អាចងាយរកមើលបាន និងងាយយល់ ។ ទោះជា

---

[86] សូមមើលគោលការណ៍កំណែទម្រង់ច្បាប់និងតុលាការ ដែលបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣ មានចែងក្នុងវត្ថុបំណងយុទ្ធសាស្ត្រពិសេសទី៣ និងទំព័រ៧ ។

[87] របាយការណ៍របស់អង្គការយូអ៊ិនឌីភី ចុះផ្សាយឆ្នាំ២០០៩ មានចំណងជើងថា "ការប្រកួតប្រជែងរបស់កម្ពុជា ៖ ជំហានដើម្បីអភិវឌ្ឍ និងកាត់បន្ថយភាពក្រីក្រ" ទំព័រ៤៧ ។

[88] រោងចក្រកាន់តែប្រសើរនៅកម្ពុជា៖ www.betterfactories.org/ILO/aboutBFC.aspx?z=2&c=1.

យ៉ាងនេះក្តី មានសេចក្តីព្រួយបារម្ភចំពោះសេចក្តីព្រាងច្បាប់ចំនួនពីរថ្មីៗនេះ គឺច្បាប់សហជីព និងច្បាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ថាអាចនឹងរាំងស្ទះដល់ការងារសហជីព និងសង្គមស៊ីវិល ។ សេចក្តីព្រាងច្បាប់ទាំងនេះត្រូវបានរងការរិះគន់ ថាបានដាក់បន្ទុកតម្រូវការយ៉ាងធ្ងន់ធ្ងរដល់សហជីព និងអង្គការមិនមែនរដ្ឋាភិបាល ជាពិសេសចំពោះការចុះបញ្ជី ព័ត៌មានលម្អិតអំពីសមាជិក និងតម្រូវឲ្យមានរបាយការណ៍ ។[89] ទោះបីជាសេចក្តីព្រាងច្បាប់ទាំងពីរនេះ ត្រូវបានកែប្រែខ្លះៗនាពេលថ្មីៗនេះ ដើម្បីកាត់បន្ថយបន្ទុកការរាយការណ៍របស់សង្គមស៊ីវិលក៏ដោយ[90] ហើយដែលការអនុម័តច្បាប់អង្គការត្រូវបានព្យួររហូតដល់ឆ្នាំក្រោយ បន្ទាប់ពីការបោះឆ្នោតថ្នាក់ជាតិ គឺជាការចាំបាច់ណាស់សម្រាប់បុព្វហេតុសេរីភាពខាងព័ត៌មាន នៅពេលដែលលទ្ធភាពធ្វើការងារ និងផ្សព្វផ្សាយព័ត៌មានរបស់សហជីព និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានគេគោរព ។

ដើម្បីចូលរួមចំណែកលើកកម្ពស់សេរីភាពខាងព័ត៌មាន និងនីតិរដ្ឋ ម.ស.ម.ក ដាក់ចេញនូវអនុសាសន៍ដូចខាងក្រោម ៖

### អនុសាសន៍

- រដ្ឋាភិបាលគួរតែជំរុញឲ្យមានកិច្ចពិភាក្សាឲ្យបានទូលំទូលាយ ក្នុងការបង្កើតនូវគោលនយោបាយ ច្បាប់ និងវិធាន ។
- កម្រងឯកសារផ្លូវការ "កាសែត" របស់រដ្ឋាភិបាល គួរត្រូវបានផ្សព្វផ្សាយជាទៀតទាត់ ហើយទិន្នន័យច្បាប់ អនុក្រិត និងប្រកាសនានា គួរដាក់ផ្សាយតាមប្រព័ន្ធអ៊ីនធឺណេត និងធ្វើបច្ចុប្បន្នភាពឲ្យបានទៀងទាត់ ។
- រដ្ឋាភិបាល ក្រសួងនិងភាគីពាក់ព័ន្ធគួរពិចារណាប្រើប្រាស់ប្រព័ន្ធសារព័ត៌មាន ដូចជាវិទ្យុជាដើម សម្រាប់ផ្សព្វផ្សាយព័ត៌មាន ។
- រដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងនាយកដ្ឋានរដ្ឋាភិបាលដទៃទៀត គួររៀបចំវេទិកាសាធារណៈដើម្បីពិភាក្សាលើច្បាប់ គោលនយោបាយ និងវិធាននានា ដើម្បីផ្សព្វផ្សាយព័ត៌មានទាំងនេះដល់ថ្នាក់មូលដ្ឋាន ។

---

[89] អត្ថបទវិទ្យុសម្លេងសហរដ្ឋអាមេរិក ចុះផ្សាយថ្ងៃទី១៥ ខែមិនា ឆ្នាំ២០១១ "សហជីពជួបប្រជុំគ្នាពិភាក្សាលើចំណុចព្រួយបារម្ភចំពោះសេចក្តីព្រាងច្បាប់" អាចរកមើលបាន ៖ www.voanews.com/khmer-english/news/Unions-Meet-Over-Worries-in-Draft-Law-118006569.html; ម.ស.ម.ក ចុះផ្សាយថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០ ស្តីអំពី "សៀវភៅសង្ខេបសម្រាប់ម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធនានាស្តីអំពីច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងលំហាដែលរួមតូចសម្រាប់សង្គមស៊ីវិលនៅកម្ពុជា" ។

[90] សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្ត៍ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១១ "ការផ្លាស់ប្តូរដ៏ធំក្នុងសេចក្តីព្រាងច្បាប់ស្តីពីសហជីព" និង សារព័ត៌មាន ឌឹ ខេមបូឌា ដេលី ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ "រដ្ឋាភិបាលនឹងលើកលែងតម្រូវការចុះបញ្ជីចេញពី ច្បាប់អង្គការ" ។

- ក្រសួងយុត្តិធម៌គួរធ្វើការជាមួយតុលាការកម្ពុជាទាំងអស់ដើម្បីបង្កើតនូវប្រព័ន្ធមួយសម្រាប់ផ្សព្វផ្សាយរាល់សាលក្រមនានារបស់តុលាការនៅប្រទេសនេះ ។
- រាល់កិច្ចជំនុំជម្រះតុលាការគួរបើកជាសាធារណៈ (លើកលែងករណីមានកម្រិតមួយចំនួនដូចជាការពាក់ព័ន្ធនឹងផលប្រយោជន៍អនិតិជនដែលតម្រូវឲ្យករណីកាត់ក្តីនោះត្រូវធ្វើឡើងតាមរយៈកាមេរ៉ា) ។

# ៧. សេរីភាពខាងព័ត៌មាន ធនធាន និងដីធ្លី

ដូចអ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា បានធ្វើការកត់សម្គាល់ថា *"លក្ខណៈនៃការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីរបស់រដ្ឋាភិបាលសម្រាប់គោលបំណងផ្សេងៗបន្តនៅជាបញ្ហាដ៏ចម្បងមួយ"* ។[91] គិតមកត្រឹមខែឧសភា ឆ្នាំ២០១០ យោងតាមព័ត៌មានសាធារណៈរបស់ក្រសួងកសិកម្ម សម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់ឲ្យក្រុមហ៊ុនចំនួន៨៥ ដែលគ្របដណ្តប់ដីធ្លីសរុបទំហំ ៩៥៦.៦៩០ហិចតា ផ្តល់ជូនក្រុមហ៊ុនចំនួន៨៥ ។[92] នេះគឺខ្វាស់នឹងព័ត៌មានដែលដាក់ផ្សាយ ដោយរដ្ឋបាលព្រៃឈើនៃកម្ពុជា ដែលបានអះអាងថា យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០១០របស់ខ្លួន ដីសម្បទានសេដ្ឋកិច្ច ទំហំ១,៣លានហិចតា ត្រូវបានផ្តល់ជូន ។[93] របាយការណ៍ថ្មីៗរបស់ សមាគមអាដហុក បានបញ្ជាក់ថាមានដីចំនួន ២,៣លានហិចតាជាដីសម្បទានដែលមានចំនួនស្មើនឹង ១៤,៧% នៃផ្ទៃដីសរុបរបស់កម្ពុជា និងបានផ្តល់ទៅកាន់ក្រុមហ៊ុនជាតិ និងអន្តរជាតិចំនួន ២២៥ក្រុមហ៊ុន ។[94] ដោយយល់ថាភាពខុសគ្នានៃតួលេខនេះ អាចបណ្តាលមកពីពេលវេលាខុសគ្នា ក្នុងការចេញផ្សាយរបាយការណ៍នោះ នេះជាឧទាហរណ៍មួយ បង្ហាញពីភាពខ្វាស់គ្នាខាងព័ត៌មានដែលសាធារណជន គួរដឹងឮពាក់ព័ន្ធនឹងដីសម្បទាន ។

ដោយសារថា ការរំលោភបំពានលើសិទ្ធិដីធ្លីកើតឡើងជាបន្តបន្ទាប់ និងការអនុវត្តមិនច្បាស់លាស់ ជុំវិញឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជានោះ រឹតតែទាមទារឲ្យមានសិទ្ធិទទួលបានព័ត៌មានជាចាំបាច់ ។ ដំណើរគ្រប់គ្រង និងប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិរបស់ប្រទេសនេះ គួរត្រូវបានគេសម្រេច ដោយឈរលើផលប្រយោជន៍ពលរដ្ឋជាធំ ដោយគ្មានអំពើពុករលួយ និងដើរតាមនិយាមច្បាប់ ។ វិធីតែមួយគត់ដើម្បីធានានូវដំណើរការនេះ គឺមានតែការផ្តល់លទ្ធភាពទទួលបានព័ត៌មាន ដល់សាធារណជន ជុំវិញដំណើរការនេះនោះទេ ។ អវត្តមាននៃព័ត៌មាន មានន័យថាធនធានសំខាន់ៗ នឹងអាច *"ត្រូវបានស្រូបយកជាផលចំណេញបុគ្គល ជាជាងជាប្រយោជន៍ជាតិទាំងមូល"*[95] ហើយនេះអាចបណ្តាលឲ្យមានការគ្រប់គ្រងមិនច្បាស់លាស់លើថវិកា ដែលអាចនឹងយកមកបំពេញចន្លោះខ្វះខាតរវាងអ្នកដែលទទួលផលចំណេញពីដីសម្បទាន និងអ្នកដែលសិទ្ធិ

---

[91] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ចុះផ្សាយខែកញ្ញា ឆ្នាំ ២០១០ មានចំណងជើងថា "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា" លេខ A/HRC/15/46, ទំព័រ៨ អាចរកមើលបាន ៖ http://cambodia.ohchr.org/EN/PagesFiles/Reports/SR-SRSG-Reports.htm

[92] ដូចខាងលើ

[93] កាសែតឌឹភ្នំពេញបុស្តិ៍ ចុះផ្សាយថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ មានចំណងជើងថា "កម្ពុជា៖ ព្រៃឈើឋិតក្រោមការគំរាមកំហែង" ។

[94] វិទ្យុវីអូអេខ្មែរ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២ "ផ្ទៃដីប្រទេសកម្ពុជាជាង ១៥% ជាដីសម្បទាន យោងតាមរបាយការណ៍" អាចអានបាន ៖ http://www.voanews.com/khmer-english/news/Nearly-15-Percent-of-Cambodia-Under-Land-Concession-Report-143992206.html ។

[95] អង្គការឃ្លាំមើលពិភពលោក ចុះផ្សាយខែកុម្ភៈ ឆ្នាំ២០០៩ មានចំណងជើងថា "កម្ពុជា ៖ ប្រទេសសម្រាប់លក់" ទំព័រ៥២ ។

របស់ពួកគាត់ត្រូវបានគេមើលរំលង ។[96]

## ៧.១ ឧស្សាហកម្មនិស្សារណកម្ម

វិស័យឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជា កំពុងតែពង្រីកយ៉ាងសម្បើមក្នុងល្បឿនមួយគួរឲ្យកត់សម្គាល់ ហើយកំពុងតែបង្កើតជាចំណូលយ៉ាងខ្លាំងដែរ ។ នេះអាចជាសក្តានុពលសម្រាប់ជំរុញកម្ពុជាឲ្យងើបចេញពីភាពក្រីក្របាន ។ ថ្វីបើជាយ៉ាងនេះក្តី ពលរដ្ឋកម្ពុជាដែលដីធ្លីរបស់ខ្លួនត្រូវបានរងប៉ះពាល់ពីសកម្មភាពនៃឧស្សាហកម្មនេះ បានអះអាងថា ពួកគាត់បានដឹងព័ត៌មានតិចតួច ឬមិនបានទទួលព័ត៌មានអ្វីទាល់តែសោះ អំពីសកម្មភាពនានានេះ ហើយថាជីវភាពរស់នៅរបស់ពួកគាត់កំពុងតែប្រឈមនឹងហានិភ័យ ដោយសារតែកិច្ចរៀបចំបែបសម្ងាត់រវាងរដ្ឋាភិបាល និងក្រុមហ៊ុនឯកជន ។

មាត្រា៩ នៃអនុសញ្ញាប្រឆាំងអំពើពុករលួយអង្គការសហប្រជាជាតិ បានអំពាវនាវឲ្យមានការផ្សព្វផ្សាយព័ត៌មានជុំវិញកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលពាក់ព័ន្ធជាមួយនឹងរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងការដាក់អញ្ជើញឲ្យមានការដេញថ្លៃ និងលក្ខខណ្ឌ ដែលរដ្ឋាភិបាលនឹងផ្តល់កិច្ចសន្យាធ្វើការជាមួយផងដែរ ។ ថ្វីបើកម្ពុជាបានចុះសច្ចាប័នលើអនុសញ្ញាប្រឆាំងអំពើពុករលួយរបស់អង្គការសហប្រជាជាតិហើយក៏ដោយ ច្បាប់ជាតិមួយចំនួន មានលក្ខណៈខ្វាស់នឹងតម្រូវការផ្សព្វ-ផ្សាយព័ត៌មានទាំងនេះ ។

ជាឧទាហរណ៍ ច្បាប់ស្តីអំពីបរិស្ថាន បានចែងថា ក្រសួងបរិស្ថានត្រូវចែកចាយព័ត៌មានស្តីអំពីសកម្មភាពរបស់ក្រុមហ៊ុននៅពេលមានការស្នើសូម ហើយជម្រុញឲ្យមានការចូលរួម ពីសាធា-រណជនក្នុងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ។[97] ប៉ុន្តែ ច្បាប់ស្តីពីការគ្រប់គ្រងការរាវរកធនធានរ៉ែ ឆ្នាំ២០០១ បានចែងជាពិសេសថា រាល់ការអនុវត្ត របាយការណ៍ ផែនការ និងការកត់ សម្គាល់នានា ពាក់ព័ន្ធនឹងការរាវរក និងជីករក ត្រូវចាត់ទុកជាការសម្ងាត់ ។[98] នេះបង្ហាញនូវការបដិសេធដល់សិទ្ធិទទួលបានព័ត៌មាន ហើយនេះបញ្ជាក់យ៉ាងច្បាស់ ពីកង្វះតម្លាភាពក្នុងក្របខណ្ឌច្បាប់ទាំងស្រុង ។[99] ឧទាហរណ៍ របាយការណ៍ជាច្រើនបានបង្ហាញ ថាអំឡុងពេលផ្អាកសកម្មភាពបូមខ្សាច់[100] មានអាជ្ញាប័ណ្ណអនុញ្ញាតិបូមខ្សាច់មួយចំនួន ត្រូវបានផ្តល់ជូនក្រុមហ៊ុនដែលមានបណ្តាញជាសមាជិករដ្ឋាភិបាល ឬគណបក្សប្រជាជន ដែលការអនុញ្ញាតទាំងនេះមានភស្តុតាងតិច

---

[96] ដូចខាងលើ ទំព័រ៥ ។

[97] មាត្រា១៦ នៃច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ ។

[98] មាត្រា២០ នៃច្បាប់គ្រប់គ្រង និងការទាញផលពីធនធានរ៉ែ ឆ្នាំ២០០១ ។.

[99] អង្គការឃ្លាំមើលពិភពលោក ដូចលេខយោងលេខ៩២ ទំព័រ១៨ ។

[100] អត្ថបទកាសែតហ្វ៊ីងគុនបុស្ត៍ មានចំណងជើងថា "ការបូមខ្សាច់នៅកម្ពុជា គំរាមកំហែងដល់បរិស្ថាន និងឧស្សាហកម្មទេសចរណ៍សេដ្ឋកិច្ច" ចុះផ្សាយថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ អាចរកមើលបាន ៖ www.dredgingtoday.com, និងអត្ថបទមានចំណងជើងថា "កម្ពុជា៖ ការបូមខ្សាច់ដែលមានភាពចម្រូងចម្រាស់នៅទន្លេតាតៃនៅតែបន្ត" ចុះផ្សាយថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ ។

តូចបំផុតថា នឹងមានផលចំណេញដល់ជាតិ ឬចំណេញដល់ពលរដ្ឋ ។[101] ក្នុងតំបន់ដូចជាកោះកុង សកម្មភាពបូមខ្សាច់ កំពុងតែប៉ះពាល់ដល់ជីវិតពលរដ្ឋថ្នាក់មូលដ្ឋាន ដោយក្នុងនោះមានជាង២០០ គ្រួសារ ដែលរស់នៅអាស្រ័យផលនេសាទទ្រង់ទ្រាយតូច ត្រូវបានប៉ះពាល់ដោយផ្ទាល់ ។[102]

ពាក់ព័ន្ធនឹងការជីករ៉ែ មាត្រា២០ នៃច្បាប់គ្រប់គ្រងធនធានរ៉ែឆ្នាំ២០១១ បានចែងថាព័ត៌មាន ដែលពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន និងសង្គម នឹងអាចត្រូវបានផ្សព្វផ្សាយទៅសាធារណៈបាន ប៉ុន្តែលុះត្រាតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីដែលទទួលបន្ទុកផ្នែកធនធានរ៉ែ ។ ច្បាប់នានាពាក់ព័ន្ធនឹងវិស័យរ៉ែ មានលក្ខណៈកាន់តែស្រពិចស្រពិល នៅពេលដែលយកមកអនុវត្តចំពោះតំបន់ដីធ្លី ដែលត្រូវបានចាត់ចំណាត់ថ្នាក់ជាតំបន់ "ត្រូវបានការពារ" ដោយសារតែគុណតម្លៃនៃការត្រូវបានអភិរក្ស និងជីវៈចម្រុះរបស់តំបន់ទាំងនោះ ។ ប្រកាសស្តីពីតំបន់អភិរក្ស កាលពីឆ្នាំ១៩៩៤ បានអះអាងថា ការជីករករ៉ែដែលមាននៅក្នុងតំបន់អភិរក្សត្រូវបានហាមឃាត់ ។ ប៉ុន្តែ នៅខែសីហា ឆ្នាំ២០០៦ ប្រកាសនេះត្រូវបានផុតសុពលភាព ។ នេះបានប៉ះពាល់យ៉ាងខ្លាំងដល់ ៖ គម្រោងគ្រប់គ្រងតំបន់អភិរក្ស និងជីវៈចម្រុះរបស់ធនាគារពិភពលោក ដែលព្យាយាមការពារសហគមន៍ដែលរស់នៅឧទ្យានជាតិវីរជ័យ ដែលជាតំបន់អភិរក្សមួយ លាតសន្ធឹងពីខេត្តរតនគិរី ដល់ខេត្តស្ទឹងត្រែង ។ ប៉ុន្តែ នៅឆ្នាំ២០០៧ សម្បទានមួយត្រូវបានផ្តល់ជូនក្រុមហ៊ុនអូស្ត្រាលី ដែលទទួលបានសិទ្ធិរាវរកលើតំបន់ទំហំជាង ៥៩% ។[103] ការធ្វើវិសោធនកម្ម ឬចាត់ទុកជានិរាករណ៍នៃច្បាប់ទាំងនេះ មិនគួរត្រូវបានធ្វើឡើងដោយសម្ងាត់នោះទេ ។ ជាងនេះទៅទៀត ភាពស្មុគស្មាញរវាងច្បាប់ អនុក្រិត និងប្រកាស ដូចបានលើកឡើងក្នុងជំពូក៥ បានផ្តល់នូវចន្លោះប្រហោងសម្រាប់ការបកស្រាយផ្សេងៗ ទៅតាមតម្រូវការនៃការអនុវត្តសកម្មភាពទាំងនោះ ។

ព័ត៌មានដែលហាមឃាត់មួយចំនួនពាក់ព័ន្ធនឹងធនធានរ៉ែគឺអាចរកបាន ។ វែបសាយរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល[104] បានរួមបញ្ចូលនូវគោលនយោបាយ និងវិធានមួយចំនួន ដែលគ្រប់គ្រងលើវិស័យធនធានរ៉ែ ក៏ដូចជាបញ្ជីឈ្មោះក្រុមហ៊ុន និងសកម្មភាពរុករករបស់ពួកគេ ។

ឧស្សាហកម្មប្រេង ក៏ផ្តល់ព័ត៌មានតិចតួចបំផុតដល់សាធារណជនផងដែរ ។ អាជ្ញាធរប្រេងកាតជាតិកម្ពុជា ដែលប្រធានអាជ្ញាធរនេះមានកាតព្វកិច្ចរាយការណ៍ផ្ទាល់ ដល់នាយករដ្ឋមន្ត្រីនោះ[105] បានគ្រប់គ្រងរាល់ការអនុញ្ញាត្តិនានា ដល់ការផ្តល់ជូនដីសម្បទាន និងកិច្ចសន្យារាវរក ប្រេងឆៅ ។ ថ្វីបើអាជ្ញាធរនេះមានវែបសាយ (www.cnpa-cambodia.com) ជាសាធារណៈក៏ដោយ ក៏

---

[101] អង្គការឃ្លាំមើលពិភពលោក មានចំណងជើងថា "ការផ្ទេរខ្សាច់ ៖ តើតម្រូវការខ្សាច់កម្ពុជារបស់ប្រទេសសឹង្ហបុរីគំរាមកំហែងដល់ប្រព័ន្ធជីវសាស្ត្រ និងអភិបាលកិច្ចល្អយ៉ាងណាដែរ" ចុះផ្សាយខែឧសភាឆ្នាំ២០១០ ។

[102] កាសែតឌឹភ្នំពេញប៉ុស្តិ៍ មានចំណងជើងថា "ការបូមខ្សាច់នៅខេត្តកោះកុងបានបន្តសារជាថ្មី" ចុះផ្សាយថ្ងៃទី១១ ខែមករា ឆ្នាំ ២០១១ ។

[103] អង្គការឃ្លាំមើលពិភពលោក ដូចលេខយោងលេខ៩២ ទំព័រ២០ ។

[104] សូមអាន ៖ http://www.gdmar.gov.kh

[105] សូមមើលផ្នែក "រចនាសម្ព័ន្ធ" នៅលើវែបសាយរបស់អាជ្ញាធរប្រេងកាតជាតិកម្ពុជា អាចរកមើលបាន ៖ cnpa.gov.kh/index.php?option=com_content&view=article&id=45&Itemid=119.

ព័ត៌មានតិចតួចបំផុតដែលបានដាក់ផ្សាយដល់សាធារណជន ។ ផ្ទុយទៅវិញ ព័ត៌មានអំពីប្រតិបត្តិការ និងសកម្មភាពនានារបស់អាជ្ញាធរនេះ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ តាមរយៈសារព័ត៌មាន ឬការធ្លាយព័ត៌មានមិនផ្លូវការទៅវិញ ។ ឧទាហរណ៍ កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០ នាយករដ្ឋមន្ត្រីបានប្រកាសថា ក្រុមហ៊ុនតូតាល់ ដែលជាក្រុមហ៊ុនប្រេងឥន្ធនៈរបស់ប្រទេសបារាំង បានបង់ថវិកាចំនួន៨លានដុល្លាសហរដ្ឋអាមេរិក សម្រាប់មូលនិធិអភិវឌ្ឍន៍សង្គម ជាផ្នែកមួយនៃកិច្ចព្រមព្រៀងក្នុងការរាវរកប្រេងឆៅ ដែលមានស្តុកនៅក្នុង តំបន់ទឹកនៅកម្ពុជា ព្រមទាំងបន្ថែមចំនួន២០លានដុល្លាសហរដ្ឋអាមេរិកថែមទៀត សម្រាប់ជាលុយលើកទឹកចិត្តក្នុងការចុះហត្ថលេខា ។[106] ការបើកចំហបែបនេះជាកិច្ចមួយគួរឲ្យស្វាគមន៍ និងលើក ទឹកចិត្ត ហើយសង្ឃឹមថានេះជាគំរូមួយដល់អាជ្ញាធរ (និងក្រសួងពាក់ព័ន្ធផ្សេងទៀតរបស់រដ្ឋាភិបាល) ក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនានាជាសាធារណៈ ។ ទោះជាយ៉ាងនេះក្តី សំណួរនៅតែមាន ថាតើមូលនិធិនេះត្រូវបានដាក់បញ្ចូលទៅក្នុងគណនីជាតិ ដែរឬយ៉ាងណា ហើយក៏មិនមានព័ត៌មានណាផ្សេងទៀត ត្រូវបានផ្តល់ជូនអំពីការប្រើប្រាស់ថវិកាទាំងនោះផងដែរ ។

នៅខែវិច្ឆិកា ឆ្នាំ២០១១ មានការរាយការណ៍ថា សេចក្តីព្រាងច្បាប់ថ្មីនេះស្តីពីប្រេងកាត នៅមានចំណុចខ្វះខាតផ្នែកសំខាន់ ក្នុងការធានាថា រដ្ឋាភិបាលនឹងផ្សព្វផ្សាយរាល់ដំណើរការហិរញ្ញវត្ថុជាមួយក្រុមហ៊ុនប្រេង និងសាំង ។ មានការអះអាងថា លក្ខណៈដែលគួរឲ្យបារម្ភបំផុតពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់នេះ គឺកង្វះសេចក្តីយោងដល់តម្លាភាពខាងព័ត៌មាន ជុំវិញវិស័យប្រេងកាត ឬតម្រូវការឲ្យមានកិច្ចពិគ្រោះយោបល់ ជាមួយសាធារណជន ។ នេះក៏អាចបង្ហាញថារាល់ការចំណាយនានាពីសំណាក់ក្រុមហ៊ុនប្រេងសាំង ដល់រដ្ឋាភិបាល នឹងអាចត្រូវបានលុបចេញពីសៀវភៅបញ្ជីរបស់រដ្ឋាភិបាល ។[107] ម.ស.ម.ក ជឿជាក់ថា សេចក្តីព្រាងច្បាប់នេះគួរត្រូវបានគេកែតម្រូវដើម្បីធានាថារាល់ព័ត៌មានពាក់ព័ន្ធនឹងឧស្សាហកម្មប្រេងសាំង នឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។

## ៧.២ ការបណ្តេញចេញពីដីធ្លី

ប្រវត្តិសាស្ត្រថ្មីបំផុតរបស់ប្រទេសកម្ពុជា ដែលរួមទាំងការបំផ្លិចបំផ្លាញកម្មសិទ្ធិដីធ្លី និងការបណ្តេញចេញពីទីក្រុងក្នុងសម័យខ្មែរក្រហមនោះ បានបង្កជាភាពមិនច្បាស់លាស់ដល់ភាពជាម្ចាស់កម្មសិទ្ធិលើដីធ្លីនៅពាសពេញប្រទេសនេះ ។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ដីសម្បទានសេដ្ឋកិច្ច និងការប្រើប្រាស់ដីនានាផ្សេងទៀត ពាក់ព័ន្ធនឹងដីដែលត្រូវបានបំលែងជាដីពាណិជ្ជកម្មក្រោមភាពមិនច្បាស់លាស់នេះ ដែលជាលទ្ធផលបានប៉ះពាល់ដល់ពលរដ្ឋរាប់រយនាក់ ជាពិសេសពលរដ្ឋក្រីក្រនៅជនបទនិងទីក្រុង ក្រុមជនដែលងាយរងគ្រោះ និងដាច់ស្រយាល ។

---

[106] កាសែតឌឹភ្នំពេញបុស្តិ៍ មានចំណងជើងថា "ក្រុមហ៊ុនតូតាល់អះអាងទឹកប្រាក់ចំនួន៨លានដុល្លាសហរដ្ឋអាមេរិក សម្រាប់មូលនិធិសង្គម" ចុះផ្សាយថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ។
[107] កាសែតឌឹខេមបូឌាដេលី មានចំណងជើងថា "គ្មានបញ្ញត្តិតម្លាភាពក្នុងសេចក្តីព្រាងច្បាប់ស្តីពីប្រេងកាត" ចុះផ្សាយថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១១ ។

ច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រិតពាក់ព័ន្ធនានា មានផ្ទុកនូវបញ្ញត្តិជាច្រើន ដែលគាំពារដល់ការផ្សព្វផ្សាយព័ត៌មាន ។ ឧទាហរណ៍ មាត្រា៥៣នៃច្បាប់ភូមិបាល ចែងថាសម្បទានដី សេដ្ឋកិច្ច *"ត្រូវសំអាងលើលិខិតគតិយុត្តជាក់លាក់ ដែលបានចេញមុនការកាន់កាប់ដីដោយអាជ្ញាធរមានសមត្ថកិច្ច"* ។ អនុក្រិតស្តីពីសម្បទានដីសេដ្ឋកិច្ច ចេញនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ បានចែងថាសម្បទានដីសេដ្ឋកិច្ចនឹងត្រូវបានផ្តល់ជូន ក្នុងករណីដែលបានបំពេញតាមលក្ខណៈវិនិច្ឆ័យមួយចំនួន រួមដូចជាកិច្ចពិគ្រោះយោបល់ជាសាធារណៈ រវាងអាជ្ញាធរមានសមត្ថកិច្ច ជាមួយនិងពលរដ្ឋនៅមូលដ្ឋាន ។[108] គោលនយោបាយ *"ស្បែកតោ"* របស់រដ្ឋាភិបាល បានចែងបន្ថែមទៀតពីដីសម្បទានសង្គមកិច្ចដែលនឹងត្រូវផ្តល់ជូន រួមជាមួយដីសម្បទានសេដ្ឋកិច្ច ដែលអាចការពារបានយ៉ាងមានប្រសិទ្ធភាពនូវ *"ចំណុចខ្មៅ"* ដែលមានដូចជា សាលារៀន តំបន់អភិរក្ស មន្ទីរពេទ្យជាដើម ពីការអភិវឌ្ឍន៍ ។[109]

អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិលំនៅដ្ឋាន បានថ្លែងថា *"រាល់ក្រុមមនុស្សដែលនឹងអាចរងប៉ះពាល់...មានសិទ្ធិទទួលបានព័ត៌មាន កិច្ចពិគ្រោះយោបល់ពេញលេញ និងការចូលរួមគ្រប់ដំណើរការ (នៃការបណ្តេញចេញ) ទាំងស្រុង"* ។[110] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានគេហទំព័រស្តីអំពីសម្បទានដីសេដ្ឋកិច្ច នៅលើវែបសាយរបស់ខ្លួន ដែលមានបញ្ចូលនូវព័ត៌មានប្រវត្តិសម្បទាន និងក្រុមហ៊ុនដែលបានទទួលសម្បទាន ។[111] ខណៈដែលព័ត៌មានទាំងនេះ មានសម្លាក់សំខាន់បំផុត និងនេះជាជំហានមួយគួរឲ្យស្វាគមន៍ចំពោះការផ្សព្វផ្សាយព័ត៌មានអំពីសម្បទាននោះ វែបសាយនោះមានកម្រិតព័ត៌មាន អំពីម្ចាស់ក្រុមហ៊ុនដែលពាក់ព័ន្ធ និងគ្មានព័ត៌មានអំពីសម្បទានដែលកំពុងត្រូវបានគេត្រួតពិនិត្យនោះទេ ។ បញ្ញត្តិមួយចំនួនក្នុងច្បាប់ភូមិបាល មានចែងអំពីរដ្ឋបាលសុរិយោដីដែលមានបន្ទុកការងារពាក់ព័ន្ធនឹងការបញ្ជាក់អះអាងកម្មសិទ្ធិដីធ្លី ។ ទាក់ទងនឹងតួនាទីនេះ រដ្ឋបាលសុរិយោដីនេះ ត្រូវ *"កសាងសៀវភៅគោលបញ្ជីដី ហើយ[ធ្វើលេខាចារិក]ឈ្មោះកម្មសិទ្ធិករ និងរាល់ទិន្នន័យ ដែលប្រមូលបានទាក់ទងទៅនឹងលក្ខណៈរូប ទំហំ និងអត្តសញ្ញាណ"* នៃអចលនវត្ថុទាំងនោះ និងត្រូវ *"ប្រគល់ជូនជនដែលបានដាក់ពាក្យស្នើសូមប្លង់ថតចម្លង និងឯកសារព័ត៌មានទាក់ទងនឹងស្ថានភាពកម្មសិទ្ធិនោះ"* (មាត្រា២២៩) ។ ការិយាល័យសុរិយោដីថ្នាក់មូលដ្ឋាន ត្រូវជួយកាងារដល់រដ្ឋបាលសុរិយោដីថ្នាក់កណ្តាលក្នុងការ *"រក្សាទុកឯកសារ និងផ្តល់ព័ត៌មានដល់អ្នកស្នើសុំ"* (មាត្រា២៣២) ។ "ការសាកសួរព័ត៌មានសុរិយោដី មិនអាចត្រូវបានប្រកែក ចំពោះជនដែលមានការទាក់ទងឡើយ (មាត្រា២៤០) ។

---

[108] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស តំណាងពិសេសនៃអគ្គលេខាធិការស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា មានចំណងជើងថា "សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា ៖ ទស្សនទានខាងសិទ្ធិមនុស្ស" ។

[109] គណៈអភិវឌ្ឍន៍ និងស្តារប្រទេសកម្ពុជា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ថ្ងៃទី២ មិថុនា ២០១០ អាចរកបាន៖ http://www.cdc-crdb.gov.kh/cdc/third_cdcf/opening/shs_third_cdcf_en.htm

[110] របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីទីលំនៅគ្រប់គ្រាន់ ជាផ្នែកមួយនៃសិទ្ធិទទួលបានជីវភាពរស់នៅសមរម្យ លោក មីលូន កូថារី ចុះផ្សាយថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៧ A/HRC/4/18 កថាខ័ណ្ឌ៣៨ ។

[111] មើលវែបសាយ ៖ http:www.elc.maff.gov.kh/en/

ច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០០៩ ក៏បានចែងស្រដៀងគ្នានូវនិតិវិធីជាក់លាក់ឲ្យមានកិច្ចពិគ្រោះយោបល់ជាសាធារណៈចំពោះរាល់សកម្មភាពនានា និងការផ្សព្វផ្សាយព័ត៌មានអំពីគម្រោងនានា ។ ច្បាប់ស្តីពីអស្សាមិករណ៍នេះចែងថា មុននឹងធ្វើសំណើស្តីពីគម្រោងអស្សាមិករណ៍ គណៈ-កម្មាធិការអស្សាមិករណ៍ត្រូវធ្វើការអង្កេតជាសាធារណៈលើ ទ្រព្យសម្បត្តិនានា (មាត្រា១៦) ។ ក្នុងការរៀបចំការអង្កេតនេះ គណៈកម្មាធិការអស្សាមិករណ៍ *"ត្រូវរៀបចំចាត់ចែងធ្វើការពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងកម្រិតអាជ្ញាធរ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយក្រុមប្រឹក្សាឃុំសង្កាត់ និងតំណាងភូមិ ឬសហគមន៍ ដែលរងនូវអស្សាមិករណ៍ ដើម្បីផ្តល់ព័ត៌មានជាក់លាក់ ច្បាស់លាស់ និងទទួលបាននូវមតិយោបល់ ពីគ្រប់ភាគីពាក់ព័ន្ធ អំពីសំណើរនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ"*(មាត្រា១៦)។

បញ្ញត្តិនានាក្នុងច្បាប់ភូមិបាល និងច្បាប់អស្សាមិករណ៍ គួរឲ្យស្វាគមន៍ និងហាក់ដូចជាបានទទួលស្គាល់ នូវសម្លាក់សំខាន់ក្នុងការចែករំលែកព័ត៌មាន អំពីដីធ្លីដែលត្រូវបានពិចារណាសម្រាប់សម្បទាន ឬអស្សាមិករណ៍ ។ ទោះជាយ៉ាងនេះក្តី ស្លាក់ស្នាមទូទៅនៃ ជម្លោះដីធ្លី និងការបណ្តេញចេញជាច្រើននៅកម្ពុជា បង្ហាញឲ្យឃើញថាការពិតដែលច្បាប់ និងគោលនយោបាយទាំងអស់មិនត្រូវបានយកមកអនុវត្តឲ្យបានសមស្របនោះទេ ហើយនឹងតែងតែមានការខ្វះខាតការទទួលបានព័ត៌មាន ដែលគ្រួសាររងការប៉ះពាល់ជាច្រើន មិនត្រូវបានជម្រាបអំពីផែនការរបស់ក្រុមហ៊ុន និងមិនបានរាប់បញ្ចូលក្នុងការពិគ្រោះយោបល់ទាល់តែសោះ ។ ព័ត៌មានដែលបានផ្តល់ជូន ភាគច្រើនគឺមិនគ្រប់គ្រាន់ និង/ឬមិនត្រឹមត្រូវ ។[112] នៅពេលដែលការពិគ្រោះយោបល់ជាមួយសហគមន៍ ត្រូវបានរៀបចំឡើងមែននោះ ពួគគាត់តែងត្រូវបានគេកេងចំណេញ ឬបង្ខំ ៖ ករណីពលរដ្ឋនៅតំបន់បឹងកក់ជាតំបន់មួយនៅទីក្រុងភ្នំពេញដែលជាដីសម្បទានសេដ្ឋកិច្ច បណ្តាលឲ្យមានការបណ្តេញចេញ និងការជម្លៀសប្រជាពលរដ្ឋជិត ៤.០០០គ្រួសារបានលើកជាមតិ ក្នុងវេទិកាសាធារណៈមួយ ដែលរៀបចំដោយ ម.ស.ម.ក កាលពីខែធ្នូ ឆ្នាំ២០១០ បានអះអាង ថាថ្វីបើពួកគាត់បានព្យាយាមលើកកង្វល់ និងបណ្តឹងរបស់ខ្លួនឲ្យបានដឹងឮដល់អាជ្ញាធរថ្នាក់មូលដ្ឋាន និងនាយករដ្ឋមន្ត្រីហើយក៏ដោយ ពួកគាត់ត្រូវបានគំរាមកំហែង និងធ្វើមិនដឹងមិនឮ ហើយផ្ទុយទៅវិញ ពួកគាត់ ត្រូវបានគេរិះគន់ ពីមធ្យោបាយដែលខ្លួនព្យាយាមដាក់បណ្តឹងថែមទៀតផង ។

## ៧.៣ សេរីភាពខាងព័ត៌មាន

ភាពផ្ទុយគ្នាស្រឡះរវាងច្បាប់ពាក់ព័ន្ធ និងការអនុវត្តន៍ជាក់ស្តែងរបស់អ្នកពាក់ព័ន្ធ ក្នុងវិស័យឧស្សាហកម្មធនធានផ្សេងៗគ្នា ក្នុងការដាក់បង្ហាញព័ត៌មានជាសាធារណៈនោះសរឲ្យឃើញនូវតម្រូវការច្បាប់សេរីភាពខាងព័ត៌មានជាចាំបាច់ ។ ច្បាប់នេះគួរត្រូវកំណត់ឲ្យច្បាស់ ពីតម្រូវការផ្សព្វផ្សាយព័ត៌មានរបស់ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចចំពោះធនធានធម្មជាតិនៅកម្ពុជា ។[113]

---

[112] ម.ស.ម.ក ចុះផ្សាយថ្ងៃទីធ្នូ ឆ្នាំ២០១០ "របាយសង្ខេបស្តីពីអាជីវកម្ម និងសិទ្ធិមនុស្សនៅកម្ពុជា ៖សរសរស្តម្ភបី" ទំព័រ២ អាចរកមើលបាន ៖ www.cchrcambodia.org/English/add_report/reports/2010_11-30_bhr_report_eng.pdf.

[113] អង្គការឃ្លាំមើលពិភពលោក ដូចលេខយោងលេខ១១០ ទំព័រ១៩ ។

គោលនយោបាយ "វិមជ្ឈការ និងវិសហមជ្ឈការ" ដូចបានពិភាក្សាក្នុងជំពូក២ នៃរបាយការណ៍នេះ ជាឧទាហរណ៍វិជ្ជមានមួយក្នុងការទទួលបាននូវព័ត៌មាន ។ ថ្វីត្បិតថាគោលនយោបាយនេះផ្តោតតែលើហេដ្ឋារចនាសម្ព័ន្ធការងារ ជាជាងធនធាន និងដីធ្លី គោលនយោបាយនេះ ដែលបង្ហាញនិតិវិធីក្នុងការផ្សារភ្ជាប់ ទំនាក់ទំនងជាមួយជនរងផលប៉ះពាល់ អាចជាជំហានវិជ្ជមានមួយ សម្រាប់រដ្ឋាភិបាលគួរអនុវត្តតាម ។

ទោះជាយ៉ាងនេះក្តី ក្នុងបរិបទប្រទេសកម្ពុជា ហាក់ដូចជាមានការសន្មតក្នុងចំណោមអ្នកដឹកនាំ ថាកិច្ចពិគ្រោះយោបល់ និងការចែករំលែកព័ត៌មានលើវិស័យទាំងនេះ អាចនឹងធ្វើឲ្យកំណើនសេដ្ឋកិច្ចមានការយឺតយ៉ាវ ។ ប៉ុន្តែ ចំណូលដែលគ្រប់គ្រងយ៉ាងល្អ ដែលទទួលបានពីធនធានទាំងនេះ ជាការពិតគួរតែអាចជួយអភិវឌ្ឍប្រទេសនេះ ។ តម្លាភាព និងសេរីភាពខាងព័ត៌មាន អាចធានាថាប្រាក់ចំណូលនានា មិនត្រូវបានគ្រប់គ្រងមិនបានល្អ ហើយអ្នកទាំងឡាយដែលរងផលប៉ះពាល់ពីឧស្សាហកម្មទាំងនេះ ត្រូវបានការពារយ៉ាងល្អ ហើយរដ្ឋាភិបាលក៏អាចសម្រេចផែនការអភិវឌ្ឍន៍របស់ខ្លួនផងដែរ ។

ការដោះស្រាយករណីសហគមន៍អភិវឌ្ឍន៍មានជ័យ គឺឆ្លុះបញ្ចាំងពីចំណុចនេះ ។ កាលពីឆ្នាំ ១៩៩៧ សាលាក្រុងភ្នំពេញ ពលរដ្ឋ និងអង្គការជាតិនិងអន្តរជាតិ បានជួបពិភាក្សាគ្នាលើដំណោះស្រាយសម្រាប់ប្រជាពលរដ្ឋ១២៩គ្រួសារ ដែលរស់នៅលើដងផ្លូវជិតស្ថានទូតចិន ប្រចាំនៅទីក្រុងភ្នំពេញ ។ រដ្ឋាភិបាលចង់ផ្លាស់ប្តូរទីលំនៅគ្រួសារទាំងនេះ ទៅទីតាំងថ្មីជាផ្នែកមួយនៃការអភិវឌ្ឍន៍ទីក្រុង ។ ក្នុងការដោះស្រាយនេះ ពលរដ្ឋត្រូវបានផ្តល់ឱកាសឲ្យជ្រើសរើសទីតាំងដី និងដើរតួយ៉ាងសំខាន់ ក្នុងដំណើរការដោះស្រាយនេះ ។ មកដល់ឆ្នាំ២០០៦ សហគមន៍នេះបានរស់នៅ និងអាស្រ័យនៅទីតាំងថ្មីនេះចំនួនប្រហែលជា៧៥% ។[114] តម្លាភាពជុំវិញគម្រោង និងតម្រូវការអភិវឌ្ឍន៍ ទំនាក់ទំនងសកម្មជាមួយពលរដ្ឋ និងយុទ្ធសាស្ត្រច្បាស់លាស់ និងដាក់ជាសាធារណៈ ដើរតួនាទីសំខាន់ក្នុងការផ្តល់សុវត្ថិភាពដីធ្លី សម្រាប់ពលរដ្ឋដែលត្រូវបានគេបណ្តេញចេញ ហើយក៏អនុញ្ញាតឲ្យផែនការអភិវឌ្ឍន៍របស់រដ្ឋាភិបាល អាចដើរឆ្ពោះទៅមុខ ។ គួរកត់សម្គាល់ថា ការចំណាយសម្រាប់គម្រោងជាក់លាក់នេះត្រូវបានគេយល់ថាចំណាយខ្ពស់ (៧៨៥ដុល្លាសហរដ្ឋអាមេរិក សម្រាប់ក្នុងមួយគ្រួសារ) ប៉ុន្តែដំណើរការនេះត្រូវបានគេជឿជាក់ថាជាដំណើរការវិជ្ជមានមួយ ហើយគួរត្រូវបានជ្រើសជាគំរូសម្រាប់គម្រោងស្រដៀងគ្នា នាពេលអនាគត ។

ពាក់ព័ន្ធនឹងឧស្សាហកម្មនិស្សារណកម្មវិញ មានគំនិតផ្តួចផ្តើមអន្តរជាតិជាច្រើនផ្តោតលើការប្រើប្រាស់គោលការណ៍សេរីភាពខាងព័ត៌មាន ក្នុងការធានាថាធនធានធម្មជាតិត្រូវបានគេប្រើប្រាស់ដើម្បីជាប្រយោជន៍ទាំងអស់គ្នា ។ ក្នុងនោះមាន *គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម* ជួយគាំទ្រដល់ប្រទេសមានធនធានសម្បូរបែបក្នុងការលើកកម្ពស់អភិបាលកិច្ចលើធនធានធម្មជាតិ ជាពិសេសតាមរយៈការបញ្ជាក់ និងផ្សព្វផ្សាយរាល់ចំណាយរបស់ក្រុមហ៊ុន និងប្រាក់

[114] សមាគមធាងត្នោត ចុះផ្សាយខែធ្នូ ឆ្នាំ២០០៦ "អង្គហេតុ និងតួលេខ៖ ការផ្លាស់ទីតាំង ឬការបណ្តេញចេញ?" ទំព័រ២ ។

ចំណូលរដ្ឋដែលទទួលបានពីផលប្រេង ឧស្ម័ន និងរ៉ែ ។ *គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្ម-និស្សារណកម្ម* នេះ ទទួលស្គាល់ថា ការដែលសាធារណជនអាចទទួលបានព័ត៌មាន អាចជួយឲ្យប្រទេសនោះជៀសផុតពី "បណ្តាសារធនធាន" ដែលនេះជាប្រតិមតិមួយ ថាប្រទេស និងតំបន់ដែលមានធនធានសម្បូរបែបអាចប្រឈមនឹងផលលំបាកពីកំណើនសេដ្ឋកិច្ចទាប និងកំសោយខាងការអភិវឌ្ឍន៍ ដោយសារតែកត្តាផ្សេងៗគ្នា រួមទាំងការគ្រប់គ្រងមិនត្រឹមត្រូវលើធនធានដែលមាន និងអំពើពុករលួយផងដែរ ហើយនេះនឹងជួយជម្រុញមជ្ឈដ្ឋានវិនិយោគទុន និងបង្កើនកំណើនសេដ្ឋកិច្ច និងស្ថេរភាពសង្គមថែមទៀត ។[115] កម្ពុជាមិនទាន់ចូលជាសមាជិករបស់ *គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម* នៅឡើយ ប៉ុន្តែម.ស.ម.ក ជឿជាក់ថាការដែលចូលជាសមាជិកនេះ នឹងអាចផ្តល់ជាខែលការពារដ៏មានប្រយោជន៍មួយ ក្នុងការឃ្លាំមើលការប្រើប្រាស់ធនធាននៅកម្ពុជា ។

*សម្ព័ន្ធភាពផ្សព្វផ្សាយពីអ្វីដែលអ្នកបានចំណាយ* ជាបណ្តាញសកលមួយនៃអង្គការសង្គមស៊ីវិល ផ្តោតលើតម្លាភាពក្នុងវិស័យឧស្សាហកម្មប្រេង ឧស្ម័ន និងរ៉ែ ។ នាពេលថ្មីៗនេះអង្គការនេះបានស្វាគមន៍ ចំពោះការដាក់ចេញនូវវិសោធនកម្មលើច្បាប់កំណែទម្រង់ the Dodd-Frank Wall Street និងការពារអតិថិជនរបស់សហរដ្ឋអាមេរិក ។ វិសោធនកម្មនោះទាមទារឲ្យក្រុមហ៊ុនប្រេង ឧស្ម័ន និងរ៉ែទាំងអស់ធ្វើការផ្សព្វផ្សាយពីចំណាយរបស់ខ្លួន ដល់រដ្ឋាភិបាលសហរដ្ឋអាមេរិក និងរដ្ឋាភិបាលបរទេស ជាផ្នែកមួយក្នុងការបំពេញភារកិច្ចប្រចាំឆ្នាំ ចំពោះ*គណៈកម្មការភាគហ៊ុននិងប្តូរប្រាក់របស់សហរដ្ឋអាមេរិក* ដែលជាស្ថាប័នមួយគ្រប់គ្រងលើវិស័យហិរញ្ញវត្ថុសហរដ្ឋអាមេរិក ។ អាស្រ័យហេតុនេះ ក្រុមហ៊ុនត្រូវតែផ្សព្វផ្សាយ នូវរាល់ចំណាយរបស់ខ្លួន ដល់រដ្ឋាភិបាលនានា រួមទាំងរដ្ឋាភិបាលកម្ពុជាផងដែរ ។ ព័ត៌មាននេះក៏ត្រូវតែផ្សព្វផ្សាយជាសាធារណៈផងដែរ ហើយនេះត្រូវអនុវត្តចំពោះក្រុមហ៊ុនប្រេង ឧស្ម័ន និងរ៉ែទាំងអស់ដែលមានភាគហ៊ុនចុះបញ្ជី ជាមួយក្រុមហ៊ុនភាគហ៊ុនសហរដ្ឋអាមេរិក ហើយដោយរាប់បញ្ចូលទាំងក្រុមហ៊ុនអន្តរជាតិធំៗ នៅលើពិភពលោកដែលប្រតិបត្តិការរកស៊ីខាងប្រេង និងឧស្ម័ន និងក្រុមហ៊ុនរ៉ែដែលធំជាងគេចំនួនប្រាំបីក្នុងចំណោមក្រុមហ៊ុនធំជាងគេចំនួនដប់នៅលើពិភពលោកនេះ ។[116] ព័ត៌មានទាំងឡាយត្រូវផ្សព្វផ្សាយឲ្យសាធារណជនបានដឹងឮ ។ អាស្រ័យហេតុនេះហើយ បើទោះបីជារដ្ឋាភិបាលកម្ពុជាមិនបានអនុវត្តតាមនិយាមច្បាប់ពាក់ព័ន្ធនឹងសិទ្ធិទទួលបានព័ត៌មាន ជុំវិញវិស័យឧស្សាហកម្មនិស្សារណកម្មយ៉ាងណាក៏ដោយ ក៏ព័ត៌មានទាំងនេះ នាពេលអនាគត នឹងអាចរកមើលបានតាមមធ្យោបាយផ្សេងឯទៀតបាន ។

[115] អត្ថបទវិទ្យុសម្លេងអាមេរិក ចុះផ្សាយថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១០ មានចំណងជើងថា "កម្ពុជាជម្រុញឲ្យចូលរួមជាសមាជិកនៃគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម" អាចរកមើលបាន ៖ www.voanews.com/khmer-english/news/economy-business/a-40-2010-04-06-voa8-90235222.html.

[116] សម្ព័ន្ធភាពផ្សព្វផ្សាយពីអ្វីដែលអ្នកបានចំណាយ ចុះផ្សាយខែវិច្ឆិកា ឆ្នាំ២០១០ មានចំណងជើងថា "បញ្ញត្តិបើកបង្ហាញព័ត៌មានអំពីឧស្សាហកម្មនិស្សារណកម្មក្នុងច្បាប់កំណែទម្រង់ Dodd-Frank Wall Street និងការការពារអតិថិជន " អាចរកមើលបាន ៖ http://www.cgdev.org/doc/blog/globaldevelopment/PWYP%20Fact%20Sheet%20on%20Extractive%20Industries%20Transparency%20Provision.pdf.

ផ្សារភ្ជាប់នឹងសេរីភាពខាងព័ត៌មាន នឹងដីធ្លីនិងធនធាននៅកម្ពុជា ម.ស.ម.ក ស្នើនូវអនុសាសន៍ដូចខាងក្រោម ៖

## អនុសាសន៍

- រដ្ឋាភិបាលគួរចូលជាសមាជិក និងអនុវត្តនូវ *គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម ។*
- រដ្ឋាភិបាលគួរកែតម្រូវច្បាប់ពាក់ព័ន្ធនឹងដីធ្លី និងឧស្សាហកម្មនិស្សារណកម្ម ដែលខ្វាស់នឹងគោលការណ៍សេរីភាពខាងព័ត៌មាន ។ ឧទាហរណ៍ វិសោធនកម្មគួរធ្វើឡើងចំពោះច្បាប់គ្រប់គ្រងរ៉ែ ដើម្បីធានាថា ព័ត៌មានពាក់ព័ន្ធនឹងកិច្ចសន្យានានាត្រូវបានដាក់ផ្សាយជាសាធារណៈ ។
- រដ្ឋាភិបាលគួរបង្កើនការផ្សព្វផ្សាយរាល់កិច្ចសន្យានានាជាសាធារណៈ ហើយផ្តល់នូវព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ រួមទាំងធនធានប្រេង ឧស្ម័ន និងរ៉ែផងដែរ ។ ព័ត៌មានទាំងនេះ គួរត្រូវបានក្រសួងពាក់ព័ន្ធដាក់ផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណេត ។
- សេចក្តីព្រាងច្បាប់ស្តីពីប្រេងកាតគួរត្រូវបានកែតម្រូវដោយបញ្ចូលនូវបញ្ញត្តិអំពីតម្លាភាព និងកិច្ចពិគ្រោះយោបល់ជាសាធារណៈ ។
- រដ្ឋាភិបាលកម្ពុជា គួរផ្សព្វផ្សាយឲ្យបានទៀងទាត់ និងចែកចាយក្នុងទម្រង់ឯកសារបោះពុម្ព និងតាមវែបសាយរដ្ឋាភិបាល នូវព័ត៌មានទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច និងសង្គមកិច្ច ។ ពាក់ព័ន្ធនឹងសម្បទានដីនានា រដ្ឋាភិបាលគួរធានាថា កិច្ចពិគ្រោះយោបល់ជាសាធារណៈត្រូវបានប្រព្រឹត្តធ្វើឡើងដូចមានចែងក្នុងច្បាប់ភូមិបាល ។

# ៨. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

លទ្ធិប្រជាធិបតេយ្យ តម្រូវឲ្យមានពលរដ្ឋដែលដឹងឮ និងការដឹកនាំប្រកបដោយគណនេយ្យភាព ។ ដើម្បីសម្រេចបាននូវគោលដៅនេះ សិទ្ធិរបស់សាធារណជន ក្នុងការដឹងឮត្រូវតែបានការពារ និងត្រូវបានពង្រឹង ប្រកបដោយវិជ្ជមាន តាមរយៈច្បាប់សេរីភាពខាងព័ត៌មាន និងតាមរយៈការ អនុវត្តន៍យ៉ាងសកម្ម លើគោលការណ៍សេរីភាពខាងព័ត៌មាន ។ របាយការណ៍នេះ បានបង្ហាញថា មានការជឿនលឿនមួយចំនួន ក្នុងការធានាដល់លទ្ធភាព របស់សាធារណជនទទួលបានព័ត៌មាននៅកម្ពុជា ។ ជាឧទាហរណ៍ ការតែងតាំងអ្នកនាំពាក្យរបស់ក្រសួងនីមួយៗ ក្នុងការឆ្លើយតបសំណួររបស់អ្នកសារព័ត៌មាន និងផ្សព្វផ្សាយសាលក្រមតុលាការ និងសាលាកាត់ក្តីនានា ជាការវិវត្តន៍គួរឲ្យស្វាគមន៍ ក្នុងការឆ្ពោះទៅរកការទទួលបានព័ត៌មានដ៏ប្រសើរមួយ ។

ជំហានដែលបានធ្វើដំណើរឆ្ពោះទៅរកការអនុម័តច្បាប់ និងគោលការណ៍សេរីភាពខាងព័ត៌មាន ក៏ជាអ្វីដែលគួរឲ្យលើកទឹកចិត្តផងដែរ ។ ទោះជាយ៉ាងនេះក្តី ម.ស.ម.ក ព្រួយបារម្ភចំពោះកង្វះឆន្ទៈនយោបាយក្នុងការអនុម័តច្បាប់មួយ និងក្នុងការធានារចនាសម្ព័ន្ធ និងការអនុវត្តន៍ចាំបាច់ ដើម្បីគាំទ្រដល់ការអនុវត្តន៍ច្បាប់នេះ ។

ដោយសារតែធនធានមានកម្រិត ស្របពេលដែលការគ្រប់គ្រងលើធនធានទាំងនេះ មិនទាន់បានត្រឹមត្រូវផងនោះ ការផ្សព្វផ្សាយព័ត៌មានជាកិច្ចការប្រឈមសម្រាប់កម្ពុជា ។ ទោះជាយ៉ាងនេះក្តី នេះមិនគួរជាលេសសម្រាប់អូសបន្លាយពេលវេលា ក្នុងការអនុវត្តន៍ច្បាប់សេរីភាពខាងព័ត៌មាននោះទេ ។ ម.ស.ម.ក ទទួលស្គាល់ថា ច្បាប់សេរីភាពខាងព័ត៌មានតែមួយមុខ នឹងមិនគ្រប់គ្រាន់ ក្នុងការធានានូវលទ្ធភាពទទួលបានព័ត៌មាន សម្រាប់ពលរដ្ឋកម្ពុជានោះឡើយ ។ វប្បធម៌ដែលរបៀបព័ត៌មានទាំងនេះត្រូវបានគេប្រើប្រាស់ និងចែករំលែក ក៏ត្រូវការឲ្យមានការផ្លាស់ប្តូរផងដែរ ។ ទាំងនេះ ទាមទារនូវការផ្លាស់ប្តូរអត្តចរិតសាធារណជន ព្រមទាំងរដ្ឋាភិបាល ស្របនឹងការយល់ដឹងរបស់ពលរដ្ឋសាមញ្ញ អំពីតួនាទីរបស់ខ្លួនក្នុងសង្គមប្រជាធិបតេយ្យមួយ និងសិទ្ធិរបស់ខ្លួន ក្នុងការទាមទារព័ត៌មាន ពីអ្នកដែលមានសមត្ថកិច្ចទាំងអស់ ហើយរដ្ឋាភិបាលក៏ត្រូវតែទទួលស្គាល់ពីតួនាទីរបស់ខ្លួនជាតំណាងឲ្យពលរដ្ឋ ដែលតួនាទីនេះទាមទារឲ្យមានគណនេយ្យភាព ចំពោះពលរដ្ឋ ។

ដូចបានរៀបរាប់ខាងលើ និងបន្ថែមលើអនុសាសន៍នានាដែលបានលើកឡើងក្នុងជំពូកនីមួយៗ ម.ស.ម.ក ស្នើនូវអនុសាសន៍ទូទៅដូចខាងក្រោម ដើម្បីលើកកម្ពស់សេរីភាពខាងព័ត៌មាននៅកម្ពុជា ៖

- សេចក្តីព្រាងច្បាប់ស្តីពីសេរីភាពខាងព័ត៌មានដែលបានកែប្រែថ្មី ដែលបានស្នើដោយគណបក្សប្រឆាំង កាលពីខែមិនា ឆ្នាំ២០១២ គួរត្រូវបានយកមកពិភាក្សាដោយយកចិត្តទុកដាក់ ក្នុង

សម័យប្រជុំរបស់រដ្ឋសភា ដោយមានការកែតម្រូវសមស្របមួយ ដើម្បីធានាថាច្បាប់នេះគោរព តាមគោលការណ៍សេរីភាពខាងព័ត៌មាន និងគួរត្រូវបានអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភាមុន នឹងច្បាប់នេះត្រូវបានប្រកាសឲ្យប្រើប្រាស់ ។ ជម្រើសផ្សេងទៀត គឺថា ក.ទ.រ.ព.អ គួរសម្រេច លើគោលការណ៍សេរីភាពខាងព័ត៌មាន ដែលខ្លួនបានធ្វើសេចក្ដីព្រាងតាំងពីឆ្នាំ២០០៧ ហើយ នេះគួរតែត្រូវបានប្រើប្រាស់ជាមូលដ្ឋាន ក្នុងការពង្រាងច្បាប់សេរីភាពខាងព័ត៌មាននៅកម្ពុជា ។

- ច្បាប់សេរីភាពខាងព័ត៌មានណាមួយ ដែលនឹងត្រូវបានអនុម័ត ឲ្យប្រើប្រាស់នោះ គួរមានបញ្ចូល នូវសិទ្ធិរបស់ពលរដ្ឋគ្រប់រូប ក្នុងការទទួលបាន និងអាចស្នើសូមព័ត៌មាន ។
- រដ្ឋាភិបាល គួរធ្វើវិសោធនកម្មលើច្បាប់បណ្ណសារ ដើម្បីកំណត់និយមន័យ "ឯកសារផ្សព្វផ្សាយ" និងអនុញ្ញាតឲ្យមានលទ្ធភាពទទួលបានព័ត៌មានកាន់តែប្រសើរឡើង ។
- ស្ថាប័នសាធារណៈគួរធានាថា ខ្លួនមានវេបសាយ និងដាក់ចេញនូវគោលការណ៍ផ្ទៃក្នុងពាក់ព័ន្ធ នឹងការធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយព័ត៌មានលើវេបសាយនោះ ។
- ស្ថាប័នសាធារណៈទាំងអស់ គួរត្រូវបានរាជរដ្ឋាភិបាលលើកទឹកចិត្ត ក្នុងការអនុម័ត និងអនុវត្ត ក្រមផ្ទៃក្នុងស្ដីពីការទទួលបានព័ត៌មានដូចមានចែងក្នុងច្បាប់នានា ។

# ឯកសារយោង

## ច្បាប់ និងកតិកាសញ្ញាអន្តរជាតិ

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨
កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
កតិកាសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៥

## ច្បាប់ជាតិ

ច្បាប់បណ្ណសារ ឆ្នាំ២០០៥
ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៥
រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣
សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
សេចក្តីព្រាងច្បាប់គ្រប់គ្រងលើការប្រើប្រាស់អាស៊ីដ
សេចក្តីព្រាងច្បាប់ស្តីពីសហជីព
ច្បាប់ការងារ ឆ្នាំ១៩៩២
ច្បាប់ភូមិបាល ឆ្នាំ២០០១
ច្បាប់ស្តីពីការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦
ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ១៩៩៤
ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ឆ្នាំ២០០១
ច្បាប់ស្តីពីការគ្រប់គ្រង និងការទាញផលធនធានរ៉ែ ឆ្នាំ២០០១
ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
ច្បាប់របបសារព័ត៌មាន ឆ្នាំ១៩៩៥
ច្បាប់ប្រឆាំងអំពើពុករលួយ ឆ្នាំ២០១០
ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨
អនុក្រិតស្តីពីសម្បទានដីសេដ្ឋកិច្ច ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥

## លិខិតគតិយុត្ត

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ចុះនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ លេខ ០៩២/ ០០៣/២០០៧ ។

## របាយការណ៍ និងការផ្សព្វផ្សាយផ្សេងៗ

ស្ថាប័នគោលនយោបាយ និងការតស៊ូមតិ ខែធ្នូ ឆ្នាំ២០១០ "លទ្ធភាពទទួលបានព័ត៌មាន និងសភា"

អានន្រ្គូ អ៊ីលេស្លូន ខែកញ្ញាឆ្នាំ២០០៨ "សំណើយុទ្ធសាស្រ្តដើម្បីសេរីភាពខាងព័ត៌មាននៅកម្ពុជា"
អង្គការមាត្រា១៩ ថុមប៊ី) មេនឌែល ( ត្រូវការពារជាអន្តរដែលជាសិទ្ធិមនុស្សព័ត៌មានសេរីភាពខាង "
"ជាតិ

អង្គការមាត្រា១៩ ចុះផ្សាយខែធ្នូ ឆ្នាំ២០០៥ "សេរីភាពខាងបញ្ចេញមតិ និងសារព័ត៌មាន"

អង្គការមាត្រា១៩ ចុះផ្សាយខែកក្កដា ឆ្នាំ១៩៩៩ មានចំណងជើងថា "សិទ្ធិរបស់សាធារណជន

ក្នុងការដឹងឮ ៖ គោលការណ៍បញ្ញត្តិសេរីភាពខាងព័ត៌មាន" ដែលអាចរកមើលលើគេហទំព័រដែលមានអាសយដ្ឋាន ៖ www.article19.org/pdfs/standards/righttoknow.pdf.

អង្គការមាត្រា១៩ ចុះផ្សាយខែកញ្ញា ឆ្នាំ២០១១ "កម្ពុជា៖ សេចក្តីព្រាងច្បាប់ស្តីពីការទទួលបានព័ត៌មាន"

ធនាគារអភិវឌ្ឍន៍អាស៊ី (តារីដ ហោដ ណៃស្ស៊ី) ចុះផ្សាយនៅឆ្នាំ២០១១ មានចំណងជើងថា "កំណែទម្រង់វិមជ្ឈការ និងវិសមជ្ឈការនៅកម្ពុជា ៖ អនុសាសន៍សម្រាប់បែបផែនការងារស្ថាប័ន"

BNG Hemoregon, កុម្ភៈ ២០០៩ "ដីធ្លី និងការសាងសង់នៅកម្ពុជា"

ឯកសារវប្បធម៌ខ្មែរ ឆ្នាំ២០១១ អាចរកបាននៅ "កម្ពុជា ៖ ប្រវត្តិសារតាទិដ្ឋភាពទូទៅ" www.culturalprofiles.net/cambodia/Directories/Cambodia_Cultural_Profile/-1727.html

គណៈកម្មាធិការព្រឹត្តកម្មសិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១០ "នៅតែគ្មានហេតុផល ៖ ការបណ្តេញចេញដោយបង្ខំ និងការគំរាមកំហែងនៅកម្ពុជា"

កាបូហ្គាយ ឆ្នាំ២០១១ "ព្រះរាជាណាចក្រឋិតនៅបាតក្រោមចំពោះតម្លាភាពថវិកា" អាចរកមើលបាន ៖ www.camboguide.com/country-profile/latest-news/5233-kingdom-near-bottom-in-budget-transparency

*ម.ស.ម.ក ខែកញ្ញា ឆ្នាំ២០១០ "កម្ពុជាត្រូវបានបំបិទមាត់ ៖ លទ្ធិប្រជាធិបតេយ្យស្ថិតក្នុងភាពគ្រោះថ្នាក់?"*

ម.ស.ម.ក ខែមិនា ឆ្នាំ២០១០ "លិខិតរបស់ ម.ស.ម.ក ទៅកាន់ប្រធានរដ្ឋសភាពីសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ" អាចអានបាន ៖ www.cchrcambodia.org/English/add_press_release/press_release/cchr%20letter%20to%20the%20president%20of%20the%20national%20assembly%20concerning%20the%20draft%20anti-corruption%20law%20(english%20translation)(031010_1268279956).pdf.

*ម.ស.ម.ក ចុះផ្សាយថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០ ស្តីអំពី "សៀវភៅសង្ខេបសម្រាប់ម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធនានាស្តីអំពីច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងលំហាដែលរួមតូចសម្រាប់សង្គមស៊ីវិលនៅកម្ពុជា" ។*

*ម.ស.ម.ក ចុះផ្សាយថ្ងៃទីធ្នូ ឆ្នាំ២០១០ "របាយសង្ខេបស្តីពីអាជីវកម្ម និងសិទ្ធិមនុស្សនៅកម្ពុជា ៖សរសេរសង្ខេបី" ទំព័រ២ អាចរកមើលបាន ៖* www.cchrcambodia.org/English/add_report/reports/2010_11-30_bhr_report_eng.pdf.

*ម ក.ម.ស."ពង្រឹងការបោះឆ្នោត និងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ៖ របាយការណ៍របស់វេទិកាស្តីពីលំហាលទ្ធិប្រជាធិបតេយ្យ និងការបោះឆ្នោត" ខែកក្កដា ឆ្នាំ២០១១ ។ ១២*

ម.ស.ម.ក ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១១ "អត្ថបទគោលនយោបាយរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្តីពីស្ថានភាពបច្ចុប្បន្ននៃច្បាប់ស្តីពីការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល" អាចរកមើលបាន ៖

http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php &anid=15&id=5

ម.ស.ម.ក ខែវិច្ឆិកា ឆ្នាំ២០១១ "សោកនាដកម្មកោះពេជ្រ ៖ មួយឆ្នាំកន្លងផុត ចម្ងល់នៅតែបន្ត"

ម.ស.ម.ក ខែវិច្ឆិកា ឆ្នាំ២០១១ "សលាកបត្រព័ត៌មានសិទ្ធិមូលដ្ឋាន ៖ ការបិទសារព័ត៌មាន"

ខុមហ្វ្រែល ខែកុម្ភៈ ឆ្នាំ២០១០ "លទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់នៅកម្ពុជា" ទំព័រ ១២ អាចអានបាន ៖ www.comfrel.org/images/others/1265785063Comfrel-Cambodia%20Democratic %20Reform%202009-En-Final.pdf.

គណៈកម្មការសិទ្ធិមនុស្ស សម័យប្រជុំលើកទី៥១ ដោយលោក អាប៊ីដ ហ៊ូសេន ស្តីពី "របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ និងការការពារសេរីភាពខាងគំនិត និងខាងការបញ្ចេញមតិ" ឯកសាររបស់អង្គការសហប្រជាជាតិ E/CN.4/1995/32, កថាខ័ណ្ឌទី៣៥ ចុះផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៤ ។

គណៈកម្មការសិទ្ធិមនុស្ស សម័យប្រជុំលើកទី៥៤ មានចំណងជើងថា "របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ និងការការពារសេរីភាពខាងគំនិត និងខាងការបញ្ចេញមតិ" ឯកសាររបស់អង្គការសហប្រជាជាតិ E/CN.4/1999/64/32, កថាខ័ណ្ឌទី១២ ចុះផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៤ ។

*ក្រុមប្រឹក្សាកែទម្រង់ប្រព័ន្ធយុត្តិធម៌ ចុះផ្សាយខែមិថុនា ឆ្នាំ២០០៣ "កំណែទម្រង់ច្បាប់ និងយុត្តិធម៌" អាចរកមើលបាន ៖* www.cljr.gov.kh/eng/library/doc/o6-Legal.and.Judiciary.Reform.Strategy.pdf.

អង្គការឃ្លាំមើលពិភពលោក ចុះផ្សាយខែកុម្ភៈ ឆ្នាំ២០០៩ មានចំណងជើងថា "កម្ពុជា ៖ ប្រទេសសម្រាប់លក់" ។

អង្គការឃ្លាំមើលពិភពលោក មានចំណងជើងថា "ការផ្ទេរខ្សាច់ ៖ តើតម្រូវការខ្សាច់កម្ពុជារបស់ប្រទេសសឹង្ហបុរីគំរាមកំហែងដល់ប្រព័ន្ធជីវសាស្ត្រ និងអភិបាលកិច្ចល្អយ៉ាងណាដែរ" ចុះផ្សាយខែឧសភាឆ្នាំ២០១០ ។

របាយការណ៍របស់មជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់មិនយកកម្រៃ មានចំណងជើងថា "អ្នកឃ្លាំមើលច្បាប់ ៖ នៅកម្ពុជា" ចុះផ្សាយថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ អាចរកមើលបាន៖ www.incl.org/knowledge/ngolawmonitor/cambida.html

ទស្សនាវត្តីស្តីអំពីព័ត៌មាន ច្បាប់ និងបច្ចេកវិទ្យា (ដាញ៉ែល អេដឡឺ) មានចំណងជើងថា "ការទទួលបានព័ត៌មានច្បាប់នៅកម្ពុជា ៖ ជំហានចាប់ផ្តើម និងឱកាសនាពេលអនាគត" ចុះផ្សាយថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៦ ទំព័រ២ ។

របាយការណ៍របស់ក.ទ.រ.ព.អ មានចំណងជើងថា "ការទទួលបានព័ត៌មាន៖ បែបផែនការងារគោលការណ៍ច្បាស់លាស់សម្រាប់កម្ពុជា" ចុះផ្សាយថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៧

ការផ្តួចផ្តើមថវិកាបើកចំហ របាយការណ៍ថវិកាបើកចំហឆ្នាំ២០១០ អាចអានបាន ៖ http://internationalbudget.org/wp-content/uploads/2011/06/2010_Full_Report-English.pdf.

ការផ្តួចផ្តើមថវិកាបើកចំហ ខែមករា ឆ្នាំ២០១១, សន្ទស្សន៍នៃថវិកាបើកចំហ ឆ្នាំ២០១០, សេចក្តីសង្ខេបតម្លាភាពថវិកា ៖ កម្ពុជា វគ្គ៣ អាចអានបាន ៖ http://www.ngoforum.org.kh/eng/dip/dipdocs/NBP_OBI_Brief_2010-English.pdf ។

ការិយាល័យថ្នាក់តំបន់អាស៊ី ២០០៥ "រាប់បញ្ចូលខ្ញុំផង! របាយការណ៍ប្រវត្តិ យុទ្ធនាការUBR បណ្តោះអាសន្ន" ទំព័រ៨ អាចរកបាននៅ ssl.brookes.ac.uk/ubr/files/4/11-Count_me_in!_Report_Background_ARO.pdf.

សម្ព័ន្ធភាពផ្សព្វផ្សាយពីអ្វីដែលអ្នកបានចំណាយ ចុះផ្សាយខែវិច្ឆិកា ឆ្នាំ២០១០ មានចំណងជើងថា "បញ្ញត្តិបើកបង្ហាញព័ត៌មានអំពីឧស្សាហកម្មនិស្សារណកម្មក្នុងច្បាប់កំណែទម្រង់ Dodd-Frank Wall Street និងការការពារអតិថិជន " អាចរកមើលបាន ៖ http://www.cgdev.org/doc/blog/globaldevelopment/PWYP%20Fact%20Sheet%20on%20Extractive%20Industries%20Transparency%20Provision.pdf.

រ៉ែម៉ុន លីអូ ចុះផ្សាយថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ មានចំណងជើងថា "សិទ្ធិទទួលបានព័ត៌មាននៅតំបន់អាស៊ីអាគ្នេយ៍ និងកម្ពុជា" ទំព័រ៦ ដែលអាចរកមើលបានលើគេហទំព័រមានអាសយដ្ឋាន ៖ www.cchrcambodia.org/admin/media/report/report/english/2009-01-08-%20Access%20to%20Information%20in%20Southeast%20Asia%20and%20Cambodia-%20EN.pdf

របាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីទីលំនៅគ្រប់គ្រាន់ ជាផ្នែកមួយនៃសិទ្ធិទទួលបានជីវភាពរស់នៅសមរម្យ លោក មីលូន កូថារី ចុះផ្សាយថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៧ A/HRC/4/18 កថាខ័ណ្ឌ៣៨ ។

អ្នកសារព័ត៌មានគ្មានព្រំដែន ខែកុម្ភៈ ឆ្នាំ២០១០ ថាសន្យាបានមន្ត្រី លោករដ្ឋនាយកកម្ពុជា ៖ លោក" "ទេនោះពន្ធនាគារក្នុងចូលត្រូវនឹងណារូបមានសារព័ត៌អ្នកនគ្មានឹង

គោលការណ៍វិមជ្ឍការ និងវិសហមជ្ឈការបានចាប់ផ្តើមដោយមានការអនុម័តច្បាប់ស្តីពីការបោះឆ្នោតឃុំសង្កាត់២០០១ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ឆ្នាំ២០០១ ។

សមាគមផាងត្នោត ចុះផ្សាយខែធ្នូ ឆ្នាំ២០០៦ "អង្គហេតុ និងតួលេខ៖ ការផ្លាស់ទីតាំង ឬការបណ្តេញចេញ?" ទំព័រ២ ។

អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ និងការការពារសេរីភាពខាងគំនិត និងខាងការបញ្ចេញមតិ ចុះផ្សាយថ្ងៃទី២៥ ខែមិនា ឆ្នាំ ២០១០ ស្តីពី "សេចក្តីប្រកាសរួមខួបលើកទី១០ ៖ ការប្រឈម១០ចំណុចរបស់សេរីភាពខាងការបញ្ចេញមតិនាទសវត្សខាងមុខ" A/HRC/14/23/Add.2, ឃ្លាទី៤ អាចរកមើលបានលើគេហទំព័រដែលមានអាសយដ្ឋាន៖ www2.ohchr.org/english/bodies/hrcouncil/docs/14session/A.HRC.14.23.Add.2_en.pdf

ធនាគារពិភពលោក ខែកុម្ភៈ ឆ្នាំ២០០៩ "ប្រទេសកម្ពុជាភ្ជាប់ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋ ៖ ការវាយតម្លៃការរួមចំណែករបស់សង្គមស៊ីវិលចំពោះអភិបាលកិច្ចល្អ" ។

តម្លាភាពអន្តរជាតិ ឆ្នាំ២០១១ "សន្ទស្សន៍ការយល់ឃើញអំពើពុករលួយឆ្នាំ២០១១" ។

គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ចុះផ្សាយថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ មានចំណងជើងថា "សេចក្តីអធិប្បាយទូទៅ លេខ៣៤ មាត្រា១៩" CCPR/C/GC/34។

របាយការណ៍របស់អង្គការយូអិនឌីភី ចុះផ្សាយឆ្នាំ២០០៩ មានចំណងជើងថា "ការប្រកួតប្រជែងរបស់កម្ពុជា ៖ ជំហានដើម្បីអភិវឌ្ឍ និងកាត់បន្ថយភាពក្រីក្រ" ។

អង្គការយូនេស្កូ (ជំនួយការអគ្គនាយកទូទៅផ្នែកទំនាក់ទំនង និងព័ត៌មាន លោក អាប់ដុល វាហ៊ីតខាន់) ចុះផ្សាយឆ្នាំ២០០៨ មានចំណងជើងថា "សេរីភាពខាងព័ត៌មាន ៖ ការស្ទាបស្ទង់មតិច្បាប់ប្រៀបធៀប" ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស តំណាងពិសេសនៃអគ្គលេខាធិការស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា មានចំណងជើងថា "សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា ៖ ទស្សនទានខាងសិទ្ធិមនុស្ស" ។
www.sithi.org/landissue/source/ELC/OHCHR_ELC%20report_2007.pdf

របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ចុះផ្សាយខែកញ្ញា ឆ្នាំ ២០១០ មានចំណងជើងថា "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា" លេខ A/HRC/15/46, ទំព័រ៨ អាចរកមើលបាន ៖

http://cambodia.ohchr.org/EN/PagesFiles/Reports/SR-SRSG-Reports.htm

ទីភ្នាក់ងារផ្តល់ជំនួយអភិវឌ្ឍសហរដ្ឋអាមេរិក/កម្ពុជា (ម៉ៃឃើល អែម. ខាឡាវ៉ាន, ស៊ើជីអូ ដាយអាសប្រ៊ីក, ដើរ៉ល អូប្រៀន) ខែសីហា ឆ្នាំ២០០៤ "ការវាយតម្លៃអំពើពុករលួយនៅកម្ពុជា" ។

## សុន្ទរកថា និងបទសម្ភាសន៍

គ្រីស្តូប ពេស្វ ថ្ងៃ៤ ឧសភា ២០១០ សន្ទរកថានៅក្នុងខាងពិភពលោក សេរីភាពទិវាសារព័ត៌មាន" ,រៀបចំដោយ អង្គការយូនេស្កូ "ព័ត៌មាន៖ សិទ្ធិយល់ដឹងOHCHR ប្រចាំនៅកម្ពុជាជាមួយនឹងក្រសួងព័ត៌មាន ភ្នំពេញ កម្ពុជា។

លោក សុន ឆ័យ ដូចដែលបានដកស្រង់សម្តីក្នុងវិទ្យុអេប៊ីស៊ី, វិទ្យុអូស្ត្រាលី កាលពីថ្ងៃទី១២ ខែមិនា ឆ្នាំ២០១០ អត្ថបទអាចអានបាន ៖

www.radioaustralia.net.au/connectasia/stories/201003/s2843946.htm ។

សុន្ទរកថារបស់លោក សៀន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាលអ.វ.ត.ក ថ្លែងនៅសន្និសីទអន្តរជាតិដោះស្រាយនឹងរបបប្រល័យពូជសាសន៍នាពេលអតីតដែលរៀបចំធ្វើឡើងនៅទីក្រុងភ្នំពេញនៃប្រទេសកម្ពុជា ផ្សាយថ្ងៃទី២៨/២៩ ខែសីហា ឆ្នាំ ២០០៦ ដែលមានចំណងជើងថា "យុទ្ធសាស្ត្រកម្ពុជា៖ ការស្វែងរកការពិត និងផ្សះផ្សារជាតិនៅកម្ពុជាតាមរយៈអ.វ.ត.ក" អាចរកមើលបាន៖
www.eccc.gov.kh/english/cabinet/speeches/2/Finding_the_Truth_and_Reconciliation.pdf.

កិច្ចសម្ភាសន៍ជាមួយលោក ឡាលាណាត់ ដេ ស៊ីលវ៉ា ចុះផ្សាយនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១០ មានចំណងជើងថា "ច្បាប់សេរីភាពខាងព័ត៌មានត្រូវបានរាលដាលពេញពិភពលោក" ដែលអាចរកមើលលើគេហទំព័រដែលមានអាសយដ្ឋាន ៖www.wri.org/stories/2010/09/freedom-information-laws-spreading-around-world.

## សារព័ត៌មាន និងសេចក្តីថ្លែងការណ៍

ម.ស.ម.ក "សេចក្តីថ្លែងការណ៍ ៖ ម.ស.ម.ក ស្វាគមន៍រាជរដ្ឋាភិបាលកម្ពុជាចំពោះជំហានឆ្ពោះទៅមុខនៃច្បាប់សេរីភាពខាងព័ត៌មាន" ចុះផ្សាយថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០ ដែលអាចរកមើលបានតាមរយៈគេហទំព័រដែលមានអាសយដ្ឋាន ៖
www.cchrcambodia.org/English/add_press_release/press_release/2010_12_08_cchr_press_release.pdf

*យុទ្ធនាការសម្លៀកបំពាក់ស្អាត ចុះផ្សាយថ្ងៃទី១៥ ខែមិនា ឆ្នាំ២០១១ "ការតម្លើងប្រាក់ខែនៅកម្ពុជា" អាចរកមើលបាន៖* www.cleanclothes.org/news/wage-increase-for-cambodian-garment-workers

[1] របាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស មានចំណងជើងថា "សវនាការលើមេដឹកនាំគណបក្សប្រឆាំងលោក សម រង្ស៊ី គឺជាឆាកល្ខោន" ចុះផ្សាយថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ អាចរកមើលបាន ៖ www.hrw.org/en/news/2010/01/28/cambodia-opposition-leader-sam-rainsy-s-trial-farce.

កាសែតឌឹខេមបូឌាដេលី មានចំណងជើងថា "សេចក្តីព្រាងច្បាប់អាស៊ីដទើបត្រូវបានយកមកពិភាក្សា" ចុះផ្សាយថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

កាសែតឌឹខេមបូឌាដេលី មានចំណងជើងថា "ការកែសម្រួលថ្មីលើច្បាប់ទឹកអាស៊ីដ បានសំរាលការដាក់ពិន័យ" ចុះផ្សាយថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១ ។

កាសែតឌឹខេមបូឌាដេលី មានចំណងជើងថា "គ្មានបញ្ញត្តិតម្លាភាពក្នុងសេចក្តីព្រាងច្បាប់ស្តីពីប្រេងកាត" ចុះផ្សាយថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១១ ។

កាសែតឌឹខេមបូឌាដេលី មានចំណងជើងថា "រដ្ឋាភិបាលនឹងលុបចេញនូវការទាមទារចុះបញ្ជីជាដាច់ខាតចេញពីច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល" ចុះផ្សាយថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ ។

កាសែតឌឹខេមបូឌាដេលី មានចំណងជើងថា "ក្រសួងផ្តល់សិទ្ធិថ្មីដល់កាសែតប្រឆាំងអំពើពុករលួយ"

អត្ថបទកាសែតហ្វ៊ីហ្វ៊ីងតុនបុស្តិ៍ មានចំណងជើងថា "ការបូមខ្សាច់នៅកម្ពុជា គំរាមកំហែងដល់បរិស្ថាន និងឧស្សាហកម្មទេសចរណ៍សេដ្ឋកិច្ច" ចុះផ្សាយថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ អាចរកមើលបាន ៖ www.dredgingtoday.com,

កាសែតឌឹភ្នំពេញបុស្តិ៍ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០ "ទាហានដើម្បីការបញ្ចេញមតិដោយសេរី" ។

កាសែតឌឹភ្នំពេញបុស្តិ៍ មានចំណងជើងថា "ក្រុមហ៊ុនតូតាល់អះអាងទឹកប្រាក់ចំនួន៨ លានដុល្លារសហរដ្ឋអាមេរិក សម្រាប់មូលនិធិសង្គម" ចុះផ្សាយថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០ ។

**ការសែត**ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១០ "បណ្តឹងស្តីពីការជំរិតទារប្រាក់កើនឡើង" ។

កាសែតឌឹភ្នំពេញបុស្តិ៍ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ "ការបង្ក្រាបខ្សែវីដេអូនៅកោះពេជ្រ" ។

កាសែតឌឹភ្នំពេញបុស្តិ៍ មានចំណងជើងថា "ការបូមខ្សាច់នៅខេត្តកោះកុងបានបន្តសារជាថ្មី" ចុះផ្សាយថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ ។

កាសែតឌឹភ្នំពេញបុស្តិ៍ ចុះផ្សាយថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ មានចំណងជើងថា "កម្ពុជា៖ ព្រៃឈើបិតក្រោមការគំរាមកំហែង" ។

សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ "វេបសាយរបស់គណបក្សប្រឆាំងត្រូវបានបិទ" ។

សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១១ "នាយករដ្ឋជំរុញឲ្យមានក្រុមការងារផ្នែកសារព័ត៌មាន"

សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី២ ខែមិនា ឆ្នាំ២០១២ "តំណាងរាស្ត្រគណបក្ស សម រង្ស៊ី ៖យ៉ាងហោចណាស់ត្រូវមានការជជែកវែកញែកលើសេចក្តីព្រាងច្បាប់អំពីសេរីភាពសារព័ត៌មាន"

សារព័ត៌មាន ឌឹ ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នា២០១១ "ការផ្លាស់ប្តូរយ៉ាងសំបើម ចំពោះសេចក្តីព្រាងច្បាប់សហជីព" ។

យូសេហ្វឧបត្ថម្ភកិច្ចប្រជុំស្តីពីសេរីភាពខាងព័ត៌មានសម្រាប់តំណាងរាស្ត្រកម្ពុជា" ចុះផ្សាយថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលអាចរកមើលតាមគេហទំព័រដែលមានអាសយដ្ឋាន៖ www.usaid.gov/kh/documents/USAID_Highlights_Feb22_08.pdf.

អត្ថបទវិទ្យុសម្លេងអាមេរិក ចុះផ្សាយថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១០ មានចំណងជើងថា "កម្ពុជាជម្រុញឲ្យចូលរួមជាសមាជិកនៃគំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម" អាចរកមើលបាន ៖ www.voanews.com/khmer-english/news/economy-business/a-40-2010-04-06-voa8-90235222.html.

អត្ថបទរបស់សារព័ត៌មានវិទ្យុសម្លេងអាមេរិក មានចំណងជើងថា "វិធីរបស់បក្សប្រឆាំងចំពោះច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលទទួលរងការរិះគន់" ចុះផ្សាយថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១១ អាចរកមើលបាន ៖ www.voanews.com/khmer-english/news/Opposition-Party-Wary-of-Revamped-NGO-Law-115011769.html.

អត្ថបទវិទ្យុសម្លេងសហរដ្ឋអាមេរិក ចុះផ្សាយថ្ងៃទី១៥ ខែមិនា ឆ្នាំ២០១១ "សហជីពជួបប្រជុំគ្នាពិភាក្សាលើចំណុចព្រួយបារម្ភចំពោះសេចក្តីព្រាងច្បាប់" អាចរកមើលបាន ៖ www.voanews.com/khmer-english/news/Unions-Meet-Over-Worries-in-Draft-Law-118006569.html

www.dredgingtoday.com,

វិទ្យុសំឡេងសហរដ្ឋអាមេរិក ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ "ការធ្វើសវនកម្មក្នុងឆ្នាំ ២០០៧ រកឃើញថាមានភាពខុសប្រក្រតី និងភាពគ្មានប្រសិទ្ធភាព" អាចអានបាន ៖ www.voanews.com/khmer-english/news/2007-Audit-Finds-Irregularities-Inefficiencies--130348243.html

វិទ្យុសំឡេងសហរដ្ឋអាមេរិក ថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១២ "ប្រជាពលរដ្ឋខ្មែរជាង១៥ភាគរយ ជួបបញ្ហាដីសម្បទាន ៖ យោងតាមរបាយការណ៍" អាចរកមើលបាន ៖ http://voanews.com/khmer-english/news/Nearly-15-Percent-of-Cambodia-Under-Land-Concession-Report-143992206.html

វិទ្យុសំឡេងសហរដ្ឋអាមេរិក ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ "ឥឡូវនេះ អំពើពុករលួយដែលរីករាលដាល "មានលក្ខណៈជាប្រព័ន្ធ ៖ យោងតាមអង្គការតម្លាភាពអន្តរជាតិ" អាចរកមើលបាន ៖

http://www.voanews.com/khmer-english/news/Widespread-Corruption-Now-Systemic-Transparency-International-146868565.html

អត្ថបទមានចំណងជើងថា "កម្ពុជា៖ ការបូមខ្សាច់ដែលមានភាពចម្រូងចម្រាស់នៅទន្លេតាតៃនៅតែបន្ត" ចុះផ្សាយថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ ។

## វែបសាយ

រោងចក្រប្រសើរឡើងនៅកម្ពុជា ៖ www.betterfactories.org/ILO/aboutBFC.aspx?z=2&c=1

គេហទំព័រសិទ្ធិមនុស្សនៅកម្ពុជា ៖ www.sithi.org

អាជ្ញាធរជាតិប្រេងកាតកម្ពុជា ៖ www.cnpa.gov.kh

ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ៖ www.ccc.gov.kh/english/index.php

កិច្ចពិភាក្សារបស់រដ្ឋសភា ៖ www.ustream.tv/channel/debate-from-cambodian-national-assembly

អង្គការពលកម្មអន្តរជាតិ៖ www.ilo.org

ទីផ្លាខ្មែរ ៖ khcampus.wordpress.com/2010/02/14/what-is-freedom-of-information/

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ៖ www.ncdd.gov.kh/

សម្ព័ន្ធភាពផ្សព្វផ្សាយពីអ្វីដែលអ្នកបានចំណាយ៖ www.publishwhatyoupay.org

សិទ្ធិទទួលព័ត៌មាន ៖ right2info.org/laws.

តុលាការកំពូលកម្ពុជា ៖ www.supremecourt.gov.kh/

បណ្ណសារដ្ឋានជាតិកម្ពុជា ៖ www.nac.gov.kh/english/